**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Économiques**
**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# ពន្ធលើប្រាក់បៀវត្ស
# និងពន្ធលើអត្ថប្រយោជន៍បន្ថែម

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ៖ លោក **សាង សុជីវិត**
លោក **ហួន សុវណ្ណារ៉ា**

សាស្ត្រាចារ្យណែនាំ
លោក **ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal University of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# ពន្ធលើប្រាក់បៀវត្ស
# និងពន្ធលើអត្ថប្រយោជន៍បន្ថែម

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **សាង សុជីវិត**

លោក **ឃួន សុវណ្ណារ៉ា**

សាស្ត្រាចារ្យណែនាំ

លោក **ឆេព សុខ**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **សាន សុជីវិត** និងខ្ញុំបាទឈ្មោះ **ហួន សុវណ្ណារ៉ា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៥ ២០១៩ បានសរសេរសារណា ដើម្បីបញ្ចប់ការសិក្សាក្រោមប្រធានបទ **ពន្ធលើប្រាក់បៀវត្ស (ពបវ) និងពន្ធលើអត្ថប្រយោជន៍បន្ថែម។**

សូមសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ

លោកឪពុក **សាន សម** និងអ្នកម្តាយ **កែវ សុនារី**

លោកឪពុក **ហួន សារ៉ាន់** និងអ្នកម្តាយ **ស សុខា**

កូនសូមថ្លែងនូវសេចក្តីគោរពដឹងគុណ ចំពោះលោកអ្នកមានគុណទាំងពីរ ដែលបានបង្កើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ប្រៀនប្រដៅ ប្រកបដោយព្រហ្មវិហាធម៌ទាំងបួនគឺ មេត្តា ករុណា មុទិតា និងឧបេក្ខា ចំពោះកូនជានិច្ច។ នៅពេលដែលកូននៅវ័យកុមារ ដែលជាវ័យមិនមានការយល់ដឹងអ្វីទាំងអស់ លោកតែងតែផ្តល់សេចក្តីស្រលាញ់ មិនប្រកាន់រាល់កំហុសរបស់កូន តែផ្ទុយទៅវិញ លោកបែរជាបន្ថែមនូវការថ្នាក់ថ្នមប្រកបដោយភាពកក់ក្តៅ។ នៅខណៈពេលដែលកូនឈានដល់វ័យទទួលការអប់រំ លោកក៏បញ្ជូនកូនទៅទទួលការអប់រំនៅសាលារៀនដោយមិនគិតពីការចំណាយ លោកបានខិតខំទាំងកម្លាំងកាយ និងកម្លាំងចិត្តដោយមិនខ្លាចនឿយហត់ ដើម្បីទំនុកបម្រុងកូនឱ្យទទួលបាននូវចំណេះដឹងដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ហើយនេះក៏ជាទ្រព្យសម្បត្តិមួយ ដែលកូនប្រើមិនអស់ក្នុងមួយឆាកជីវិតនេះ។ ទោះបីជាសាលារៀននោះជាសាលារដ្ឋ ឬសាលារៀនឯកជនក្តី លោកទាំងពីរបានបញ្ជូនកូនមកសិក្សា ដើម្បីក្រេបយកចំណេះដឹង ជំនាញ ដែលទាំងនេះបានធ្វើឱ្យកូនចាកផុតពីភាពល្ងង់ខ្លៅ និងក្លាយជាបុគ្គលដែលប្រកបដោយគន្លងធម៌ គុណធម៌ សីលធម៌។

យើងខ្ញុំសូមសម្តែងការដឹងគុណចំពោះ **បងប្អូនទាំងប្រុស ទាំងស្រី** របស់យើងខ្ញុំ ដែលបងប្អូនប្រុសស្រី តែងតែផ្តល់ក្តីអាណិតស្រលាញ់មើលថែថ្នាក់ថ្នម ពុំដែលមានការគុំគួនដល់យើងខ្ញុំម្តងណាឡើយ។ មិនត្រឹមតែប៉ុណ្ណោះ គឺជាអ្នកផ្តល់យោបល់យ៉ាងមានភាពកក់ក្តៅ និងជាអ្នកផ្តល់កម្លាំងចិត្តយ៉ាងសំខាន់ដែលជួយជំរុញ និងចម្លងយើងខ្ញុំបានបោះជំហានចូល និងបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះដោយជោគជ័យ។

យើងខ្ញុំសូមថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់បំផុតចំពោះ **ឯកឧត្តម លុយ ចណ្ណា** សាលកវិទ្យាធិការ ព្រមទាំងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានលះបង់នូវរាល់កម្លាំងកាយ កម្លាំងចិត្តក្នុងការដឹកនាំ បង្ហាត់បង្រៀន ដើម្បីផ្តល់នូវចំណេះដឹងថ្មីៗ

និងដំបូន្មានល្អៗដល់យើងខ្ញុំ។ តាមរយៈឧបការគុណរបស់អស់លោក លោកស្រី ទើបធ្វើឱ្យយើងខ្ញុំទទួលបាននូវចំណេះដឹងល្អៗ និងចំណេះធ្វើផ្សេងៗ ដែលនាំឱ្យយើងខ្ញុំអាចបញ្ចប់ការសិក្សាប្រកបដោយភាពជោគជ័យនាពេលនេះ។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាស្ត្រាចារ្យ **ទេព សុខ** ដែលជាសាស្ត្រាចារ្យដឹកនាំសារណាបញ្ចប់ការសិក្សានេះ។ លោកបានចំណាយពេលវេលាដ៏មានតម្លៃ ព្រមទាំងលះបង់អស់នូវកម្លាំងកាយនិងចិត្ត ជួយណែនាំ ផ្តល់ដំបូន្មាន អនុសាសន៍នានា ដើម្បីកែសម្រួល និងតម្រង់ទិសយើងខ្ញុំ រហូតដល់សារណានេះទទួលបានជោគជ័យ។

ជាចុងក្រោយ កូនសូមជូនពរដល់លោកឪពុកអ្នកម្តាយ ហើយក៏សូមជូនពរដល់អស់លោក លោកស្រី សាស្ត្រាចារ្យ សិស្ស និស្សិត និងមិត្តអ្នកអានឱ្យជួបប្រទះតែសំណាងល្អ ទទួលបាននូវភាពជោគជ័យក្នុងជីវិត មានសុខភាពល្អ។ ជាពិសេសសូមឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំទាំងពីរនាក់ ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រអស់រយៈពេល ៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួចមក មានការចាប់អារម្មណ៍លើពន្ធអាករយ៉ាងខ្លាំង ដោយយើងខ្ញុំយល់ឃើញថាចំណូលពន្ធគឺជាប្រភពមួយដ៏សំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសកម្ពុជា។ ជាមួយគ្នានេះដែរ យើងខ្ញុំសង្កេតឃើញថា ការយល់ដឹងរបស់ប្រជាពលរដ្ឋទៅលើបញ្ហាពន្ធក៏ពុំសូវទូលំទូលាយ ចំណែកឯមន្ត្រីរាជការ និងបុគ្គលិកក្រុមហ៊ុននានាដែលកំពុងបំពេញមុខងារទាក់ទងនឹងពន្ធទៀតសោត ក៏ជួបប្រទះនូវផលវិបាកក្នុងការបំពេញការងាររបស់ខ្លួនផងដែរ។ ជាងនេះទៅទៀតឯកសារដែលសរសេរ រៀបរាប់ ពន្យល់អំពីបញ្ហាពន្ធ ក៏ពុំសូវមានច្រើននោះទេ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកស្រាវជ្រាវជំនាន់ក្រោយ ក៏ដូចជាតម្រូវការរបស់មិត្តអ្នកអាន ព្រមទាំងជាការស្រលាញ់ពេញចិត្តផ្ទាល់ខ្លួន ហើយជាពិសេសដើម្បីទុកជាឯកសារក្រោយពេលបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ទើបយើងខ្ញុំទាំងពីរនាក់សម្រេចចិត្តជ្រើសយកប្រធានបទស្តីពី "**ពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម**" ដើម្បីលើកយកមកធ្វើការសិក្សាស្រាវជ្រាវ តាក់តែងចងក្រងជាសារណានេះឡើង។

យើងខ្ញុំពិតជាមានមោទកភាពជាខ្លាំងចំពោះស្នាដៃនេះ ដោយហេតុថា នេះជាការស្រាវជ្រាវមួយដែលថ្មី ស្របជាមួយនិងបរិបទនៃការផ្លាស់ប្តូរកែទម្រង់យ៉ាងច្រើនក្នុងវិស័យពន្ធដារនៅកម្ពុជា។ ជាងនេះទៅទៀត យើងខ្ញុំអាចបង្កើតស្នាដៃនេះឡើង ខណៈពេលដែលយើងខ្ញុំមានការលំបាកខ្លាំងក្នុងការស្វែងរកឯកសារ និងសរសេរឱ្យបានត្រឹមត្រូវតាមក្បួនខ្នាត។ ក្នុងស្នាដៃនេះ ត្រូវបានសរសេររៀបរាប់អំពី ទ្រឹស្តីដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋាននានាដែលចេញដោយក្រសួង និងស្ថាប័នពាក់ព័ន្ធនានា សៀវភៅរបស់អ្នកនិពន្ធនានា ឯកសារផ្សេងៗជាច្រើនទៀត ព្រមទាំងបានឃើញពីការបំពេញមុខងារជាក់ស្តែងរបស់មន្ត្រីពាក់ព័ន្ធ និងធ្វើការស្រាវជ្រាវនៅស្ថាប័នពាក់ព័ន្ធនានា ដើម្បីយកឯកសារមកធ្វើជាឧបសម្ព័ន្ធគាំទ្រដល់សារណានេះ។

យើងខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា ស្នាដៃនេះពិតជាអាចចូលរួមចំណែកក្នុងការផ្តល់នូវចំណេះដឹងផ្នែកច្បាប់ទៅដល់បងប្អូនប្រជាពលរដ្ឋ មិត្តអ្នកអាន សិស្ស និស្សិត អ្នកស្រាវជ្រាវជំនាន់ក្រោយៗទៀត និងដើម្បីចូលរួមលើកស្ទួយវិស័យពន្ធនៅកម្ពុជាឱ្យកាន់តែរីកចម្រើន។

យើងខ្ញុំទាំងពីរនាក់ក៏សូមអភ័យទោសផងដែរ ចំពោះកំហុសឆ្គងដោយអចេតនាដែលកើតមានឡើងនៅពេលសរសេរ និងចងក្រងឯកសារមួយនេះ ព្រោះការយល់ដឹង ក៏ដូចជាបទពិសោធន៍របស់យើងខ្ញុំទាំងពីរនៅមានកម្រិតនៅឡើយ។ យើងខ្ញុំទាំងពីរនឹងទទួលយកនូវការណែនាំល្អៗ ការរិះគន់ក្នុងន័យស្ថាបនា ពីសំណាក់លោកគ្រូ អ្នកគ្រូ និងមិត្តអ្នកអានទាំងអស់ដោយក្តីរីករាយ។

# មាតិកា

ទំព័រ

**សេចក្ដីផ្ដើម**............................................................................................. ១

## ជំពូកទី១

## ទិដ្ឋភាពទូទៅនៃប្រព័ន្ធពន្ធដារនៅប្រទេសកម្ពុជា

១.១. ប្រវត្តិច្បាប់ពន្ធដារនៅព្រះរាជាណាចក្រកម្ពុជា........................................ ៣

១.២. ដើមកំណើតនៃអគ្គនាយកពន្ធដារ និងរដ្ឋបាលពន្ធដារ .................................. ៣

១.២.១. ការបង្កើតអគ្គនាយកដ្ឋានពន្ធដារ......................................................... ៣

១.២.២. រចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធដារ........................................................៤

១.២.៣. បេសកកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ...................................................៤

១.២.៤. តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ........................................៥

១.៣. ទ្រឹស្ដីទូទៅនៃពន្ធដារ ..........................................................................៦

១.៣.១. ពន្ធផ្ទាល់ និងពន្ធប្រយោល .................................................................៦

១.៣.២. ការបង្វៀងពន្ធ និងការគេចវេសពន្ធ ......................................................៧

១.៣.៣. របបពន្ធដារ ប្រភេទពន្ធដារ និងការចុះបញ្ជី.............................................៨

ក. របបពន្ធដារ ......................................................................................៨

ខ. ប្រភេទពន្ធ.........................................................................................៨

គ. ការចុះបញ្ជីពន្ធដារ ..............................................................................៩

ឃ. ការងារបិទបញ្ជីពន្ធដារប្រចាំខែ និងប្រចាំឆ្នាំ ........................................... ១៨

## ជំពូកទី២

## ការអនុវត្តពន្ធលើប្រាក់បៀវត្ស (ពបវ)

២.១. ការវិវត្តប្រភេទពន្ធលើប្រាក់បៀវត្សនៅកម្ពុជា .........................................១៩

២.២. បញ្ញត្តិស្ដីពីពន្ធលើប្រាក់បៀវត្ស ............................................................២០

២.២.១. និយមន័យ .........................................................................................២០

២.២.២. ដែនវិសាលភាពនៃពន្ធលើប្រាក់បៀវត្ស.................................................... ២១

២.២.៣. ការវៀរលែងពន្ធលើប្រាក់បៀវត្ស............................................................... ២២
២.២.៤. អត្រាពន្ធលើប្រាក់បៀវត្ស............................................................... ២៣
២.២.៥. ទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក............................................................... ២៣
២.២.៦. កាតព្វកិច្ចរបស់និយោជក និងនិយោជិត............................................................... ២៤
២.៣. ការគណនាពន្ធលើប្រាក់បៀវត្ស............................................................... ២៥
២.៣.១. មូលដ្ឋានលើការគណនាពន្ធប្រាក់បៀវត្ស............................................................... ២៥
២.៣.២. វិធីសាស្រ្តគណនាពន្ធលើប្រាក់បៀវត្សសម្រាប់និវាសនជន............................................................... ២៦
ក. វិធានទី១ - វិធីសាស្រ្តបូកបន្ថែម............................................................... ២៦
ខ. វិធានទី២- វិធីសាស្រ្តដកបន្ថយ............................................................... ២៧
២.៣.៣. វិធីគណនាពន្ធលើប្រាក់បៀវត្សតាមវិធីឆាប់រហ័ស............................................................... ២៩
២.៣.៤. វិធីគណនាពន្ធលើប្រាក់បៀវត្សតាមកម្មវិធីទូរសព្ទដៃ............................................................... ៣១
២.៣.៥. វិធីសាស្រ្តគណនាពន្ធលើប្រាក់បៀវត្សសម្រាប់អនិវាសនជន............................................................... ៣២

**ជំពូកទី៣**

**វិធីសាស្រ្តគណនាពន្ធលើអត្ថប្រយោជន៍បន្ថែម និងឥណទានពន្ធបរទេស**

៣.១. ពន្ធលើអត្ថប្រយោជន៍បន្ថែម............................................................... ៣៣
៣.១.១. តើអ្វីជាអត្ថប្រយោជន៍បន្ថែម?............................................................... ៣៣
៣.១.២. វិសាលភាពនៃអត្ថប្រយោជន៍បន្ថែម............................................................... ៣៣
៣.១.៣. ការគណនាពន្ធលើអត្ថប្រយោជន៍បន្ថែម............................................................... ៣៥
៣.២. ឥណទានពន្ធបរទេស............................................................... ៣៧
៣.២.១. ការគណនាឥណទានពន្ធបរទេស............................................................... ៣៨
**សេចក្តីសន្និដ្ឋាន**............................................................... ៤០
**អនុសាសន៍**............................................................... ៤២
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ចសព | : | ច្បាប់ស្តីពីសារពើពន្ធ |
| សហវ | : | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| អពដ | : | អគ្គនាយកដ្ឋានពន្ធដារ |
| បវ | : | ប្រាក់បៀវត្សជាប់ពន្ធ |
| ពបវ | : | ពន្ធលើប្រាក់បៀវត្ស |
| មពបវ | : | មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស |
| លបព | : | លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ |
| អតប | : | អាករលើតម្លៃបន្ថែម |
| VAT | : | Value Added Tax |
| TIN | : | Tax Identification Number |

# សេចក្តីផ្តើម

# សេចក្តីផ្តើម

រដ្ឋនីមួយៗ អាចទទួលបានការអភិវឌ្ឍទៅបាន លុះត្រាតែមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ។ ការចូលរួមរបស់ប្រជាពលរដ្ឋក្រៅពីការចូលរួមក្នុងសកម្មភាពផ្សេងៗ ប្រជាពលរដ្ឋនៅមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋជាទឹកប្រាក់មួយចំនួន ដើម្បីឱ្យរដ្ឋយកប្រាក់នេះទៅប្រើប្រាស់ក្នុងវិស័យសាធារណៈមួយចំនួនដូចជា កសាងសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ ឱ្យបានគ្រប់គ្រាន់ និងមានប្រសិទ្ធភាពសម្រាប់ប្រើប្រាស់នៅតាមតំបន់នីមួយៗ។ ម្យ៉ាងវិញទៀត វិស័យពន្ធដារក៏បានជួយជំរុញឱ្យមានកំណើនអ្នកវិនិយោគ ចូលមកបោះទុនវិនិយោគនៅក្នុងប្រទេសកម្ពុជាកាន់តែច្រើនថែមទៀត តាមរយៈគោលនយោបាយអនុគ្រោះពន្ធ និងការបន្ថយអត្រាពន្ធនាំចេញ-នាំចូលដែលបានធ្វើឱ្យសកម្មភាពអាជីវកម្មក្នុងស្រុកមានការកើនឡើង ដែលជាកត្តាមួយជំរុញឱ្យសេដ្ឋកិច្ចក្នុងស្រុករីកចម្រើនទៅមុខ និងជួយឱ្យប្រជាពលរដ្ឋមានការកើនឡើងនូវប្រាក់ចំណូលផងដែរ។ ពិសេសជាងនេះទៅទៀតការយកពន្ធ ឬយកអាករនេះ បានផ្តល់ជាមធ្យោបាយមួយដល់រដ្ឋាភិបាលកំណត់យកពីអ្នកមានលទ្ធភាព ទៅជួយដល់ប្រជាពលរដ្ឋដែលមានជីវភាពមិនសូវធូរធារ តាមរយៈការប្រើប្រាស់សេវាសាធារណៈដោយមិនចាំបាច់បង់ប្រាក់ ឬដោយបង់ប្រាក់ក្នុងកម្រិតមួយតិចតួចបំផុត។ នៅក្នុងចំណោមប្រភេទពន្ធទាំងអស់ **ពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម** ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន មានចំនួនប្រហែល ២០% (ម្តៃភាគរយ) នៃចំនួនប្រាក់ពន្ធសរុបដែលប្រមូលបានពីពន្ធគ្រប់ប្រភេទ។

**ពន្ធ** គឺជាកាតព្វកិច្ចដែលកំណត់ដោយច្បាប់ចំពោះ រូបវន្តបុគ្គល សាជីវកម្ម ឬសហគ្រាសដែលត្រូវបង់ពន្ធជូនរដ្ឋ ដោយផ្អែកលើប្រាក់ចំណូល ឬប្រាក់ចំណាយរបស់ប្រជាពលរដ្ឋ។ ជាមួយគ្នានេះដែរ ការប្រមូលពន្ធមាន២បែបគឺ ការប្រមូលដោយផ្ទាល់ ដែលគេប្រើវាក្យស័ព្ទ **ពន្ធ** រីឯការប្រមូលពន្ធដោយប្រយោលគេប្រើវាក្យស័ព្ទ **អាករ**។

ការស្រាវជ្រាវនេះ មានគោលបំណងពន្យល់អំពីអត្ថន័យពន្ធអាករ និងពន្យល់ពីការវិវត្តនៃការយកពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម។ ជនទាំងឡាយមិនថាជា និវាសនជន ឬអនិវាសនជន ដែលបាននឹងកំពុងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយកំពុងបម្រើការងារក្នុងគ្រឹះស្ថានសាធារណៈ ឬឯកជន ដើម្បីយកប្រាក់ឈ្នួលជាប្រភពចំណូលរបស់ខ្លួន ជនទាំងនោះមានកាតព្វកិច្ចបង់ពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែមផ្សេងៗទៀត ទៅតាមកម្រិតប្រាក់បៀវត្សដែលខ្លួនទទួលបាន និងដែលបានកំណត់ដោយច្បាប់។ ការសិក្សាអំពីពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែមបានដកស្រង់យក ច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងឯកសារនានា ដើម្បីរៀបរៀង និងសរសេរជាសៀវភៅនេះឡើង ក្នុងគោលបំណងស្វែងយល់អំពីពន្ធ

មួយប្រភេទនេះ និងយល់ឱ្យកាន់តែស៊ីជម្រៅអំពីការអនុវត្តការប្រមូលពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

លទ្ធផលដែលកើតចេញពីការស្រាវជ្រាវនេះនឹងចូលរួមចំណែកក្នុងការផ្តល់ជាពុទ្ធិ និងបំណិនទាក់ទងនឹងការប្រមូលពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម នៅព្រះរាជាណាចក្រកម្ពុជា ហើយដែលអនុលោមទៅតាមច្បាប់ស្តីពីសារពើពន្ធកម្ពុជា ក៏ដូចជាចូលរួមចំណែកអនុវត្តន៍ច្បាប់សារពើពន្ធនៃកម្ពុជាជាមូលដ្ឋាន។ ជាងនេះទៅទៀត ក៏នឹងជួយជំរុញជនដែលជាប់កាតព្វកិច្ចបង់ពន្ធ បានយល់ដឹងពីកាតព្វកិច្ចរបស់ខ្លួនក្នុងការបង់ពន្ធជូនរដ្ឋ ដែលអាចឱ្យរដ្ឋមានចំណូលកាន់តែច្រើនសម្រាប់ការអភិវឌ្ឍប្រទេស ។

វិសាលភាពនៃការស្រាវជ្រាវនេះផ្តោតទៅលើពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ចាប់ពីឆ្នាំ១៩៩៧ ដល់ ឆ្នាំ២០១៩ រួមជាមួយនិងការរំលឹកអំពីទ្រឹស្តីពន្ធដារ ក៏ដូចជាវិធាននានាដែលត្រូវបានដាក់ឱ្យអនុវត្តន៍ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានអគ្គនាយកដ្ឋានពន្ធដារជាសេនាធិការ សម្រាប់ធ្វើកិច្ចការប្រមូលពន្ធ ដើម្បីបង្កើនចំណូល និងលុបបំបាត់ឱនភាពថវិការដ្ឋ។

តើពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ត្រូវបានគណនាដូចម្តេច? ផ្អែកលើអ្វីជាមូលដ្ឋានគិតពន្ធ? ហើយរដ្ឋធ្វើការប្រមូលពន្ធតាមរបៀបណា? ដើម្បីបកស្រាយប្រធានបទ **ពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម** ឱ្យបានលម្អិត និងគ្រប់ជ្រុងជ្រោយឆ្លើយតបទៅនិងបញ្ហាគតិយុត្ត ដូចដែលបានចោទខាងលើនេះ ការស្រាវជ្រាវនេះត្រូវបានរៀបចំជាបីជំពូកធំៗដូចខាងក្រោម៖

**ជំពូកទី១ ទិដ្ឋភាពទូទៅនៃពន្ធដារនៅប្រទេសកម្ពុជា**

**ជំពូកទី២ សញ្ញាណគតិយុត្តលើប្រាក់បៀវត្ស**

**ជំពូកទី៣ អត្ថប្រយោជន៍បន្ថែម និងឥណទានបរទេស**

# ជំពូកទី១

# ទិដ្ឋភាពទូទៅនៃ
# ប្រព័ន្ធពន្ធដារនៅកម្ពុជា

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃប្រព័ន្ធពន្ធដារនៅប្រទេសកម្ពុជា

## ១.១. ប្រវត្តិច្បាប់ពន្ធដារនៅព្រះរាជាណាចក្រកម្ពុជា

ប្រព័ន្ធសារពើពន្ធបច្ចុប្បន្នរបស់ព្រះរាជាណាចក្រកម្ពុជា បានដាក់ឱ្យប្រើប្រាស់អស់រយៈពីរទសវត្សរ៍មកហើយ និងនៅតែជាផ្នែកមួយនៃច្បាប់ដែលមានការអភិវឌ្ឍជាបន្តបន្ទាប់ ហើយបាននឹងកំពុងដំណើរការយ៉ាងល្អប្រសើរ។ ប្រព័ន្ធច្បាប់សារពើពន្ធ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៧ ហើយត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ២០០៣។ ច្បាប់ស្តីពីសារពើពន្ធកម្ពុជាបច្ចុប្បន្ន បានអនុលោមយ៉ាងទូលំទូលាយទៅតាមកម្រិតស្តង់ដារអន្តរជាតិ។

ប្រវត្តិសារពើពន្ធក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) អាចបែងចែកទៅជា ៣តំណាក់កាល។ តំណាក់កាលទី១ ចាប់ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩៣ ពឹងផ្អែកលើរបបមៅការសុទ្ធ។ តំណាក់កាលទី២ ចាប់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៧ ជាអំឡុងពេលដែលរបបពិតត្រូវអនុវត្តបណ្តើរៗ ហើយសេដ្ឋកិច្ចកម្ពុជាបើកទទួលវិនិយោគឯកជន ដែលក្នុងនោះមានទាំងរបបមៅការ និងរបបពិតដែលបានប្រតិបត្តិការព្រមគ្នា និងតំណាក់កាលទី៣ ចាប់ពីឆ្នាំ១៩៩៧ មកទល់បច្ចុប្បន្ន ដែលចាប់ផ្តើមពីការចែងច្បាប់ស្តីពីសារពើពន្ធ ដែលរបបមៅការត្រូវការបំបាត់ចោលម្តងបន្តិចៗ។[1]

ប្រព័ន្ធពន្ធដារ កំពុងតែអភិវឌ្ឍន៍ដើម្បីឲ្យស្របទៅតាមតម្រូវការប្រទេស ដែលមានការរីកចម្រើនយ៉ាងឆាប់រហ័ស ដោយពង្រឹងនូវមូលដ្ឋានគិតពន្ធ និងពង្រឹងនូវការគោរពច្បាប់សារពើពន្ធ។ វាបានចាប់ផ្តើមដំណើរការយឺតៗ ទៅរកប្រព័ន្ធពន្ធដារសេរី មានន័យថា ពន្ធដារត្រូវបានអនុវត្តន៍ស្មើៗគ្នាទៅលើអ្នកជាប់ពន្ធទាំងអស់។

## ១.២. ដើមកំណើតនៃអគ្គនាយកពន្ធដារ និងរដ្ឋបាលពន្ធដារ

### ១.២.១. ការបង្កើតអគ្គនាយកដ្ឋានពន្ធដារ

នាយកដ្ឋានពន្ធដារនៅកម្ពុជាបានបង្កើតឡើងនៅឆ្នាំ១៩៨២ ក្រោយមកបានតម្លើងទៅជាអគ្គនាយកដ្ឋានពន្ធដារ ដោយអនុក្រឹត្យលេខ១៣៤ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ នៃរាជរដ្ឋាភិបាលកម្ពុជា។ អគ្គនាយកដ្ឋានពន្ធដារកម្ពុជាគ្រប់គ្រងដោយអគ្គនាយក១រូប អគ្គនាយករងចំនួន៦រូប និងអគ្គនាយិការង១រូប។ អគ្គនាយកដ្ឋានពន្ធដារនៅកម្ពុជា បានបែងចែកជាពីរផ្នែក គឺ អគ្គនាយកដ្ឋានពន្ធដារ និងសាខាពន្ធដារ។ នៅក្នុងអគ្គនាយកដ្ឋានពន្ធដារមាន ៩ នាយកដ្ឋាន ១ សាលាជាតិពន្ធដារ និង ១ ទីចាត់ការពន្ធដាររាជធានីភ្នំពេញ។ សាខាពន្ធដារចែកចេញជា សាខាពន្ធដារខណ្ឌ ដែលមាន

[1] VDB Loi Cambodia, Cambodia Tax (2014) 16

៩សាខាពន្ធដារខណ្ឌនៅក្នុងរាជធានីភ្នំពេញ និង២៤សាខាពន្ធដារនៅគ្រប់ខេត្ត រួមមានការិយាល័យពន្ធដារសរុបទាំងអស់ ១៣៨ ការិយាល័យ។[2]

### ១.២.២. រចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធដារ




### ១.២.៣. បេសកកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មធ្វើឱ្យសម្រេចការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារតាមរយៈ៖

- ការផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មាន អប់រំ ពន្យល់ ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវ តាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ការអនុវត្តកម្មវិធីចាប់បង្ខំ ដោយការធ្វើសវនកម្ម ការអនុវត្តវិធានការតឹងរឹង និងការអនុវត្តទោសទណ្ឌតាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារ ចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានា ស្តីពីពន្ធដារ
- ការប្រមូលចំណូលពន្ធ តាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ

[2] http://tax.gov.kh/aboutus.php

- ការផ្តល់សេវា និងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឱ្យច្បាប់នានាស្តីពីពន្ធដារ ត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ
- ការអនុវត្តកម្មវិធីចាប់បង្ខំ ប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ ព្រមទាំងស្មើភាពគ្នា ចំពោះអ្នកជាប់ពន្ធដែលមិនគោរពច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ
- ការអនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានា ស្តីពីពន្ធដារ ដើម្បីបង្កើនការជឿទុកចិត្តចំពោះរដ្ឋបាលសារពើពន្ធ
- ការបន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធ ក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួន ធ្វើឱ្យមានភាពសាមញ្ញចំពោះតម្រូវការផ្សេងៗ និងបន្ថយការចំណាយរបស់អ្នកជាប់ពន្ធ
- ការបង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីអាចបំពេញការងារឱ្យមានប្រសិទ្ធភាព
- ការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង តាមរយៈគោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារដែលមានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន។

### ១.២.៤. តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចជាអាទិ៍ដូចតទៅ៖

- រៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាននានាស្តីពីពន្ធដារ កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការ ដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការអង្កេត និងផ្តុំព័ត៌មាន
- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តការងារសវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុក ដែលបានល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ

- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ

## ១.៣. ទ្រឹស្តីទូទៅនៃពន្ធដារ

**ពន្ធដារ** គឺជាកាតព្វកិច្ចដែលខានមិនបានរបស់ប្រជាពលរដ្ឋដែលត្រូវតែគោរពតាម ដោយត្រូវបង់ជាប្រាក់នូវចំនួនកំណត់មួយដោយខានមិនបានដល់រដ្ឋ ហើយពន្ធដារគឺមានលក្ខណៈឯកតោភាគី។[3] ប្រជាពលរដ្ឋមានកាតព្វកិច្ចបង់ពន្ធនេះគ្រប់ៗគ្នាដោយមិនប្រកាន់ ឋានៈ វណ្ណៈ មាន ឬក្រឡើយ។ ការប្រមូលពន្ធនេះ គឺដើម្បីឱ្យប្រជាពលរដ្ឋរួមចំណែកក្នុងការកសាងប្រទេសជាតិ ព្រោះថវិកាដែលប្រមូលបានពីវិស័យពន្ធដារនេះ ត្រូវបានរដ្ឋយកទៅប្រើប្រាស់នៅក្នុងវិស័យសាធារណៈ អភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ សាងសង់ ផ្លូវ សាលារៀន មន្ទីរពេទ្យ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដើម្បីឱ្យប្រជាពលរដ្ឋនៅតាមតំបន់ទូទាំងប្រទេសប្រើប្រាស់ដោយយកថ្លៃតិចតួច ឬមិនយកកម្រៃតែម្តង។

ក្រៅពីនេះ ការយកពន្ធក៏ធ្វើឱ្យប្រជាពលរដ្ឋមានការងារធ្វើច្រើនផងដែរ ព្រោះការអនុវត្តគោលការណ៍លើកលែងពន្ធ បានទាក់ទាញអ្នកវិនិយោគឱ្យមកបោះទុនរកស៊ីនៅប្រទេសយើងកាន់តែច្រើនឡើង។ កាន់តែពិសេសជាងនេះទៅទៀត វាក៏បានជួយផ្តល់ឱ្យប្រជាពលរដ្ឋដោយប្រយោលនូវផលប្រយោជន៍មួយចំនួនផ្សេងទៀត ឧទាហរណ៍ដូចជា ការកំណត់យកពន្ធខ្ពស់លើបារីមានផលវិជ្ជមានដល់អ្នកជក់បារី ដែលអាចកាត់បន្ថយការជក់បារីនេះទៅតាមហ្នឹងផងដែរ។

### ១.៣.១. ពន្ធផ្ទាល់ និងពន្ធប្រយោល

ប្រទេសជាច្រើនទូទាំងពិភពលោក បានជ្រើសរើសយកប្រព័ន្ធ២មកអនុវត្តន៍គឺ ពន្ធផ្ទាល់ ឬហៅថាវិធីសាស្ត្រផ្ទាល់ និងពន្ធប្រយោល ឬវិធីសាស្ត្រប្រយោល។[4]

***១. __ពន្ធផ្ទាល់__*** គឺជាប្រភេទ ពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់បៀវត្ស ពន្ធលើអត្ថប្រយោជន៍បន្ថែម ពន្ធលើប្រាក់ចំណេញ ដែលរូបវន្តបុគ្គល សាជីវកម្ម ឬសហគ្រាសទទួលបាន ហើយពួកគេត្រូវទៅបង់ពន្ធដោយខ្លួនឯងតែម្តង។[5]

***២. __ពន្ធប្រយោល__*** គឺជាប្រភេទពន្ធដែលកំណត់លើទំនិញ ឬសេវា ដែលត្រូវបង់ដោយអ្នកប្រើប្រាស់ទំនិញ ឬសេវាទាំងនោះទៅឱ្យរដ្ឋ តាមរយៈអន្តរការី ដែលមានជាអាទិ៍ អ្នកផ្គត់ផ្គង់ ឬហៅថាអ្នកលក់ ឬពន្ធដែលប្រមូលពីអ្នកជាប់ពន្ធ ប៉ុន្តែបង់ដោយតតិយជន ដែលមានដូចជា ពន្ធលើការលក់អាករលើតម្លៃបន្ថែម អាករពិសេសជាដើម។

---

[3] ទេព សុខ, *នីតិថវិកា និងពន្ធដារ* (២០១៨), ៦១។

[4] ថង សុខុម, *សារពើពន្ធព្រះរាជាណាចក្រកម្ពុជា* (២០១៤), ៥៤។

[5] ថង សុខុម, *សារពើពន្ធព្រះរាជាណាចក្រកម្ពុជា* (២០១៤), ៥៤។

### ១.៣.២. ការបង្វៀងពន្ធ និងការគេចវេសពន្ធ

អ្នកជាប់ពន្ធតែងរកវិធីផ្សេងៗដើម្បីកាត់បន្ថយការបង់ពន្ធ ទោះបីជាវាត្រូវបានធ្វើឱ្យមើលទៅស្របច្បាប់ក៏ដោយ ក៏វានៅតែផ្ទុយពីស្មារតីច្បាប់ដដែល។ ហើយសកម្មភាពនេះត្រូវបានគេហៅថា **អប្បដិបត្តិ**។ ការគេចវេសពន្ធនេះត្រូវបានបែងចែកជាពីរគឺ ការគេចវេសពន្ធដោយស្របច្បាប់ និងការគេចវេសពន្ធដោយមិនស្របតាមច្បាប់ដែលបានកំណត់ អាស្រ័យលើការប្រព្រឹត្តិខុសពីច្បាប់សារពើពន្ធយ៉ាងណាខ្លះ និងការមិនសហប្រតិបត្តិការឆ្ពោះទៅកាន់ការបញ្ចូលគ្នាទាំងពីរ ដែលវាស្ថិតនៅក្នុងមនោភាពនៃអប្បដិបត្តិ។

*ការបង្វៀងពន្ធស្របច្បាប់ ដែលសហសគ្រាសពាណិជ្ជកម្មធ្វើ ដើម្បីកាត់បន្ថយចំនួននៃប្រាក់បង់ពន្ធ និងចំណេញពេលវេលាក្នុងការបង់ពន្ធ។ អ្នកជាប់ពន្ធជាច្រើនរិះរកកំហិតបន្ទុកពន្ធ ទៅតាមលទ្ធភាពដែលអាចធ្វើទៅបានតាមផ្លូវច្បាប់[6]។ ក្រុមហ៊ុនតែងតែជ្រើសរើសយក ថ្ងៃចុងក្រោយនៃកាលបរិច្ឆេទបង់ពន្ធ ដែលច្បាប់សារពើពន្ធបានកំណត់។* ទោះជាយ៉ាងណាក៏ដោយ តើការបង្វៀងពន្ធ គឺជាកិច្ចការត្រឹមត្រូវដែលត្រូវធ្វើដែរឬទេ?

ឧទាហរណ៍៖ ច្បាប់សារពើពន្ធ កំណត់ឱ្យបង់ពន្ធពីថ្ងៃទី០១ ដល់ថ្ងៃទី២០ នៃខែបន្ទាប់ រាប់ចាប់ពីថ្ងៃក្រុមហ៊ុនចាប់ប្រត្តិបត្តិការ នោះអ្នកបង់ពន្ធនឹងជ្រើសរើសបង់ពន្ធនៅថ្ងៃទី២០ ជាថ្ងៃចុងក្រោយ។

*ការគេចពន្ធ គឺជាអំពើខុសច្បាប់ដោយចេតនា ព្រោះមានការគិតទុកជាមុន និងច្រើនដងទៅលើអ្វីដែលមានចែងនៅក្នុងច្បាប់ស្តីពីសារពើពន្ធ ធ្វើយ៉ាងណាកាត់បន្ថយប្រាក់បង់ពន្ធឱ្យមានចំនួនកាន់តែតិចទៅៗ[7]។ បន្ថែមពីនេះ ការធ្វេសប្រហែសដែលមានលក្ខណៈធ្ងន់ធ្ងរ ក៏ត្រូវចាត់ទុកថាជាការគេចពន្ធផងដែរ។*

ការគេចពន្ធត្រូវបានចាត់ទុកថាជាបទល្មើសចេតនាបានរៀបចំទុកជាមុន។ ប្រសិនបើកើតឡើងដោយការធ្វេសប្រហែសធ្ងន់ធ្ងរពីរលើកដាច់ពីគ្នា ក្នុងរយៈពេលបីឆ្នាំប្រតិទិន ឬបីលើក ឬច្រើនពីហ្នឹងដាច់ពីគ្នា ក្នុងរយៈពេលណាមួយក៏ដោយ គឺត្រូវចាត់ទុកថាជាបទល្មើសចេតនាដែរ ហើយអាចត្រូវផ្តន្ទាទោសពី ដប់លាន (១០.០០០.០០០)រៀល ទៅ ម្ភៃលាន (២០.០០០.០០០)រៀល ឬអាចជាប់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ឬទោសទាំងពីរតែម្តង។[8]

[6] ថង សុខុម, *សារពើពន្ធព្រះរាជាណាចក្រកម្ពុជា* (២០១៩), ៥៥។

[7] ថង សុខុម, *សារពើពន្ធព្រះរាជាណាចក្រកម្ពុជា* (២០១៩), ៥៤។

[8] ច្បាប់សារពើពន្ធ លេខនស/រកម/០៣០៣/០១០, ៣១ មីនា ២០០៣, មាត្រា១២៧-១៣៥។

### ១.៣.៣. របបពន្ធដារ ប្រភេទពន្ធដារ និងការចុះបញ្ជី

**ក. របបពន្ធដារ**

របបពន្ធដារនៅប្រទេសកម្ពុជាមានពីរប្រភេទដូចមានរៀបរាប់ដូចខាងក្រោម៖

**ក.១. <u>ពន្ធតាមរបបពិត</u>** គឺជាប្រព័ន្ធពន្ធស្វ័យប្រកាស (ដោយខ្លួនឯង) ជាប្រព័ន្ធគ្រប់គ្រងពន្ធមួយប្រភេទដែលរាជរដ្ឋាភិបាលកម្ពុជាប្រើចំពោះសហគ្រាសខ្នាតធំ និងមធ្យមគ្រប់ប្រភេទមានដូចជាសហគ្រាសនាំចេញនាំចូល សហគ្រាសវិនិយោគដែលមានលក្ខណៈគតិយុត្ត ហើយសហគ្រាសទាំងនោះធ្វើការប្រកាសពន្ធដោយខ្លួនឯងដែលហៅថា **ស្វ័យប្រកាស**។[9] សហគ្រាសមួយស្ថិតនៅក្នុងរបបស្វ័យប្រកាសលុះត្រាតែ៖

**ក.១.១.** ផ្អែកលើទ្រង់ទ្រាយសហគ្រាសជាគតិយុត្ត មានន័យថា សហគ្រាសនេះមិនមែនជាសហគ្រាសឯកបុគ្គល ហើយបង់ពន្ធក្រោមរបបពិតដោយមិនចាំបាច់ផ្អែកលើសកម្មភាពអាជីវកម្ម និងកម្រិតផលរបរឡើយ។ សហគ្រាសគតិយុត្តមានដូចជា ក្រុមហ៊ុនឯកជន សហគមន៍ ឬអង្គការឯកជន សហគ្រាសរដ្ឋ ក្រុមហ៊ុនចម្រុះរដ្ឋ មានសកម្មភាពអាជីវកម្មដើម្បីស្វែងរកប្រាក់ចំណេញ ឬបានផលចំណេញពីទ្រព្យសម្បត្តិរបស់ពួកគេ។[10]

**ក.១.២.** ផ្អែកលើផលរបរសម្រាប់សហគ្រាសឯកបុគ្គល ដែលសកម្មភាពអាជីវកម្មជារបស់ខ្លួនឯង និងបានចុះបញ្ជីនៅការិយាល័យរបបពិត។[11]

**ក.១.៣.** ផ្អែកលើសកម្មភាពអាជីវកម្មជាសហគ្រាសឯកបុគ្គល ជាសហគ្រាសអាហារ័ណនិហារ័ណ ឬអាចជាគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។[12]

**ក.២. <u>ពន្ធតាមរបបម៉ៅការ</u>** ជាប្រព័ន្ធវាយតម្លៃផ្លូវការ ដែលកំណត់យកចំពោះសហគ្រាសឯកបុគ្គល ដែលមានសកម្មភាពជំនួញគ្រប់ប្រភេទ មានកម្រិតផលរបរទាប និងរាល់សហគ្រាសដែលមិនមានលក្ខណៈដូចលក្ខខណ្ឌដែលបានកំណត់ចូលជារបបពិតខាងលើ ហើយរបបពន្ធនេះអាចអនុវត្តន៍បាននៅគ្រប់ទីកន្លែងនៃព្រះរាជាណាចក្រកម្ពុជា។

**ខ. ប្រភេទពន្ធ**

នៅព្រះរាជាណាចក្រកម្ពុជាមានពន្ធជាច្រើនប្រភេទដូចជា ពន្ធលើប្រាក់ចំណេញ ពន្ធកាត់ទុក ពន្ធអប្បបរមា **ពន្ធលើប្រាក់បៀវត្ស** អាករលើតម្លៃបន្ថែម ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ពន្ធគយ និងពន្ធផ្សេងៗ (ពន្ធលើអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

[9] ថង សុខុម, *សារពើពន្ធព្រះរាជាណាចក្រកម្ពុជា* (២០១៤), ៥០។
[10] ថង សុខុម, *សារពើពន្ធព្រះរាជាណាចក្រកម្ពុជា* (២០១៤), ៥០។
[11] ថង សុខុម, *សារពើពន្ធព្រះរាជាណាចក្រកម្ពុជា* (២០១៤), ៥០។
[12] ថង សុខុម, *សារពើពន្ធព្រះរាជាណាចក្រកម្ពុជា* (២០១៤), ៥០។

ពន្ធលើដីធ្លីមិនប្រើប្រាស់ ពន្ធតែមប្រៃសណីយ៍ ពន្ធប៉ាតង់)។ល។ ចំណែកឯអាករវិញមានដូចជា អាករលើផលរបរ អាករលើការប្រើប្រាស់ អាករលើទំនិញនិងសេវា អាករពិសេស និងអាករលើតម្លៃបន្ថែម អាករលើការស្នាក់នៅ ជាដើម។

**គ. ការចុះបញ្ជីពន្ធដារ**

ស្របតាមមាត្រា១០១ នៃច្បាប់សារពើពន្ធ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៥៩៦សហវ[13] ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ កំណត់នូវវិធាន និងនីតិវិធីនៃការចុះបញ្ជីពន្ធដារ ក្នុងគោលដៅពង្រឹង និងបង្កើនប្រសិទ្ធិភាពនៃការចុះបញ្ជីពន្ធដារ ដើម្បីគ្រប់គ្រងឱ្យបានកាន់តែប្រសើរនូវទិន្នន័យអ្នកជាប់ពន្ធ និងគាំទ្រដល់ការផ្តល់សេវាដល់អ្នកជាប់ពន្ធឱ្យបានកាន់តែប្រសើរ ព្រមទាំងគាំទ្រដល់ការគ្រប់គ្រងការដាក់លិខិតប្រកាស ការធ្វើសវនកម្ម និងការប្រមូលបំណុលពន្ធឱ្យកាន់តែមានតម្លាភាព និងប្រសិទ្ធិភាព។ ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធទាំងឡាយ ដែលធ្វើសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងប្រកាសលេខ ១០១ សហវ បានកំណត់អំពីនិយមន័យ និងឯកសារតម្រូវផ្សេងៗដើម្បី ធ្វើការចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារដូចខាងក្រោម៖

**ប្រការ ៤.- និយមន័យ** សម្រាប់គោលដៅនៃប្រកាសនេះ៖

- ពាក្យ **ការចុះបញ្ជីពន្ធដារ** សំដៅដល់ការចុះបញ្ជី អ្នកជាប់ពន្ធទាំងឡាយដែលធ្វើសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ពាក្យ **អ្នកជាប់ពន្ធ** សំដៅដល់បុគ្គលទាំងឡាយដែលមានកាតព្វកិច្ចត្រូវបង់ពន្ធ។
- ពាក្យ **សកម្មភាពសេដ្ឋកិច្ច** សំដៅដល់សកម្មភាពរបស់បុគ្គលដែលធ្វើជានិច្ចកាល ជាប់បន្ត ឬមួយដងមួយគ្រា ដើម្បី ឬមិនរកចំណេញ ក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញ ឬសេវាឱ្យបុគ្គលដទៃ ក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។
- ពាក្យ **អាជីវកម្ម** សំដៅដល់សកម្មភាពរបស់បុគ្គលដែលមានគោលដៅទាញយកប្រាក់ចំណូលពីការផលិត និងលក់ទំនិញ ការផ្គត់ផ្គង់សេវា ភតិសន្យា ការជួល ឬលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងទៀត។

ប្រការ ៥.- **កាតព្វកិច្ចចុះបញ្ជីពន្ធដារ**

បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ។

[13] សូមមើលឧបសម្ព័ន្ធ២

ប្រការ ៦.- **ការស្នើសុំចុះបញ្ជីពន្ធដារ**

បុគ្គលទាំងឡាយ ដែលមានកាតព្វកិច្ចចុះបញ្ជីពន្ធដារ ដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ ត្រូវធ្វើការស្នើសុំចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬតាមប្រព័ន្ធអេឡិកត្រូនិច (E-registration) ដោយត្រូវបំពេញទម្រង់ចុះបញ្ជីដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ និងតម្រូវឱ្យភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ ដូចមានចែងក្នុងប្រការខាងក្រោម។

បុគ្គលទាំងឡាយ ដែលមានកាតព្វកិច្ចចុះបញ្ជីពន្ធដារ ត្រូវរៀបចំឯកសារដូចបានរៀបរាប់ខាងលើទៅតាមប្រភេទទម្រង់ ឬសកម្មភាពអាជីវកម្មរបស់ខ្លួន ដើម្បីទទួលបានវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ[14] (អាករលើតម្លៃបន្ថែម-អតប) ប័ណ្ណពន្ធប៉ាតង់ប្រចាំឆ្នាំ[15] និងកាតសម្គាល់លេខអត្តសញ្ញាណអាករលើតម្លៃបន្ថែម (VAT TIN Card)។[16]

**សម្គាល់៖** សម្រាប់ វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) និងប័ណ្ណពន្ធប៉ាតង់ប្រចាំឆ្នាំ ត្រូវដាក់ស៊ុមហើយព្យួរ ឬតាំងនៅកន្លែងដែលអាចងាយមើលឃើញ នៅក្នុងក្រុមហ៊ុន ឬសហគ្រាសរបស់ខ្លួន។

ប្រការ ៧.- **ឯកសារ និងការតម្រូវ សម្រាប់ការចុះបញ្ជីពន្ធដារ**

**១ - អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ**

**ក. ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ**

ប្រធាន ឬអ្នកតំណាងរបស់ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយត្រូវបានតម្រូវឱ្យបំពេញព័ត៌មាន ក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់ជាមួយនូវ ច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារទាំងឡាយ ដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ចដូចខាងក្រោម៖

- **ឯកសារចុះបញ្ជីចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ**
  - លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នពាក់ព័ន្ធ ឬ/និង

[14] សូមមើលឧបសម្ព័ន្ធ២

[15] សូមមើលឧបសម្ព័ន្ធ២

[16] សូមមើលឧបសម្ព័ន្ធ២

- លក្ខន្តិកៈ ឬអនុសារណៈយោគយល់គ្នា ជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច

- **ឯកសារបញ្ជាក់អត្តសញ្ញាណ ប្រធាន ឬអ្នកតំណាង**
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
  - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល០៣ខែ ដែលមានទំហំ ៣៥x៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយព៌ណសចំនួន០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះ និង ចុះហត្ថលេខាម្ចាស់រូបថតនៅខាងខ្នង

- **ឯកសារបញ្ជាក់ទីតាំង**
  - ប័ណ្ណកម្មសិទ្ធិទីតាំង ឬកិច្ចសន្យាជួលទីតាំងការិយាល័យ
  - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ (បើមាន)

**ខ. សហគ្រាសឯកបុគ្គល និងសហគ្រាសនីតិបុគ្គល**

ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាស ត្រូវបានតម្រូវឱ្យមកថតរូប ស្កេនម្រាមដៃដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ។

ករណីប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាស ដែលមានសញ្ជាតិបរទេស ហើយស្នាក់នៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលមិនអាចអញ្ជើញមកថតរូប ស្កេនម្រាមដៃ ត្រូវធ្វើលិខិតផ្ទេរសិទ្ធិឱ្យអ្នកតំណាងណាមួយនៅក្នុងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដែលបានទទួលស្គាល់ដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ មកថតរូប និងស្កេនម្រាមដៃជំនួសបាន និងត្រូវសហការផ្តល់នូវឯកសារពាក់ព័ន្ធដែលមានចែងក្នុងប្រការនេះ ដើម្បីទទួលបាននូវប័ណ្ណពន្ធប៉ាតង់ ឬ/និង វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬ/និង ប័ណ្ណសម្គាល់ចុះបញ្ជីពន្ធដារ។

ចំពោះប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាសមានសញ្ជាតិបរទេស តែស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ប្រធានក្រុមប្រឹក្សាភិបាល ម្ចាស់សហគ្រាសមានសញ្ជាតិខ្មែរ ត្រូវបានតម្រូវឱ្យមកថតរូប និងស្កេនម្រាមដៃ និងត្រូវសហការផ្តល់នូវឯកសារពាក់ព័ន្ធ ដែលចែងក្នុងប្រការនេះ ដើម្បីទទួលបាននូវ ប័ណ្ណប៉ាតង់ ឬ/និង វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬ/និង ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ។

ក្នុងករណីចាំបាច់ អ្នកជាប់ពន្ធអាចស្នើសុំឱ្យរដ្ឋបាលសារពើពន្ធផ្តល់សេវាទៅថតរូប និងស្កេនម្រាមដៃ ដល់ទីតាំងសហគ្រាស ឬទីកន្លែងសមស្របណាមួយ។

ប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធិករ ឬម្ចាស់ភាគហ៊ុន បណ្ណាធិការ ឬអ្នកតំណាងត្រូវបានតម្រូវឱ្យបំពេញព័ត៌មានក្នុងទម្រង់ ដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវ ច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារទាំងឡាយ ដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ចដូចខាងក្រោមៈ

- **ឯកសារចុះបញ្ជីចេញដោយ ក្រសួង ឬស្ថាប័នពាក់ព័ន្ធ**
  - លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ឬ/នឹង
  - លិខិតទទួលចុះបញ្ជីនូវការបង្កើតសាខា ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ (សម្រាប់ការចុះបញ្ជីសាខា) ឬ/និង
  - លក្ខន្តិកៈក្រុមហ៊ុនសម្រាប់នីតិបុគ្គល ឬ/និង
  - ព័ត៌មានគណនីធនាគាររបស់សហគ្រាស ដូចជា លិខិតបញ្ជាក់គណនីធនាគារ របាយការណ៍ធនាគារ ឬសៀវភៅគណនី ដែលចេញដោយធនាគារ។
- **ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធករ ឬម្ចាស់ភាគហ៊ុន បណ្ណាធិការ អ្នកតំណាង និងអ្នកគ្រប់គ្រងសាខា**
  - អត្តសញ្ញាប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
  - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ខែ ដែលមានទំហំ ៣៥×៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយព័ណ៌ស ចំនួន ០២សន្លឹក ដែលមានបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធានក្រុមប្រឹក្សាភិបាល។
- **ឯកសារបញ្ជាក់ទីតាំងទីចាត់ការសហគ្រាស អាជីវកម្មគោលដើម សាខាសហគ្រាស និងឃ្លាំង**
  - ប័ណ្ណកម្មសិទ្ធកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
  - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ
- **ឯកសារផ្សេងៗ**
  - វិញ្ញាបនបត្រចុះបញ្ជីរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ឬគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត (សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់)
  - អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច (បើមាន)។

**គ. សមាគម និងអង្គការនានា**

ប្រធានសមាគម ប្រធានអង្គការនានាដែលធ្វើអាជីវកម្ម ឬអ្នកតំណាងណាមួយដែលបានទទួលស្គាល់ដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ត្រូវបានតម្រូវឱ្យមកថតរូប និងស្កេនម្រាមដៃដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ និងតម្រូវឱ្យបំពេញព័ត៌មានក្នុងទម្រង់ ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធដោយភ្ជាប់មកជាមួយនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារទាំងឡាយដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ចដូចខាងក្រោមៈ

- **ឯកសារចុះបញ្ជីចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ**
  - លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នពាក់ព័ន្ធ ឬ/និង
  - លក្ខន្តិកៈ ឬអនុស្សរណៈយោគយល់គ្នាជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច
  - ព័ត៌មានគណនីធនាគារ ដូចជាលិខិតបញ្ជាក់គណនីធនាគារ របាយការណ៍ធនាគារ ឬសៀវភៅគណនី ដែលចេញដោយធនាគារ (សម្រាប់តែសមាគម ឬអង្គការនានាដែលធ្វើអាជីវកម្ម)
- **ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ប្រធាន ឬអ្នកតំណាង**
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
  - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ខែ ដែលមានទំហំ ៣៥×៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយព័ណ៌ស ចំនួន ០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះម្ចាស់រូបថត និងមានចុះហត្ថលេខាទទួលខុសត្រូវដោយប្រធាន ឬអ្នកតំណាងសមាគម ឬអង្គការនានា។
- **ឯកសារបញ្ជាក់ទីតាំង**
  - ប័ណ្ណកម្មសិទ្ធកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងការិយាល័យ
  - លិខិបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ (បើមាន)

**២ - អ្នកជាប់ពន្ធដទៃទៀត**

អ្នកជាប់ពន្ធតូច ឬបុគ្គលទាំងឡាយណា ដែលមានសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០ លានរៀល ឬមានផលរបរក្នុងរយៈពេល ០៣ខែណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តក្រោម៦០លានរៀល ត្រូវបានតម្រូវឱ្យបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ និងភ្ជាប់មកជាមួយនូវ ឯកសារច្បាប់ដើម ឬច្បាប់ថតចម្លងនៃឯកសារទាំងឡាយ ដែលមានបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច

ដូចខាងក្រោម៖

- **ឯកសារចុះបញ្ជីចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ**
  - លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជីចេញដោយក្រសួង ស្ថាប័នពាក់ព័ន្ធ
- **ឯកសារបញ្ជាក់អត្តសញ្ញាណរបស់កម្មសិទ្ធករ**
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
  - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ខែ ដែលមានទំហំ ៣៥×៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយព័ណ៌ស ចំនួន០២ សន្លឹក ដែលមានការបញ្ជាក់ឈ្មោះ និងចុះហត្ថលេខាទទួលខុសត្រូវដោយម្ចាស់រូបថត។
- **ឯកសារបញ្ជាក់ទីតាំងអាជីវកម្មដ្ឋាន**
  - ប័ណ្ណកម្មសិទ្ធកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
  - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ (បើមាន)

**៣ - ការប្រើប្រាស់អាសយដ្ឋានក្នុងការចុះបញ្ជីពន្ធដារ និងតម្រូវការឯកសារភ្ជាប់បន្ថែម**

សម្រាប់គោលដៅនៃការចុះបញ្ជីពន្ធដារ អាសយដ្ឋាននៃទីតាំងរបស់ស្ថាប័ន ឬទីចាត់ការសហគ្រាស ឬសាខាសហគ្រាស ឬសមាគម ឬអង្គការនានា ដែលគ្មានអគារ (ដីទំនេរ) ឬមានសំណង់ទើបតែចាប់ផ្តើមសាងសង់ មិនអាចប្រើប្រាស់បាន មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ជាអាសយដ្ឋានសម្រាប់ការចុះបញ្ជីពន្ធដារបានឡើយ វៀរលែងតែមានការយល់ព្រមពីអគ្គនាយដ្ឋានពន្ធដារ។

អ្នកជាប់ពន្ធដែលមានអាសយដ្ឋានស្នាក់នៅខុសពីអាសយដ្ឋាន នៅក្នុងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន អ្នកជាប់ពន្ធត្រូវភ្ជាប់បន្ថែមនូវសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

ប្រការ៨.- **ការស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់សហគ្រាសដែលបានចុះបញ្ជី**

១. អនុលោមតាមមាត្រា១០១ នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធបានចុះបញ្ជីពន្ធដាររួចហើយ ត្រូវបានតម្រូវឱ្យធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ក្នុងករណីដែលព័ត៌មានណាមួយក្នុងចំណោមព័ត៌មានខាងក្រោមនេះត្រូវបានផ្លាស់ប្តូរ៖

ក. នាមករណ៍សហគ្រាស

ខ. អាសយដ្ឋានទីចាត់ការ កន្លែងប្រកបអាជីវកម្មជាគោលដើម ឬសាខា ឃ្លាំងរបស់សហគ្រាស

គ. អាសយដ្ឋានម្ចាស់សហគ្រាស អភិបាល ឬបណ្ណាធិការ របស់សហគ្រាស

ឃ. ទ្រង់ទ្រាយគតិយុត្តរបស់សហគ្រាស

ង. កម្មវត្ថុអាជីវកម្ម

ច. ការផ្ទេរ ការបញ្ឈប់អាជីវកម្ម

ឆ. សមាសភាពអ្នកគ្រប់គ្រង

ជ. អ្នកទទួលបន្ទុកកិច្ចការពន្ធ

ឈ. លេខគណនីធនាគារសហគ្រាស

ញ. លេខទំនាក់ទំង (លេខទូរស័ព្ទ សារអេឡិចត្រូនិក)។

២. អ្នកជាប់ពន្ធត្រូវស្នើសុំមករដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីមានការផ្លាស់ប្តូរព័ត៌មានដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការនេះ ដើម្បីធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដារឡើងវិញ ដោយត្រូវគោរពតាមលក្ខខណ្ឌ និងភ្ជាប់មកនូវ ច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារចុងក្រោយនៃឯកសារនានា ដែលបានតម្រូវក្នុងប្រការ៧ នៃប្រកាសនេះ។

៣. ចំពោះអ្នកជាប់ពន្ធដែលមានការផ្លាស់ប្តូរអាសយដ្ឋានទីចាត់ការសហគ្រាស ឬទ្រង់ទ្រាយគតិយុត្តរបស់សហគ្រាស ដែលនាំឱ្យមានការផ្លាស់ប្តូរពីការគ្រប់គ្រង របស់អង្គភាពពន្ធដារមួយទៅអង្គភាពពន្ធដារមួយទៀត ត្រូវធ្វើការស្នើសុំផ្លាស់ប្តូរអង្គភាពទៅតាមទម្រង់ ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ។

៤. ចំពោះអ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារមុនថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤ ប្រធានស្ថាប័នរដ្ឋ ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាស ប្រធានអង្គការមិនមែនរដ្ឋាភិបាល ត្រូវមកធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដារឡើងវិញ ដោយត្រូវគោរពតាមលក្ខខណ្ឌ និងភ្ជាប់មកនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារចុងក្រោយនៃឯកសារនានា ដែលបានតម្រូវក្នុងប្រការ៧នៃប្រកាសនេះ។

ប្រការ៩.- **កម្រៃសេវាចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស**

១. កម្រៃសេវាចុះបញ្ជីពន្ធដារមានដូចខាងក្រោមៈ

- **0 (សូន្យ) រៀល** សម្រាប់ស្ថាប័នរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បេសកកម្មទូតកុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ ដែលបានស្នើសុំ ដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌ ១ នៃប្រកា១៧ នៃប្រកាសនេះ

- **២០.០០០រៀល** សម្រាប់អ្នកជាប់ពន្ធតូច និងអ្នកជាប់ពន្ធដែលមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០លានរៀល ឬមានផលរបរក្នុងរយៈពេល ០៣ខែណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តក្រោម ៦០លានរៀល ដែលបានស្នើសុំ ដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការ៧ នៃប្រកាសនេះ
- **៤០០.០០០រៀល** សម្រាប់អ្នកជាប់ពន្ធមធ្យម អ្នកជាប់ពន្ធធំ សមាគម និងអង្គការនានា ដែលបានស្នើសុំដូចមានចែងក្នុងវាក្យខណ្ឌ ខ និងវាក្យខណ្ឌ គ នៃកថាខណ្ឌ១ នៃប្រការ៧ នៃប្រកាសនេះ។

២. កម្រៃសេវាធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ មានដូចខាងក្រោម៖

- **០ (សូន្យ) រៀល** សម្រាប់ស្ថាប័នរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បេសកកម្មទូតកុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ
- **១០.០០០រៀល** សម្រាប់អ្នកជាប់ពន្ធតូច ឬបុគ្គលទាំងឡាយណា ដែលមានសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០លានរៀល ឬមានផលរបរក្នុងរយៈពេល ០៣ខែ ណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តក្រោម ៦០លានរៀល
- **២០០.០០០រៀល** សម្រាប់អ្នកជាប់ពន្ធមធ្យម អ្នកជាប់ពន្ធធំ សមាគម អង្គការនានា។

៣. កម្រៃសេវាដូចមានចែងក្នុងកថាខណ្ឌ២ នៃប្រការ៩ នៃប្រកាសនេះ ត្រូវអនុវត្តន៍ផងដែរចំពោះអ្នកជាប់ពន្ធដែលមានការផ្លាស់ប្តូរព័ត៌មាននៅលើប័ណ្ណពន្ធប៉ាតង់ ឬវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬលិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ ឬស្នើសុំបោះពុម្ពឡើងវិញនូវ ប័ណ្ណពន្ធប៉ាតង់ ឬវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬលិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ។ ដោយឡែកការស្នើសុំបោះពុម្ពប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារឡើងវិញ អ្នកជាប់ពន្ធត្រូវបានតម្រូវឱ្យបង់កម្រៃសេវាចំនួន **៥.០០០រៀល**។

ប្រការ១០.- **ការបញ្ជាក់ការទទួលសំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារ**

រដ្ឋបាលសារពើពន្ធ ត្រូវចេញលិខិតបញ្ជាក់ការទទួលសំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារ ដោយបញ្ជាក់កាលបរិច្ឆេទទទួលសំណុំឯកសារ បន្ទាប់ពីបានពិនិត្យឃើញថា សំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារនោះត្រឹមត្រូវ និងគ្រប់គ្រាន់តាមការកំណត់ក្នុងប្រការ៧ នៃប្រកាសនេះ។

ប្រការ១១.- **រយៈពេលទទួលបានការចុះបញ្ជីពន្ធដារ ឬការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស**

១. អ្នកជាប់ពន្ធអាចទទួលបានសេចក្តីសម្រេចចុះបញ្ជីពន្ធដារ ឬការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសក្នុងរយៈពេល៖

- ០១ថ្ងៃ ទៅ០៧ថ្ងៃ នៃថ្ងៃធ្វើការ ចំពោះការចុះបញ្ជីតាមរយៈប្រព័ន្ធអេឡិចត្រូនិក
- ០៧ថ្ងៃ ទៅ១០ថ្ងៃ នៃថ្ងៃធ្វើការ ចំពោះការធ្វើការចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ។

២. ក្រោយពេលចុះបញ្ជីពន្ធដារ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសរួចរាល់ រដ្ឋបាលសារពើពន្ធត្រូវចុះដល់ទីតាំងផ្ទាល់របស់សហគ្រាស ដើម្បីថតរូបទីតាំង និងកត់ត្រានិន្នន័យរបស់ទីតាំងសហគ្រាស (GPS) ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រង់ទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ និងប្រគល់ឯកសារផ្លូវការដែលបានចេញដោយរដ្ឋបាលសារពើពន្ធ ដោយមានការចុះហត្ថលេខាទទួលត្រឹមត្រូវពីអ្នកជាប់ពន្ធ។

៣. ឯកសារផ្លូវការនៃការចុះបញ្ជីពន្ធដារ ឬការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដែលត្រូវប្រគល់-ទទួលមានដូចខាងក្រោម៖

ក. ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា គណបក្សនយោបាយ សមាគម អង្គការនានា ដែលមិនប្រកបអាជីវកម្ម៖

- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬ/និង
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ឬ/និង
- លិខិតជូនដំណឹងស្តីពីការដាក់លិខិតប្រកាសពន្ធ

ខ. សហគ្រាសឯកបុគ្គល សហគ្រាសនីតិបុគ្គល សមាគម និងអង្គការនានា ដែលប្រកបអាជីវកម្ម៖

- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬ/និង
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ឬ/និង
- ប័ណ្ណពន្ធប៉ាតង់ ឬ/និង
- លិខិតជូនដំណឹងស្តីពីការដាក់លិខិតប្រកាសពន្ធ

គ. អ្នកជាប់ពន្ធដែលមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០លានរៀល ឬមានផលរបរក្នុងរយៈពេល ០៣ខែណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តក្រោម ៦០លានរៀល៖

- លិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ ឬ/និង
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ

**ឃ. ការងារមិនបញ្ជីពន្ធដារប្រចាំខែ និងប្រចាំឆ្នាំ**

នៅរៀងរាល់ខែ និងរាល់ដំណាច់ឆ្នាំ អ្នកជាប់ពន្ធត្រូវរៀបចំបិទបញ្ជិកាគណនេយ្យរបស់ខ្លួន ហើយត្រូវរៀបចំបំពេញបែបបទប្រកាស និងបង់ជូនរដ្ឋបាលសារពើពន្ធទៅតាមសកម្មភាពអាជីវកម្មរបស់ខ្លួនឱ្យបានរួចរាល់យ៉ាងយូរត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ ដែលរួមមានដូចខាងក្រោម៖

**១. ពន្ធដែលត្រូវប្រកាស និងបង់ប្រចាំខែ៖**

- ពន្ធលើប្រាក់បៀវត្ស (Tax on Salary) និងអត្ថប្រយោជន៍បន្ថែម (Fringe Benefit Tax)
- ពន្ធកាត់ទុក (Withholding Tax)
- ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ (Prepayment on Profit Tax)
- អាករពិសេសលើទំនិញ និងសេវាមួយចំនួន (Specific Tax on certain merchandise and services)
- អាករស្នាក់នៅ (Accommodation Tax)
- អាករបំភ្លឺសាធារណៈ (Public Lighting Tax)
- អាករលើតម្លៃបន្ថែម (Value Added Tax) និង
- ពន្ធអាករដទៃទៀតដែលពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មរបស់ខ្លួន។

**២. ពន្ធដែលត្រូវប្រកាស និង បង់ប្រចាំឆ្នាំ៖**

- ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ (Annual Profit Tax Return)
- ពន្ធ ប៉ាតង់ (Patent Tax)
- ពន្ធលើអចលនទ្រព្យ (Property Tax)។

ប្រសិនបើអ្នកជាប់ពន្ធមិនបានបង់ពន្ធដារត្រឹមត្រូវតាមច្បាប់ អ្នកជាប់ពន្ធទាំងនោះនឹងជួបប្រទះនូវបញ្ហាមួយចំនួនដូចខាងក្រោម៖

- ការផាកពិន័យធ្ងន់ធ្ងរនៅពេលដែលសវនករពន្ធដារចុះធ្វើសវនកម្ម ដោយគិតរាប់ចាប់តាំងពីពេលដំណើរការដំបូងរហូតមក ដោយមិនអាចគេចផុតឡើយ
- ការមិនអាចអនុវត្តបាននូវស្តង់ដារគណនេយ្យកម្ពុជា ឬអន្តរជាតិ
- អាចប្រឈមរហូតដល់មានទោសតាមផ្លូវច្បាប់ និងករណីផ្សេងៗទៀត៕

# ជំពូកទី២

# ការអនុវត្ត

# ពន្ធលើប្រាក់បៀវត្ស

# ជំពូកទី២

# ការអនុវត្តពន្ធលើប្រាក់បៀវត្ស (ពបវ)

## ២.១. ការវិវត្តប្រភេទពន្ធលើប្រាក់បៀវត្សនៅកម្ពុជា

បទប្បញ្ញត្តិស្ដីពីពន្ធលើប្រាក់បៀវត្ស មានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១.នស.៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ត្រូវបានធ្វើវិសោធនកម្មដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋ។ ប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស ត្រូវបានដាក់ឱ្យអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ ពេលនោះកម្រិតអប្បបរិមាដែលត្រូវជាប់ពន្ធលើប្រាក់បៀវត្សគឺគិតចាប់ពី **៥០០.០០១រៀល** (ហាសិបម៉ឺនមួយរៀល) ឡើងទៅ។ ការអនុវត្តការប្រមូលពន្ធលើប្រាក់បៀវត្សក្នុងកម្រិតខាងលើបានបន្តអនុវត្តរហូតដល់ឆ្នាំ២០១៤។

ដោយសារកំណើនសេដ្ឋកិច្ច ក៏ដូចជាកម្រិតប្រាក់បៀវត្សមន្ត្រីរាជការ និងបុគ្គលិកក្រុមហ៊ុនចេះតែកើនឡើងជាលំដាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសេចក្តីណែនាំលេខ ០០២ សហវ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ ដោយអនុលោមតាមមាត្រា៤៧ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ អត្រាកំណើនតាមថ្នាក់ថ្មីសម្រាប់គិតពន្ធលើប្រាក់បៀវត្សគឺគិតចាប់ពី **៨០០.០០១រៀល** (ប៉ែតសិបម៉ឺនមួយរៀល) ឡើងទៅ។

នៅក្នុងឆ្នាំ២០១៧ អត្រាកំណើនតាមថ្នាក់ថ្មីសម្រាប់គិតពន្ធលើប្រាក់បៀវត្សត្រូវបានផ្លាស់ប្តូរជាថ្មីម្តងទៀត ដោយយោងតាមសេចក្តីណែនាំលេខ ០១៧សហវ-អពដ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ ដោយអនុលោមតាមមាត្រា៤៧ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ អត្រាកំណើនតាមថ្នាក់ថ្មីសម្រាប់គិតពន្ធលើប្រាក់បៀវត្សគឺគិតចាប់ពី **១.០០០.០០១រៀល** (មួយលានមួយរៀល) ឡើងទៅ។

ក្នុងគោលបំណងសម្រួលទុក្ខលំបាកដល់ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ គ្រូបង្រៀន គ្រូពេទ្យ ព្រមទាំងកម្មករ កម្មការនី និងបុគ្គលិកជាទូទៅ យោងតាមសេចក្តីណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ លេខ០០២ សហវ-អពដ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ ដោយអនុលោមតាមមាត្រា៤៧ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលត្រូវបានប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២១៧/

០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ចាប់ពី ខែមករា ឆ្នាំ ២០១៨នេះតទៅ គ្រប់សហគ្រាស ដែលជាអ្នកជាប់ពន្ធនិវាសនជន ស្ថាប័នរដ្ឋ អង្គការនានា ដែលមានកាតព្វកិច្ចកាត់ទុក និងបង់ពន្ធលើប្រាក់បៀវត្ស ត្រូវអនុវត្តអត្រាកំណើនតាមថ្នាក់ថ្មី ចំពោះប្រាក់បៀវត្សដែលបើកជូននិយោជិតចាប់ពីខែមករា ឆ្នាំ២០១៨ តរៀងទៅ ហើយត្រូវដាក់លិខិតប្រកាសបង់ពន្ធប្រចាំខែនីមួយៗ យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់។

ប្រាក់បៀវត្សត្រឹម១.២លានរៀលចុះក្រោម នឹងមិនមានកាតព្វកិច្ចបង់ពន្ធទេចាប់ពីឆ្នាំ២០១៨តទៅ ពោលគឺប្រាក់បៀវត្សប្រចាំខែចាប់ពី **១លានពីរសែន១រៀល** ទើបជាប់ពន្ធលើប្រាក់បៀវត្ស។

ប្រាក់បៀវត្សចាប់ពី ១លានពីរសែន១រៀល ឡើងទៅទើបជាប់ពន្ធ មានន័យថាមិនយក ១.២ លានរៀល មកបូកទាំងអស់នោះទេ។ ឧទាហរណ៍៖ ប្រាក់បៀវត្ស ១លាន ៤សែនរៀល គឺយកតែ ២ សែនរៀលប៉ុណ្ណោះ មកគិតជាប៉ុន្មានភាគរយដែលនឹងត្រូវបង់ជូនរដ្ឋបាលពន្ធដារ។

ដោយផ្អែកតាមស្ថានភាពគ្រួសារ អ្នកដែលមានបន្ទុកចិញ្ចឹមកូន ប្តី ឬប្រពន្ធ ត្រូវបានអនុញ្ញាតឱ្យកាត់បន្ថយក្នុងម្នាក់ៗ ១៥០.០០០រៀល ក្នុង១ខែ។ ការកាត់បន្ថយនេះ ធ្វើឱ្យមូលដ្ឋានគិតពន្ធកាន់តែទាប ដែលនាំឱ្យអ្នកដែលមានប្រាក់បៀវត្សប្រចាំខែក្នុងរង្វង់ពី ១.២០០.០០០រៀល ដល់ ១.៦០០.០០០រៀល (ប្រមាណពី ៣០០ទៅ ៤០០ដុល្លារអាមេរិក) អាចនឹងត្រូវរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស។

ជាមួយគ្នានេះដើម្បីផ្តល់ភាពងាយស្រួលក្នុងការគណនាពន្ធលើប្រាប់បៀវត្សនេះ អគ្គនាយកដ្ឋានពន្ធដារ បានបង្កើតនូវកម្មវិធីទូរស័ព្ទ (App) «ពន្ធប្រាក់បៀវត្ស ឬ Cambodia Salary Tax 2018» អាចឱ្យអ្នកជាប់ពន្ធកាន់តែងាយស្រួលដឹងថា តើប្រាក់បៀវត្សរបស់ខ្លួនជាប់ពន្ធឬអត់?

## ២.២. បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស

### ២.២.១. និយមន័យ

**យោងតាមច្បាប់សារពើពន្ធ/ជំពូកទី២/ផ្នែកទី១/មាត្រា៤០ ៤១ និង៤២**

**ពន្ធលើប្រាក់បៀវត្ស** សំដៅដល់ពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្សដែលបានទទួលក្នុងក្របខណ្ឌនៃការបំពេញសកម្មភាពបំរើការងារ។

រូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ចំពោះប្រាក់បៀវត្សប្រភពកម្ពុជា និងបៀវត្សប្រភពបរទេស។

រូបវន្តបុគ្គលអនិវាសនជនត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ចំពោះប្រាក់បៀវត្សប្រទេសកម្ពុជា។

សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស ពាក្យគន្លឹះខាងក្រោមត្រូវបានកំណត់ន័យដូចតទៅ៖

១- ពាក្យ «**និវាសនជន**» ក្នុងករណីដែលប្រើចំពោះនិយោជិត អ្នកជាប់ពន្ធ ឬរូបវន្តបុគ្គល មានន័យថា និវាសនដ្ឋាន ឬមានកន្លែងស្នាក់នៅជាដើមនៅជាគោលដើម នៅក្នុងព្រះជាណាចក្រកម្ពុជា ឬមានវត្តមាននៅក្នុងព្រះជាណាចក្រកម្ពុជា លើសពី១៨២ថ្ងៃ ក្នុងរយៈពេល ១២ខែ ណាមួយដែលបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត។

២- ពាក្យ «**អនិវាសនជន**» មានន័យថា បុគ្គលណាមួយដែលមិនមែនជា និវាសនជន តាមកថាខណ្ឌ១ ខាងលើ និងទទួលប្រាក់បៀវត្សប្រភពកម្ពុជា។

៣- វៀរលែងតែមានបទបញ្ញត្តិផ្ទុយ ការប្រើពាក្យនិយោជិតអ្នកជាប់ពន្ធ និង រូបវន្តបុគ្គលគឺសំដៅដល់ទាំងនិវាសនជន និង អនិវាសនជនដូចមានចែងក្នុងមាត្រា៤០នៃច្បាប់សារពើពន្ធ។

៤- ពាក្យ «**និយោជក**» រួមមាន ស្ថាប័នរដ្ឋ នីតិបុគ្គលនិវាសនជន ក្រុមអាជីវកម្មនិវាសនជន គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការមិនស្វែងរកប្រាក់ចំណេញ ឬរូបវន្តបុគ្គលនិវាសនជនដែលប្រកបអាជីកម្ម។

៥- ពាក្យ «**និយោជិត**» សំដៅដល់រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្ស អំពីសកម្មភាពបម្រើការងាររបស់ខ្លួនរួមបញ្ចូលទាំងអ្នកទទួលខុសត្រូវ ឬអភិបាលរបស់សហគ្រាស មន្ត្រីរាជការ មន្ត្រីជ្រើសតាំងបោះឆ្នោត លើកលែងតែ សមាជិករដ្ឋសភា និងព្រឹទ្ធសភា។

៦- ពាក្យ «**ប្រាក់បៀវត្សប្រភពកម្ពុជា**» មានន័យថាប្រាក់បៀវត្ស ដែលបានទទួលក្នុងក្របខណ្ឌនៃការបំពេញសកម្មភាពបំរើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយឡែកចំពោះប្រាក់បៀវត្សដែលអនិវាសជនបានទទួលក្នុងការផ្តល់ជំនួយបច្ចេកទេស ត្រូវចាត់ទុកថាមានប្រភពនៅក្នុងប្រទេសដែលទូទាត់ប្រាក់បៀវត្សនោះស្នាក់នៅ។

៧- ពាក្យ «**បរទេស**»

ក. ពេលណាប្រើជាមួយរូបវន្តបុគ្គលមានន័យថាជា អនិវាសនជន

ខ. ចំពោះការកំណត់ប្រភពប្រាក់ចំណូលមានន័យថា ក្រៅពីព្រះរាជាណាចក្រកម្ពុជា។

៨- ពាក្យ «**ប្រាក់បៀវត្ស**» ក្នុងច្បាប់នេះ សំដៅដល់ប្រាក់បៀវត្ស លាភការ ប្រាក់បំណាច់បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែម ដែលបានទូទាត់ឱ្យដល់និយោជិត ឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិតចំពោះការបំពេញសកម្មភាពបម្រើការងារ។

### ២.២.២. ដែនវិសាលភាពនៃពន្ធលើប្រាក់បៀវត្ស

ពន្ធលើប្រាក់បៀវត្សត្រូវបានសហគ្រាសធ្វើការកាត់ទុក មុនពេលបើកប្រាក់បៀវត្សនោះឱ្យដល់និយោជិត ហើយសហគ្រាសមានកាតព្វកិច្ចបង់ប្រាក់ពន្ធនោះជូនរដ្ឋបាលសារពើពន្ធ តាមកាល

បរិច្ឆេទដែលច្បាប់បានកំណត់ត្រឹមថ្ងៃទី២០ នៃខែបន្ទាប់។ ពន្ធលើប្រាក់បៀវត្សគឺជាពន្ធប្រចាំខែដែលកំណត់លើប្រាក់បៀវត្សរបស់រូបវន្តបុគ្គលបានទទួល ក្នុងក្របខណ្ឌនៃការបំពេញសកម្មភាពឱ្យដល់សហគ្រាស ហើយរូបវន្តបុគ្គលដែលជានិវាសនជន ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា និងប្រាក់បៀវត្សប្រភពបរទេស រីឯរូបវន្តដែលជាអនិវាសនជនត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ចំពោះប្រាក់បៀវត្សប្រភពកម្ពុជា ទៅតាមច្បាប់សារពើពន្ធរបស់ប្រទេសកម្ពុជា។

### ២.២.៣. ការលើកលែងពន្ធលើប្រាក់បៀវត្ស

**ច្បាប់សារពើពន្ធ/ជំពូកទី២/ផ្នែកទី២/មាត្រា៤៣ និង៤៤**

ការលើកលែងពន្ធលើកប្រាក់បៀវត្សរបស់មន្ត្រីការទូត និងមន្ត្រីបរទេសដទៃទៀត ត្រូវបានកំណត់ដូចតទៅ៖

១- ត្រូវបានលើកលែងពន្ធលើប្រាក់បៀវត្សចំពោះ៖

ក. ប្រាក់បៀវត្សដែលមន្ត្រី និងនិយោជិតនៃបេសកម្មទូត ឬកុងស៊ុលរបស់រដ្ឋាភិបាលបរទេសណាមួយដែលកាន់លិខិតឆ្លងដែនការទូត ឬផ្លូវការរបស់ប្រទេសនោះ បានទទួលក្នុងក្របខណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាច្រកម្ពុជា។

ខ. ប្រាក់បៀវត្សដែលតំណាងមន្ត្រី និងនិយោជិតបរទេសរបស់អង្គការអន្តរជាតិ និងរបស់ទីភ្នាក់ងារខាងសហប្រតិបត្តិការបរទេសនៃរដ្ឋាភិបាលដទៃទៀត បានទទួលក្នុងក្របខណ្ឌនៃការបំពេញមុខងារនៅក្នុងព្រះរាជាណាក្រកម្ពុជា។

២- ការលើកលែងពន្ធត្រូវឈរលើគោលការណ៍បដិការ រវាងរដ្ឋាភិបាលពាក់ព័ន្ធ។

**ប្រាក់ចំណូលលើកលែងពន្ធរបស់និយោជិតដែលត្រូវបានលើកលែងពន្ធ៖**

១- ប្រាក់សំណងដោយពិតប្រាកដនូវចំណាយខាងវិជ្ជាជីវៈ ដែលបានចាយវាយដោយនិយោជិតតាមសេចក្ដីបង្គាប់ និងសម្រាប់ប្រយោជន៍និយោជកហើយដែលបានបំពេញលក្ខខណ្ឌចំនួន៣ដូចតទៅ៖

ក. បានចាយក្នុងផលប្រយោជន៍ផ្ទាល់ និងដាច់ខាតរបស់សហគ្រាស

ខ. មិនបង្ហាញលក្ខណៈហួសប្រមាណ ឬស្ដុកស្ដម្ភហួសហេតុ

គ. បានបង្ហាញជាភស្តុតាងដោយមានវិក្កយបត្រដោយលម្អិត និងបានទូទាត់ស្រេចបាច់ ហើយដែលបានធ្វើក្នុងនាមជាអ្នកទទួលប្រាក់សំណង នូវរាល់ចំណាយពិតប្រាកដ

២- ប្រាក់បំណាច់នៃការបញ្ឈប់មិនឱ្យធ្វើការ ក្នុងកម្រិតដែលចែងក្នុងបញ្ញត្តិច្បាប់ការងារ

៣- លាភការបន្ថែមដែលមានលក្ខណៈខាងសង្គមកិច្ចក្នុងករណីដែលត្រូវបានបញ្ញត្តិក្នុងច្បាប់ការងារ

៤- ការផ្គត់ផ្គង់ដោយឥតយកថ្លៃ ឬមួយយកថ្លៃដែលទាបជាងថ្លៃដើម នៃឯកសណ្ឋាន ឬបរិក្ខារសម្រាប់វិជ្ជាជីវៈពិសេស

៥- ប្រាក់ចំណាយមៅការសម្រាប់ចំណាយបេសកកម្ម និងការធ្វើដំណើរ។ ប្រាក់បំណាច់នេះមិនត្រូវត្រួតគ្នានឹងប្រាក់សំណងពិតប្រាកដ នូវចំណាយដែលចែងក្នុងមាត្រានេះឡើយ។

### ២.២.៤. អត្រាពន្ធលើប្រាក់បៀវត្ស

តាមការរៀបរាប់ក្នុងចំណុច ២.១. ស្តីពីការវិវត្តពន្ធលើប្រាក់បៀវត្សខាងលើ យើងសង្កេតឃើញថា ពន្ធលើប្រាក់បៀវត្សត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ១៩៩៧ មកម្លេះ ក៏ប៉ុន្តែដោយសារកត្តាសេដ្ឋកិច្ចកត្តានយោបាយ កត្តាសង្គម ជាដើម បានធ្វើឱ្យពន្ធលើប្រាក់បៀវត្សមានការកែប្រែអត្រាកំណើនតាមថ្នាក់ជាបន្តបន្ទាប់រហូតដល់ឆ្នាំ២០១៨ ដោយយោងតាមសេចក្តីណែនាំរបស់ អគ្គនាយកដ្ឋានពន្ធដារលេខ ០០២ សហវ-អពដ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ ដោយអនុលោមតាមមាត្រា៤៧ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងត្រូវកាត់ទុកដោយនិយោជកទៅតាមអត្រាកំណើនតាមថ្នាក់ដូចខាងក្រោមៈ

| ភាគបៀវត្សជាប់បង់ពន្ធប្រចាំខែ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០ ៛ | ដល់ | ១ ២០០ ០០០ ៛ | ០ |
| ពី | ១ ២០០ ០០១ ៛ | ដល់ | ២ ០០០ ០០០ ៛ | ៥% |
| ពី | ២ ០០០ ០០១ ៛ | ដល់ | ៨ ៥០០ ០០០ ៛ | ១០% |
| ពី | ៨ ៥០០ ០០១ ៛ | ដល់ | ១២ ៥០០ ០០០ ៛ | ១៥% |
| | | លើសពី | ១២ ៥០០ ០០០ ៛ | ២០% |

### ២.២.៥. ទាយជ្ជទានសម្រាប់សហព័ទ្ធ និងកូនក្នុងបន្ទុក

ផ្អែកលើការបង្ហាញភស្តុតាងនៃស្ថានភាពគ្រួសារដើម្បីសម្រួលដល់ជីវភាពរស់នៅរបស់មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ កម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តី ឬប្រពន្ធ ចាប់តាំងពីឆ្នាំ២០១៧មក រាជរដ្ឋាភិបាលក៏បានសម្រេចធ្វើការតម្លើងកម្រិតកាត់បន្ថយមូលដ្ឋានគិតពន្ធលើប្រាក់

បៀវត្សចំពោះកូនក្នុងបន្ទុក និងសហព័ទ្ធជាមេផ្ទះក្នុងម្នាក់ៗពី ៧៥.០០០រៀល ដល់ **១៥០.០០០រៀល** ក្នុងមួយខែ (កើនឡើងទ្វេមួយជាពីរ)។ ការតម្លើងកម្រិតកាត់បន្ថយនេះ ធ្វើឱ្យមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សកាន់តែតិចដែលនាំឱ្យ មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តី ឬប្រពន្ធ ដែលមានប្រាក់បៀវត្សក្នុងរង្វង់ ១.២០០.០០១ ដល់ ១.៦០០.០០០រៀល អាចនឹងរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស។

### ២.២.៦. ភាតព្វកិច្ចរបស់និយោជក និងនិយោជិត

**ឯកសារគតិយុត្ត ៖ ច្បាប់ស្តីពីសារពើពន្ធ មាត្រា ៥២ - ៥៤/ប្រកាសពបវ ផ្នែកទី៥.១ - ៥.២**

ទោះបីជាពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែមជាពន្ធលើប្រាក់ចំណូលរបស់និយោជិត និងជាបំណុលរបស់និយោជិតក៏ដោយ តែវាក៏ជាកាតព្វកិច្ចរួមគ្នារបស់និយោជក និងនិយោជិតក្នុងការបង់ពន្ធជូនអគ្គនាយកដ្ឋានពន្ធដារ។ ក្នុងការអនុវត្តជាក់ស្តែង ពន្ធលើប្រាក់បៀវត្សត្រូវបានកាត់ដោយនិយោជក និងត្រូវផ្ញើមកអគ្គនាយកដ្ឋានពន្ធដារ នៅក្នុងខែដែលត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ព្រោះនិយោជិតមិនតម្រូវឱ្យចុះបញ្ជីពន្ធក៏មិនតម្រូវឱ្យដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលដែរ។ ប្រកាសស្តីពីពន្ធលើប្រាក់បៀវត្សបានបញ្ជាក់យ៉ាងច្បាស់ថា **ពន្ធលើប្រាក់បៀវត្ស** គឺជាការប្រមូលពន្ធតាមរយៈការកាត់ទុកហើយ តែវាមិនមែនជាចំណាយរបស់និយោជក តែបំណុលពន្ធលើប្រាក់បៀវត្សជាបំណុលរបស់និយោជិតម្នាក់ៗ។

**និយោជកត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម៖**

i. កាត់ទុក និងបង់ពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ជូនទៅអគ្គនាយកដ្ឋានពន្ធដារ យ៉ាងយូរបំផុតនៅថ្ងៃទី២០ នៃខែបន្ទាប់ ពេលប្រាក់បៀវត្សត្រូវបានទូទាត់រួចរាល់ហើយ។

ii. រក្សាទុកនៅក្នុងឯកសារបម្រើការងាររបស់និយោជិត នូវព័ត៌មានដូចខាងក្រោម៖

ក. នាម និងគោត្តនាមរបស់និយោជិត

ខ. ភេទ

គ. ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត

ឃ. សញ្ជាតិ

ង. ទីលំនៅ ឬកន្លែងស្នាក់នៅ

ច. មុខងារ

ឆ. កាលបរិច្ឆេទចូលបម្រើការងារ និងឈប់បម្រើការងារ (បើមាន)

ជ. ប្រាក់បៀវត្សប្រចាំខែដុល ដែលមានចុះក្នុងកិច្ចសន្យាបម្រើការងារ

iii. កត់ត្រាក្នុងឯកសារទូទាត់លើរាល់ការទូទាត់ប្រាក់បៀវត្ស ដល់និយោជិតនូវព័ត៌មានដូចខាងក្រោម៖

ក. ប្រាក់បៀវត្សប្រចាំខែសរុបគ្មានអត្ថប្រយោជន៍បន្ថែម ដែលបានបើកឱ្យនិយោជិត

ខ. ការទូទាត់ផ្សេងៗ ដូចជាប្រាក់ម៉ោងបន្ថែម ប្រាក់សំណងនូវចំណាយ ហើយនិងការទូទាត់បុព្វលាភដទៃទៀត

គ. ការបង់ចូលបេឡាជាតិរបបសន្តិសុខសង្គម

ឃ. ចំនួនពន្ធដែលកាត់ទុក

iv. កត់ត្រានូវអត្ថប្រយោជន៍បន្ថែមដែលបានទូទាត់ដល់និយោជិត រួមមាន៖

ក. កត់ត្រានូវប្រភេទ និងតម្លៃនៃអត្ថប្រយោជន៍បន្ថែមនោះ

ខ. ករណីនិយោជកទិញអត្ថប្រយោជន៍បន្ថែម សម្រាប់ជាប្រយោជន៍ដល់និយោជិត និយោជកត្រូវរក្សាទុកវិក្កយបត្រ និងកិច្ចសន្យាទិញអត្ថប្រយោជន៍បន្ថែមនោះ

ពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ត្រូវប្រកាសលើលិខិតប្រកាសពន្ធតែមួយរួមគ្នា។ លិខិតប្រកាសត្រូវដាក់បំណុលពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ដែលត្រូវបង់ជូនអគ្គនាយកដ្ឋានពន្ធដារ យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ បន្ទាប់ពីប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែមត្រូវបានទូទាត់ជូននិយោជិត។

ដូច្នេះ ប្រាក់បៀវត្សដែលត្រូវទូទាត់ទៅនិយោជិតក្នុងខែមិថុនា ឆ្នាំ២០១៩ នឹងត្រូវបញ្ចូលក្នុងលិខិតប្រកាសពន្ធលើប្រាក់បៀវត្សក្នុងខែមិថុនា ឆ្នាំ២០១៩ ដែលចាំបាច់ត្រូវបំពេញដោយនិយោជក និងដាក់ជូនអគ្គនាយកដ្ឋានពន្ធដារ យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៩។

**សម្គាល់៖** មូលដ្ឋានគិតពន្ធសម្រាប់គិតពន្ធលើប្រាក់បៀវត្ស ត្រូវបញ្ចូលការទូទាត់ប្រាក់បៀវត្សជាប់ពន្ធ**ទាំងអស់**នៅក្នុងខែ - មិនត្រឹមតែការទូទាត់ប្រាក់បៀវត្សប្រចាំខែទេ។

## ២.៣. ការគណនាពន្ធលើប្រាក់បៀវត្ស

### ២.៣.១. មូលដ្ឋានលើការគណនាពន្ធប្រាក់បៀវត្ស

រំលឹកឡើងវិញ យោងតាមមាត្រា៤២ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ពាក្យ «**ប្រាក់បៀវត្ស**» សំដៅដល់ប្រាក់បៀវត្ស លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែមដែលបានទូទាត់ឱ្យដល់និយោជិត ឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិត ចំពោះការបំពេញសកម្មភាពបម្រើការងារ។

ផ្អែកលើសេចក្តីណែនាំរបស់ អគ្គនាយកដ្ឋានពន្ធដារលេខ ០០២សហវ-អពដ គ្រប់ក្រុមហ៊ុនសហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជន ស្ថាប័នរដ្ឋ អង្គការនានា ដែលមានកាតព្វកិច្ចកាត់ទុក

និងបង់ពន្ធលើប្រាក់បៀវត្ស (ពបវ) ត្រូវអនុវត្តអត្រាកំណើនតាមថ្នាក់ថ្មីចំពោះប្រាក់បៀវត្ស ដែលបើកជូននិយោជិតចាប់ពីខែមករា ឆ្នាំ២០១៨ តរៀងទៅ ដែលនឹងត្រូវដាក់លិខិតប្រកាសបង់ប្រាក់ពន្ធប្រចាំខែនីមួយៗយ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់។ ដើម្បីគណនាពន្ធលើប្រាក់បៀវត្សរបស់និយោជិតនិវាសនជន គេត្រូវរក*មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស ដោយយកចំនួនប្រាក់បៀវត្សជាប់ពន្ធសរុប ដកចេញនូវ ទាយជ្ជទានសម្រាប់សហព័ទ្ធ និងកូនក្នុងបន្ទុក។ ដោយឡែកចំពោះ កម្មករនិយោជិត រោងចក្រ សហគ្រាស ប្រាក់បៀវត្សជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យដកចេញបន្ថែមទៀតនូវប្រាក់ឧបត្ថម្ភដែលទទួលបានពីការបំពេញការងារ ដូចមានចែងក្នុងសារាចរលេខ ០១១ សហវ ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការអនុវត្តកាតព្វកិច្ច កាត់ទុកលើអត្ថប្រយោជន៍បន្ថែម។*

**២.៣.២. វិធីសាស្ត្រគណនាពន្ធលើប្រាក់បៀវត្សសម្រាប់និវាសនជន**

វិធីគណនាពន្ធលើប្រាក់បៀវត្ស អាចធ្វើឡើងបានតាមច្រើនបែប ប៉ុន្តែតម្រូវឱ្យអនុលោមតាមសេចក្តីណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានប្រកាសចេញនូវអត្រាកំណើនតាមថ្នាក់ដែលនឹងអាចប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ អាស្រ័យទៅតាមការចាំបាច់ និងស្ថានភាពជាក់ស្តែង។ **ខាងក្រោមនេះគឺជាវិធីសាស្ត្រក្នុងការគណនារកពន្ធលើប្រាក់បៀវត្សតាមរបៀបផ្សេងៗគ្នា៖**

ឧទាហរណ៍៖ លោក «**ក**» ជានាយកគ្រប់គ្រងផ្នែកអភិវឌ្ឍមុខជំនួញក្រុមហ៊ុននៅNEC។ គាត់ទទួលបានប្រាក់បៀវត្សប្រចាំខែដុលចំនួន ៣.៤៦០ដុល្លារអាមេរិក។ រៀងរាល់ខែ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងស្តីពីអត្រាប្តូរប្រាក់ផ្លូវការ នៅខែឧសភា ឆ្នាំ២០១៩ អត្រាប្តូរប្រាក់ផ្លូវការសម្រាប់គណនាពន្ធលើប្រាក់បៀវត្សគឺ ៤.០៥៥រៀល ក្នុង១ដុល្លារសហរដ្ឋអាមេរិក។ ដើម្បីគណនាពន្ធលើប្រាក់បៀវត្សរបស់លោក «**ក**» យើងត្រូវប្តូរប្រាក់ខែជាលុយដុល្លារបស់គាត់ ឱ្យទៅជាប្រាក់រៀលគឺ ៣.៤៦០ដុល្លារ គុណនឹងអត្រាប្តូរប្រាក់ ៤.០៥៥រៀល ក្នុង១ដុល្លារ ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ[17] (៣.៤៦០ x ៤.០៥៥ = **១៤.០៣០.៣០០រៀល**)។

ដូច្នេះ ១៤.០៣០.៣០០រៀលជាមូលដ្ឋានគិចតពន្ធលើប្រាក់បៀវត្សរបស់លោក «**ក**»

**ក. វិធានទី១ - វិធីសាស្ត្របូកបន្ថែម**

| ក | ខ | ក - ខ | អត្រា | ទឹកប្រាក់ពន្ធ |
|---|---|---|---|---|
| **១ ២០០ ០០០៛** | ០៛ | ១ ២០០ ០០០៛ | 0% | **០៛** |
| **២ ០០០ ០០០៛** | ១ ២០០ ០០០៛ | ៨០០ ០០០៛ | ៥% | **៤០ ០០០៛** |

[17] សូមមើលឧបសម្ព័ន្ធ

| ក | ខ | ក - ខ | អត្រា | ទឹកប្រាក់ពន្ធ |
|---|---|---|---|---|
| **៨ ៥០០ ០០០៛** | ២ ០០០ ០០០៛ | ៦ ៥០០ ០០០៛ | ១០% | **៦៥០ ០០០៛** |
| **១២ ៥០០ ០០០៛** | ៨ ៥០០ ០០០៛ | ៤ ០០០ ០០០៛ | ១៥% | **៦០០ ០០០៛** |
| **១៤ ០៣០ ៣០០៛** | ១២ ៥០០ ០០០៛ | ១ ៥៣០ ៣០០៛ | ២០% | **៣០៦ ០៦០៛** |
| **សរុបពន្ធលើប្រាក់បៀវត្សដែលត្រូវបង់** | | | | **១ ៥៥៦ ០៦០៛** |

**ខ. វិធានទី២- វិធីសាស្ត្រដកបន្ថយ**[18]

| | | | | |
|---|---|---|---|---|
| **១ ២០០ ០០០៛** | ៥% | ៦០ ០០០៛ | ៦០ ០០០៛ | ៥% |
| **២ ០០០ ០០០៛** | ៥% | ១០០ ០០០៛ | ១៦០ ០០០៛ | ១០% |
| **៨ ៥០០ ០០០៛** | ៥% | ៤២៥ ០០០៛ | ៥៨៥ ០០០៛ | ១៥% |
| **១២ ៥០០ ០០០៛** | ៥% | ៦៣៥ ០០០៛ | ១ ២១០ ០០០៛ | ២០% |

**ការបកស្រាយរូបមន្ត៖**

តាង Y ជាមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស

- **ប្រសិនបើ ១.២០០.០០០ < Y < ២.០០០.០០០ អត្រា ៥%**

  ពន្ធលើប្រាក់បៀវត្ស៖

  = (Y - ១.២០០.០០០) x ៥%

  **ពន្ធលើប្រាក់បៀវត្ស = Y៥% - ៦០,០០០**

- **ប្រសិនបើ ២.០០០.០០០ < Y < ៨.៥០០.០០០ អត្រា ១០%**

  ពន្ធលើប្រាក់បៀវត្ស៖

[18] លិខិតប្រកាសពន្ធទម្រង់ បពវ ០១

= (Y - ២.០០០.០០០) x ១០% + (២.០០០.០០០ - ១.២០០.០០០) x ៥%

= Y១០% - ២.០០០.០០០(១០% - ៥%) - ១.២០០.០០០ x ៥%

= Y១០% - ២.០០០.០០០ x ៥% - ១.២០០.០០០ x ៥%

= Y១០% - (២.០០០.០០០ + ១.២០០.០០០) x ៥%

**ពន្ធលើប្រាក់បៀវត្ស = Y១០% - ១៦០.០០០**

❖ **ប្រសិនបើ ៨.៥០០.០០០ < Y < ១២.៥០០.០០០ អត្រា ១៥%**

ពន្ធលើប្រាក់បៀវត្សៈ

= (Y - ៨.៥០០.០០០) x ១៥% + (៨.៥០០.០០០ - ២.០០០.០០០) x ១០% + (២.០០០.០០០ - ១.២០០.០០០) x ៥%

= Y១៥% - ៨.៥០០.០០០(១៥% - ១០%) - ២.០០០.០០០ x (១០% - ៥%) - ១.២០០.០០០ x ៥%

= Y១៥% - ៨.៥០០.០០០ x ៥% - ២.០០០.០០០ x ៥% - ១.២០០.០០០ x ៥%

= Y១៥% - (៨.៥០០.០០ + ២.០០០.០០០ + ១.២០០.០០០) x ៥%

**ពន្ធលើប្រាក់បៀវត្ស = Y១៥% - ៥៨៥.០០០**

❖ **ប្រសិនបើ Y > ១២.៥០០.០០០ អត្រា ២០%**

ពន្ធលើប្រាក់បៀវត្សៈ

= (Y - ១២.៥០០.០០០) x ២០% + (១២.៥០០.០០០ - ៨.៥០០.០០០)x ១៥% + (៨.៥០០.០០០ - ២.០០០.០០០) x ១០% + (២.០០០.០០០ -១.២០០.០០០) x ៥%

= Y២០% - ១២.៥០០.០០០(២០% - ១៥%) - ៨.៥០០.០០០(១៥% -១០%) - ២.០០០.០០០ x (១០% - ៥%) - ១.២០០.០០០ x ៥%

= Y២០% - ១២.៥០០.០០០ x ៥% - ៨.៥០០.០០០ x ៥% - ២.០០០.០០០ x ៥% - ១.២០០.០០០ x ៥%

= Y២០% - (១២.៥០០.០០០ + ៨.៥០០.០០ + ២.០០០.០០០ + ១.២០០.០០០) x ៥%

**ពន្ធលើប្រាក់បៀវត្ស = Y២០% - ១.២១០.០០០**

**នៅពេលជំនួសតួលេខប្រាក់បៀវត្ស ១៤.០៣០.៣០០រៀល ចូលក្នុងតារាងខាងក្រោមៈ**

| **ជំនួសតួលេខប្រាក់បៀវត្ស ១៤.០៣០.៣០០រៀល** | | |
|---|---|---|
| **៥%** | (២ ០០០ ០០០៛ - ១ ២០០០ ០០០៛) x ៥% | ៤០ ០០០៛ |
| **១០%** | (៨ ៥០០ ០០០៛ - ២ ០០០ ០០០៛) x ១០% | ៦៥០ ០០០៛ |
| **១៥%** | (១២ ៥០០ ០០០៛ - ៨ ៥០០ ០០០៛) x ១៥% | ៦០០ ០០០៛ |
| **២០%** | (១៤ ០៣០ ៣០០៛ - ១២ ៥០០ ០០០៛) x ២០% | ៣០៦ ០៦០៛ |
| **សរុបពន្ធលើប្រាក់បៀវត្សដែលត្រូវបង់** | | **១ ៥៩៦ ០៦០៛** |

### ២.៣.៣. វិធីគណនាពន្ធលើប្រាក់បៀវត្សតាមវិធីនាប់រហ័ស[19]

ដើម្បីគណនាពន្ធលើប្រាក់បៀវត្សរបស់និយោជិតនិវាសនជន ត្រូវរកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស ដោយយកចំនួនប្រាក់បៀវត្សជាប់ពន្ធសរុប ដកចេញនូវ ទាយជ្ជទានសម្រាប់សហព័ទ្ធ និងកូនក្នុងបន្ទុក។ ដោយឡែកចំពោះ កម្មករនិយោជិត រោងចក្រ សហគ្រាស ប្រាក់បៀវត្សជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យដកចេញបន្ថែមទៀតនូវ ប្រាក់ឧបត្ថម្ភផ្សេងៗដែលទទួលបានពីការបំពេញការងារដូចមានចែងក្នុងសារាចរ លេខ០១១ សហវ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកលើអត្ថប្រយោជន៍បន្ថែម។

បន្ទាប់មកត្រូវពិនិត្យមើលថា តើមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សនោះស្ថិតក្នុងថ្នាក់អត្រាពន្ធមួយណា ទើបយកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សនោះ ទៅគុណនឹងអត្រាពន្ធ ហើយដកចេញនូវលម្អៀងលើសប្រាក់ពន្ធសម្រាប់ថ្នាក់អត្រាពន្ធនោះ។ លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ គឺជាផលបូកនៃពន្ធលើប្រាក់បៀវត្សដែលបានលើកលែងចំពោះប្រាក់បៀវត្ស ១.២០០.០០០រៀល ដំបូង និងលម្អៀងលើសនៃប្រាក់ពន្ធតាមថ្នាក់នីមួយៗ។

ខាងក្រោមនេះជាតារាងអត្រាកំណើនតាមថ្នាក់និងលម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ៖

| ភាគបៀវត្សជាប់បង់ពន្ធប្រចាំខែ | | | | អត្រា | លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ |
|---|---|---|---|---|---|
| ពី | ០ ៛ | ដល់ | ១ ២០០ ០០០ ៛ | ០ | ០ ៛ |
| ពី | ១ ២០០ ០០១ ៛ | ដល់ | ២ ០០០ ០០០ ៛ | ៥% | ៦០ ០០០ ៛ |
| ពី | ២ ០០០ ០០១ ៛ | ដល់ | ៨ ៥០០ ០០០ ៛ | ១០% | ១៦០ ០០០ ៛ |
| ពី | ៨ ៥០០ ០០១ ៛ | ដល់ | ១២ ៥០០ ០០០ ៛ | ១៥% | ៥៨៥ ០០០ ៛ |
| លើសពី | | | ១២ ៥០០ ០០០ ៛ | ២០% | ១ ២១០ ០០០ ៛ |

**រូបមន្ត៖**

- **ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០.០០០៛ X សហព័ទ្ធនិងកូនក្នុងបន្ទុក**
- **មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស (មពបវ) = ប្រាក់បៀវត្សជាប់ពន្ធ (បវ) – ទាយជ្ជទាន សហព័ទ្ធនិងកូនក្នុងបន្ទុក**

[19] សេចក្តីណែនាំរបស់ អគ្គនាយកដ្ឋានពន្ធដារលេខ ០០២ សហវ-អពដ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨

- **ពន្ធលើប្រាក់បៀវត្ស (ពបវ) = មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស (មពបវ) x អត្រាពន្ធ – លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ (លបព)**

**កំណត់សម្គាល់៖**

ចំពោះកម្មករនិយោជិត រោងចក្រ សហគ្រាស ប្រសិនបើប្រាក់បៀវត្សជាប់ពន្ធ (បវ) មានរួមបញ្ចូលនូវប្រាក់ឧបត្ថម្ភដែលទទួលបានពីការបំពេញការងារ ប្រាក់ឧបត្ថម្ភនោះត្រូវបានអនុញ្ញាតឱ្យដកចេញពីប្រាក់បៀវត្សជាប់ពន្ធ (បវ)។

**ឧទាហរណ៍ទី១៖** កម្មករនិយោជិត រោងចក្រ សហគ្រាសម្នាក់មានបៀវត្ស ១.៨០០.០០០រៀល ដែលក្នុងនោះមានប្រាក់ឧបត្ថម្ភសោហ៊ុយធ្វើដំណើរ និងថ្លៃបាយសរុប ១០០.០០០រៀល។

❖ **ករណីនៅលីវ**

មពបវ = ១.៨០០.០០០៛ - ១០០.០០០៛ = ១.៧០០.០០០៛ (ត្រូវជាប់ក្នុងអត្រា ៥%)

លបព = ៦០.០០០៛

**ពបវ** (ពន្ធលើប្រាក់បៀវត្ស) = (១.៧០០.០០០៛ x ៥%) - ៦០.០០០៛ = **២៥.០០០៛**

❖ **ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣ ក្នុងបន្ទុក**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០.០០០៛ x ៤ = ៦០០.០០០៛

មពបវ = ១.៨០០.០០០៛ - ១០០.០០០៛ - ៦០០.០០០៛ = ១.១០០.០០០៛ (ត្រូវជាប់ក្នុងអត្រា 0%)

លបព = 0៛

**ពបវ** (ពន្ធលើប្រាក់បៀវត្ស) = (១.១០០.០០០៛ x 0%) - 0៛ = **0៛**

**ឧទាហរណ៍ទី២៖** អ្នកគ្រប់គ្រងក្រុមហ៊ុនម្នាក់បៀវត្ស ៨.៦០០.០០០

❖ **ករណីនៅលីវ**

មពបវ = ៨.៦០០.០០០៛ (ត្រូវជាប់ក្នុងអត្រា ១៥%)

លបព = ៥៨៥.០០០៛ (លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់)

ពបវ = (៨.៦០០.០០០៛ x ១៥%) - ៥៨៥.០០០៛ = **៧០៥.០០០៛**

❖ **ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣ ក្នុងបន្ទុក**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០.០០០៛ x ៤ = ៦០០.០០០៛

មពបវ = ៨.៦០០.០០០៛ - ៦០០.០០០៛ = ៨.០០០.០០០៛ (ត្រូវជាប់ក្នុងអត្រា ១០%)

លបព = ១ ៦០០ ០០០៛

ពបវ = (៨.០០០.០០០៛ x ១០%) - ១៦០ ០០០៛ = **៦៤០.០០០៛**

### ២.៣.៤. វិធីគណនាពន្ធលើប្រាក់បៀវត្សតាមកម្មវិធីទូរស័ព្ទដៃ

ដើម្បីងាយស្រួលក្នុងការគណនាពន្ធលើប្រាក់បៀវត្ស អគ្គនាយកដ្ឋានពន្ធដារបានបង្កើតនូវកម្មវិធីគណនាពន្ធលើប្រាក់បៀវត្សនៅលើទូរសព្ទដៃ និងឧបករណ៍អេឡិចត្រូនិចនានា ដែលដើរដោយប្រព័ន្ធ iOS និង ANDROID ដោយត្រូវតម្លើងកម្មវិធីមានឈ្មោះជាភាសាអង់គ្លេសថា «Salary Tax 2018» នៅលើទូរសព្ទដៃ ឬឧបករណ៍អេឡិចត្រូនិច ហើយត្រូវជ្រើសរើស និងបញ្ចូលព័ត៌មានមួយចំនួន ដូចមានបង្ហាញក្នុងរូបភាពខាងក្រោម។ បើកកម្មវិធី «Salary Tax 2018» រួចចុចលើពាក្យ **<u>និវាសនជន</u>** ឬ អនិវាសនជន និងបំពេញព័ត៌មានចូលក្នុងប្រអប់នោះ៖

**<u>ករណីប្រាក់បៀវត្សជាប្រាក់រៀល៖</u>**




**<u>ករណីប្រាក់បៀវត្សជាប្រាក់ដុល្លារ៖</u>** ត្រូវចុចលើពាក្យ ជាប្រាក់ដុល្លារ រួចបញ្ចូលប្រាក់ខែជាប្រាក់ដុល្លារទៅក្នុងប្រអប់ប្រាក់បៀវត្សប្រចាំខែ* និងបញ្ចូលអត្រាប្តូរប្រាក់ទៅក្នុងប្រអប់អត្រាប្តូរប្រាក់ (1USD)*។

<u>បញ្ជាក់</u>៖ ត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ។



### ២.៣.៥. វិធីសាស្ត្រគណនាពន្ធលើប្រាក់បៀវត្សសម្រាប់អនិវាសនជន

ការគណនាពន្ធលើប្រាក់បៀវត្សចំពោះអនិវាសនជនមានភាពងាយស្រួលជាង ជាមួយនឹងអត្រា **២០%** (ម្ភៃភាគរយ) ថេរ ហើយតម្រូវឱ្យអនុវត្តលើចំនួនប្រាក់បៀវត្សជាប់ពន្ធប្រចាំខែទាំងអស់ ដោយមិនមានការគិតពន្ធតាមថ្នាក់នៅអត្រាផ្សេងគ្នានោះទេ។

**រូបមន្តៈ**

- **ពន្ធលើប្រាក់បៀវត្ស (ពបវ) = ប្រាក់បៀវត្សជាប់ពន្ធ (បវ) X ២០%**

**ឧទាហរណ៍ៈ**

លោក ***ភូល*** ត្រូវចាត់ទុកជាអ្នកជាប់ពន្ធអនិវាសនជន ដែលធ្វើការងារក្នុងកិច្ចសន្យាបណ្ដោះអាសន្នក្នុងប្រទេសកម្ពុជា ទទួលបានប្រាក់បៀវត្ស ១០.០០០.០០០រៀល ដែលជាប្រភពកម្ពុជា ហើយត្រូវបានទូទាត់ដោយក្រុមហ៊ុនចុះបញ្ជីកម្ពុជា។

- ពន្ធលើប្រាក់បៀវត្សដែលត្រូវបង់គឺ ១០.០០០.០០០រៀល x ២០% = **២.០០០.០០០រៀល**
- លោក ***ភូល*** ទទួលបានប្រាក់បៀវត្សសុទ្ធចំនួន ៨.០០០.០០០រៀល៕

# ជំពូកទី៣
# វិធីសាស្ត្រគណនា
# ពន្ធលើអត្ថប្រយោជន៍បន្ថែម
# និង ឥណទានពន្ធបរទេស

# ជំពូកទី៣
# វិធីសាស្ត្រគណនាពន្ធលើអត្ថប្រយោជន៍បន្ថែម និងឥណទានពន្ធបរទេស

## ៣.១. ពន្ធលើអត្ថប្រយោជន៍បន្ថែម

**ច្បាប់សារពើពន្ធ/ជំពូកទី២/ផ្នែកទី៣/មាត្រា៤៨**

ចំពោះអត្ថប្រយោជន៍បន្ថែម ជារៀងរាល់ខែនិយោជកត្រូវកាត់ទុក និងបង់ពន្ធតាមការកំណត់ តាមអត្រា **២០% (ម្ភៃភាគរយ)** ថេរ នៃតម្លៃសរុបរបស់អត្ថប្រយោជន៍បន្ថែម ដែលផ្តល់ឱ្យនិយោជិតទាំងអស់។ តម្លៃនៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សាររួមទាំងពន្ធអាករទាំងអស់។

### ៣.១.១. តើអ្វីជាអត្ថប្រយោជន៍បន្ថែម?

និយោជកមួយចំនួនផ្តល់ប្រាក់សំណងទៅនិយោជិត ជំនួសឱ្យ ឬបន្ថែមពីលើប្រាក់បៀវត្សដែលជាចំណែកមួយនៃកញ្ចប់ប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗ។ អត្ថប្រយោជន៍បន្ថែមទាំងនេះជាញឹកញាប់មិនមែនជាសាច់ប្រាក់ដែលទូទៅជាវត្ថុ ឧទាហរណ៍ដូចជាការប្រើប្រាស់រថយន្តរបស់ក្រុមហ៊ុន។ អត្ថប្រយោជន៍ទាំងនេះ អាចត្រូវបានផ្តល់ជូនទៅឱ្យនិយោជិត ឬសមាជិកគ្រួសាររបស់និយោជិត។

### ៣.១.២. វិសាលភាពនៃអត្ថប្រយោជន៍បន្ថែម

វិសាលភាពអត្ថប្រយោជន៍បន្ថែមដែលស្ថិតក្រោមច្បាប់ស្តីពីសារពើពន្ធ គឺមានលក្ខណៈទូលំទូលាយរួមមាន ទំនិញ សេវា ឬអត្ថប្រយោជន៍ជាសាច់ប្រាក់ ឬជាវត្ថុផ្សេងទៀត ដែលនិយោជកផ្តល់ឱ្យដោយផ្ទាល់ ឬដោយប្រយោលដល់រូបវន្តបុគ្គល ចំពោះសកម្មភាពបំរើការងារដែលរូបវន្តបុគ្គលនោះបានបំពេញដើម្បីជាផលប្រយោជន៍ដល់និយោជក (ផ្នែកទី៣.១ នៃប្រកាស ពបវ)[20]។ បញ្ជីនៃអត្ថប្រយោជន៍បន្ថែម ដែលស្ថិតនៅក្រោមវិសាលភាពនៃអត្ថប្រយោជន៍បន្ថែមជាប់ពន្ធ មានបង្ហាញជូនក្នុងប្រកាស ពបវ (សូមមើលតារាងខាងក្រោម ដែលដកស្រង់ចេញពីប្រកាស ពបវ)។ តារាងនេះបង្ហាញនូវអត្ថប្រយោជន៍បន្ថែមធម្មតា ដែលផ្តល់ជូនដោយនិយោជក ប៉ុន្តែមិនកំណត់តែនៅក្នុងតារាងនោះទេ ផ្ទុយមកវិញអត្ថប្រយោជន៍ដែលមិនមានកំណត់ក្នុងតារាងនេះ ក៏អាចជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែមផងដែរ។

| ប្រភេទអត្ថប្រយោជន៍ | ការពន្យល់ |
|---|---|
| **យានយន្តគ្រប់ប្រភេទ** | ការប្រើប្រាស់ឡាន ឬរថយន្តផ្សេងៗ |

[20] **ពបវ** ជាអក្សរកាត់នៃពាក្យ ពន្ធលើប្រាក់បៀវត្ស

| | |
|---|---|
| ម្ហូបអាហារ | |
| លំនៅដ្ឋាន និងការស្នាក់នៅ | ផ្ទះ ឬលំនៅដ្ឋាន ជាដើម |
| ទឹក ភ្លើង ទូរស័ព្ទ | ការបង់លើវិក្កយបត្រទឹក ភ្លើង ទូរស័ព្ទចំពោះការស្នាក់នៅ |
| អ្នកបម្រើការងារក្នុងលំនៅដ្ឋាន | ដូចជាអ្នកបោសសំអាត អ្នកបើកបរជាដើម |
| កម្ចីដោយឥតការប្រាក់ ឬទាបជាងអត្រាទីផ្សារ | ការប្រាក់លើកម្ចីទាបជាងអត្រាទីផ្សារ ដែលអត្រាការប្រាក់ទីផ្សារត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ការលក់ទំនិញបញ្ចុះថ្លៃ | អ្នកផលិត ឬអ្នកលក់រាយអាចផ្តល់ទំនិញទៅបុគ្គលិក នូវតម្លៃទាបជាងតម្លៃទីផ្សារធម្មតា - ចំនួនបញ្ចុះតម្លៃត្រូវចាត់ទុកជាអត្ថប្រយោជន៍បន្ថែម |
| ជំនួយផ្នែកអប់រំសម្រាប់និយោជិត ដែលមិនទាក់ទិននឹងការបំពេញការងារ | ជំនួយផ្នែកអប់រំដែលមិនទាក់ទិនផ្ទាល់នឹងកាតព្វកិច្ចបំពេញការងារ |
| ជំនួយផ្នែកអប់រំសម្រាប់កូនរបស់និយោជិត | ជំនួយផ្នែកអប់រំដែលផ្តល់ជូនទៅកូនក្នុងបន្ទុករបស់និយោជិត |
| បុព្វលាភធានារ៉ាប់រងអាយុជីវិត និងសុខភាព លើកលែងតែមានផ្តល់អត្ថ-ប្រយោជន៍បន្ថែមដូចគ្នាឱ្យដល់និយោជិតគ្រប់រូប ដោយគ្មានការបែងចែកតាមទួនាទីឬមុខងារ | ក្រុមហ៊ុនដែលផ្តល់ធានារ៉ាប់រងសុខភាពនូវក្នុងកម្រិតដូចគ្នាទៅឱ្យបុគ្គលិកទាំងអស់នោះ បុព្វលាភធានារ៉ាប់រងនឹងមិនជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែមទៅលើនិយោជិតទេ។ ប្រសិនបើបុគ្គលិកមួយចំនួនទទួលបានធានារ៉ាប់រង ឧទាហរណ៍ផ្តល់ឱ្យតែបុគ្គលិកនៅកម្រិតគ្រប់គ្រង បុព្វលាភធានារ៉ាប់រងនឹងត្រូវជាប់ពន្ធ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលបុគ្គលិកមួយចំនួនទទួលបានធានារ៉ាប់រងកម្រិតខ្ពស់ជាងនោះបុព្វលាភធានារាប់រងនឹងត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែមចំពោះបុគ្គលិកមួយចំនួននោះ។ |
| ចំណែកនៃការឧបត្ថម្ភដែលហួសហេតុ | ចំណែកនៃការឧបត្ថម្ភដែលមិនចាត់ទុកថាសមហេតុផល និងមិនចាំបាច់សម្រាប់អាជីវកម្មរបស់និយោជក |
| ចំនួនប្រាក់បង់ចូលបេឡាជាតិរបបសន្តិសុខសង្គមដែលលើសពីកម្រិតដែលច្បាប់បានអនុញ្ញាត | ច្បាប់នាពេលបច្ចុប្បន្នបានកំណត់ថា និយោជកអាចបង់ ០.៨% នៃបៀវត្សប្រចាំខែជាមធ្យមរបស់និយោជិត ជាចំនួនទឹកប្រាក់ត្រូវបង់ចូលបេឡាជាតិរបបសន្តិសុខសង្គម។ ដូច្នេះចំនួនដែលលើសនឹងត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែម |
| ចំនួនប្រាក់បង់ពន្ធចូលបេឡាសោធនដែលលើសពី ១០% នៃប្រាក់បៀវត្សប្រចាំខែ | សម្គាល់ថាការគណនានេះគឺអាស្រ័យតែលើប្រាក់បៀវត្សប្រចាំខែប៉ុណ្ណោះ គឺមិនមានបញ្ចូលនូវអត្ថប្រយោជន៍បន្ថែមទេ |

| | |
|---|---|
| **ចំណាយដែលមិនទាក់ទិននឹងសកម្មភាពការងារ** | ការចំណាយទាំងនេះមានដូចជាការកំសាន្ត ឬការសម្រាកលំហែ |

**៣.១.៣. ការគណនាពន្ធលើអត្ថប្រយោជន៍បន្ថែម**

**យោងតាមច្បាប់ស្តីពីសារពើពន្ធ មាត្រា៤៨-៤៩/ប្រកាសពបវ ផ្នែកទី៣-៣/ប្រកាស៥៩៩**

ពន្ធលើអត្ថប្រយោជន៍បន្ថែមត្រូវគិតតាមអត្រា **២០% (ម្តៃភាគរយ)** ថេរ ដែលអនុវត្តលើតម្លៃសរុបនៃអត្ថប្រយោជន៍ទាំងអស់ដែលផ្តល់ជូនទៅនិយោជិតដោយផ្ទាល់ ឬដោយប្រយោលតាមរយៈសមាជិកគ្រួសារ រួមទាំងពន្ធអាករផ្សេងៗដែលត្រូវជាប់ពន្ធ។

ចំពោះការអនុវត្តពីមុន តម្លៃអត្ថប្រយោជន៍បន្ថែមត្រូវបំប៉ោង (ដោយចែកនឹង០.៨) មុនពេលគណនាពន្ធលើអត្ថប្រយោជន៍បន្ថែម ក៏ប៉ុន្តែបន្ទាប់ពីប្រកាសលេខ៥៩៩ ត្រូវបានដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ២០០៩ នោះមិនមែនជាវិធីសាស្ត្រត្រឹមត្រូវឡើយ ហើយពន្ធដែលត្រូវអនុវត្តន៍ត្រូវយកតម្លៃជាក់ស្តែងនៃអត្ថប្រយោជន៍ដែលផ្តល់ជូន។ ក្នុងករណីនិយោជកបង់ពន្ធលើអត្ថប្រយោជន៍បន្ថែមដោយពន្ធជាបន្ទុកខ្លួនឯង និយោជកមិនត្រូវបានអនុញ្ញាតឱ្យកាត់កងជាចំណាយ នៅពេលគណនាពន្ធលើប្រាក់ចំណេញនៅចុងឆ្នាំទេ។

យោងតាមការរៀបរាប់ខាងលើ តម្លៃថេរនៃអត្ថប្រយោជន៍បន្ថែមដែលទទួលបាន ត្រូវជាប់ពន្ធតែមួយគត់តាមអត្រា **២០%** មិនចំពោះកម្រិតនៃអត្ថប្រយោជន៍ ឬក៏ស្ថានភាពនិវាសនជនរបស់និយោជិកឡើយ។

**ឧទាហរណ៍១៖ លោក ភីតធី** ទទួលបានអត្ថប្រយោជន៍ប្រចាំខែដូចខាងក្រោម៖

- ការធានារ៉ាប់រងខាងវេជ្ជសាស្ត្រដែលផ្តល់ជូនតែថ្នាក់គ្រប់គ្រង ៥០ដុល្លារ
- ការស្នាក់នៅក្នុងអាផាតមិន ១.១០០ដុល្លារ
- អ្នកសម្អាត/ចុងភៅ ៣០០ដុល្លារ
- អត្រាប្តូរប្រាក់ផ្លូវការរបស់អពដគឺ ៤.០៥៥រៀលក្នុង១ដុល្លារ ក្នុងខែឧសភា ឆ្នាំ២០១៩

តម្លៃសរុបនៃអត្ថប្រយោជន៍បន្ថែមរបស់លោក ភីតធី គឺ ១.៤៥០ដុល្លារ (៥០ + ១.១០០ + ៣០០ដុល្លារ)។ នៅពេលគិតពន្ធលើអត្ថប្រយោជន៍បន្ថែម ត្រូវប្តូរទៅជាប្រាក់រៀល ទៅតាមអត្រាប្តូរប្រាក់ផ្លូវការដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ តម្លៃសរុបនៃអត្ថប្រយោជន៍បន្ថែមរបស់លោក ភីតធី គឺ ៥.៨៧៩.៧៥០រៀល។

ដូច្នេះពន្ធលើអត្ថប្រយោជន៍បន្ថែមរបស់លោក ភីតធី គឺ **១.១៧៥.៩៥០ រៀល** (៥.៨៧៩.៧៥០ រៀល គុណនឹង ២០%)។

**ឧទាហរណ៍២៖ លោក សែម៉ុន** ជានិវាសនជនកម្ពុជា ធ្វើការនៅសណ្ឋាគារមួយនៅភ្នំពេញ ដែលគ្រប់គ្រងដោយក្រុមហ៊ុនបានចុះបញ្ជីកម្ពុជា។ លោក សែម៉ុន នៅលីវ និងមិនមាននោះកូនទេ។ ក្នុងខែកុម្ភៈ ឆ្នាំ២០១៥ គាត់ទទួលបានការទូទាត់ដូចខាងក្រោម៖

- ប្រាក់បៀវត្សមូលដ្ឋាន ២.៥០០ដុល្លារ
- ការទូទាត់ប្រាក់ម៉ោងបន្ថែម ៣០០ដុល្លារ
- ការផ្តល់ការស្នាក់នៅតម្លៃ ១.០០០ដុល្លារ
- ប្រាក់បេឡាសោធន ១០០ដុល្លារ
- ប្រាក់សំណងនៃចំណាយបេសកកម្ម ២០០ដុល្លារ សម្រាប់ធ្វើដំណើរទៅសណ្ឋាគារសៀមរាបដែលគ្រប់គ្រងដោយនិយោជករបស់គាត់ រួមទាំងការហោះហើរពីភ្នំពេញទៅសៀមរាបដែលគាត់មានវិក្កយបត្រសម្រាប់ជាឯកសារ។

*ចូរគណនា ពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែមរបស់លោក សែ ម៉ុន ក្នុងខែកុម្ភៈ ឆ្នាំ២០១៩ ជាប្រាក់រៀល ជាមួយអត្រាប្តូរប្រាក់ផ្លូវការ ១ដុល្លារ ស្មើនឹង ៤,០៥៥រៀល?*

**ចម្លើយ៖**

- ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែរបស់គាត់ គឺ ២.៨០០ដុល្លារ (ប្រាក់បៀវត្ស ២.៥០០ + ប្រាក់ម៉ោងបន្ថែម ៣០០) ឬ១១.៣៥៤.០០០រៀល ហើយអត្ថប្រយោជន៍បន្ថែមជាប់ពន្ធរបស់គាត់គឺ ១.០០០ដុល្លារ ឬ ៤.០៥៥.០០០ (ការស្នាក់នៅ)។
- លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់សម្រាប់ប្រាក់បៀវត្សដែលស្ថិតក្នុងចន្លោះពី ៨.៥០០.០០១ រៀល ដល់ ១២.៥០០.០០០ = ៥៨៥.០០០រៀល ជាមួយអត្រាពន្ធ ១៥%។
- ពន្ធលើប្រាក់បៀវត្សគឺ (១០.៧៩៦.០០០រៀល × ១៥%) - ៥៨៥.០០០ = **១.១១៨.១០០រៀល**
- ពន្ធលើអត្ថប្រយោជន៍បន្ថែម (៤.០៥៥.០០០រៀល × ២០%) = **៨១១.០០០រៀល**

**សម្គាល់៖** ប្រាក់បេឡាសោធនមិនត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែមទេ ព្រោះប្រាក់សោធនដែលផ្តល់ឱ្យមានចំនួនតែ ១០០ដុល្លារប៉ុណ្ណោះ គឺវាតិចជាង ១០% នៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែរបស់លោក សែ ម៉ុន ដែលស្ថិតក្រោមការកំណត់អត្ថប្រយោជន៍បន្ថែមជាប់ពន្ធ។ លើសពីនេះទៀត ប្រាក់សំណងនៃចំណាយអាជីវកម្មមិនជាប់ពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែមទេ។

**ឧទាហរណ៍៣៖** អ្នកស្រី **ដាវិន** ជានិវាសនជនកម្ពុជា ធ្វើការនៅភ្នាក់ងារផ្សាយពាណិជ្ជកម្មដែលជាក្រុមហ៊ុនចុះបញ្ជីនៅកម្ពុជា ប្រតិបត្តិការអាជីវកម្មខាងផ្នែកទីផ្សារ និងផ្សព្វផ្សាយនៅលើប្រព័ន្ធអ៊ីនធឺណិត។ ប្តីរបស់អ្នកស្រីបានស្លាប់ តែគាត់មានកូនប្រុសម្នាក់អាយុ៦ឆ្នាំ។ ក្នុងខែមេសា ឆ្នាំ ២០១៩ អ្នកស្រីទទួលបានទូទាត់ដូចខាងក្រោម៖

- ប្រាក់បៀវត្សមូលដ្ឋាន ២.៥០០ដុល្លារ
- ការទូទាត់បុព្វលាភសម្រាប់ឱកាសបុណ្យចូលឆ្នាំខ្មែរ ១.០០០ដុល្លារ
- ថ្នាក់បណ្ដុះបណ្ដាលជំនាញ IT ដែលចាំបាច់ចំពោះតួនាទីរបស់អ្នកស្រី។ ការបណ្ដុះបណ្ដាលនេះមានតម្លៃ ១០០ដុល្លារ
- ប្រាក់ធានារ៉ាប់រង ១០០ដុល្លារ ដែលផ្ដល់ជូនទៅបុគ្គលិកនៅគ្រប់កម្រិតទាំងអស់នៅភ្នាក់ងារផ្សាយពាណិជ្ជកម្ម

*ចូរគណនាពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែមរបស់អ្នកស្រី ដារិន ក្នុងខែមេសា ឆ្នាំ២០១៩ ជារៀល ជាមួយអត្រាប្ដូរប្រាក់ផ្លូវការ ១ដុល្លារ ស្មើនឹង ៤,០៥៥រៀល។*

**ចម្លើយ៖**

- ប្រាក់បៀវត្សប្រចាំខែមេសារបស់អ្នកស្រីដារិនសរុបគឺ ៣.៥០០ដុល្លារ (ប្រាក់បៀវត្សមូលដ្ឋាន ២.៥០០ដុល្លារ + ប្រាក់បុព្វលាភ ១.០០០ដុល្លារ) ឬ១៤,១៩២,៥០០រៀល។ បន្ទាប់ពីកាត់បន្ថយ ១៥០,០០០រៀល លើកូនក្នុងបន្ទុកម្នាក់ មូលដ្ឋានជាប់ពន្ធប្រាក់បៀវត្សរបស់គាត់គឺ ១៤,០៤២,៥០០រៀល។
- លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់សម្រាប់ប្រាក់បៀវត្សចាប់ពី ១២.៥០០.០០១រៀលឡើងទៅស្មើនឹង ១.២១០.០០០រៀល ជាមួយអត្រាពន្ធ ២០%។
- គាត់មិនទទួលបានអត្ថប្រយោជន៍បន្ថែមជាប់ពន្ធក្នុងខែនេះទេ។
- ពន្ធលើប្រាក់បៀវត្សគឺ(១៤,០៤២,៥០០រៀល × ២០%) - ១.២១០.០០០ = **១.៥៩៨.៥០០រៀល**

**សម្គាល់៖** ការបណ្ដុះបណ្ដាលដែលអ្នកស្រីទទួលបានគឺចាំបាច់ចំពោះការងាររបស់គាត់ ដូច្នេះត្រូវរួចពន្ធលើអត្ថប្រយោជន៍បន្ថែម។ ធានារ៉ាប់រងដែលផ្ដល់ជូនក៏រួចពន្ធដែរ ពីព្រោះធានារ៉ាប់រងនេះផ្ដល់ជូនទៅបុគ្គលិកទាំងអស់ស្មើៗគ្នា។

## ៣.២. ឥណទានពន្ធបរទេស

### ច្បាប់សារពើពន្ធ/ជំពូកទី២/ផ្នែកទី៣/មាត្រា៥០

អ្នកជាប់ពន្ធនិវាសនជនដែលបានទទួលប្រាក់បៀវត្សប្រភពបរទេស និងបានបង់ពន្ធតាមច្បាប់ពន្ធដារបរទេស អាចទទួលបានឥណទានពន្ធក្នុងព្រះរាជាណាចក្រកម្ពុជា លុះត្រាណាតែមានការបង្ហាញឯកសារ ដែលត្រូវផ្ដល់ទៅអគ្គនាយកដ្ឋានពន្ធដារ (អពដ) ដូចមានចែងក្នុងផ្នែកទី៤.២ នៃប្រកាសរបស់ អពដ ដូចខាងក្រោម៖

i. ត្រូវផ្ដល់កិច្ចសន្យាបម្រើការងារ ឬសេចក្ដីបញ្ជាក់ការងារដែលមានរៀបរាប់លម្អិតអំពីការងារ កាលបរិច្ឆេទ ចំនួនប្រាក់បៀវត្សបានទូទាត់សម្រាប់ការងារនៅក្រៅប្រទេស

ii. ច្បាប់ចម្លងនៃទម្រង់ឯកសារ ដែលនិយោជកបានដាក់ទៅជូនរដ្ឋបាលសារពើពន្ធប្រទេសក្រៅនោះដើម្បីបង់ប្រាក់ពន្ធ

iii. បង្កាន់ដៃទទួលប្រាក់ពន្ធបរទេសដែលរដ្ឋបាលសារពើពន្ធបរទេសបានចេញឱ្យ។

ក្រៅពីនេះ ប្រសិនឯកសារខាងលើដែលផ្តល់ដោយនិយោជកបរទេស ជាភាសាផ្សេងទៀត ក្រៅពី ភាសាខ្មែរ អង់គ្លេស ឬបារាំង ត្រូវភ្ជាប់មកជាមួយនូវឯកសារសេចក្តីបកប្រែ ដែលមានបញ្ជាក់ទទួលស្គាល់ត្រឹមត្រូវ។

**៣.២.១. ការគណនាឥណទានពន្ធបរទេស**

**ឯកសារគតិយុត្តៈ ចសព មាត្រា៤៧/ប្រកាស ពបវ ផ្នែកទី៤.១**

ក. ដើម្បីគណនាប្រាក់ពន្ធដែលត្រូវបង់ នៅព្រះរាជាណាចក្រកម្ពុជា មុនពេលកាត់ឥណទានពន្ធនេះ គឺត្រូវយកចំនួនសរុបនៃប្រាក់បៀវត្សដែលបានទទួលតាមប្រភពកម្ពុជា និងប្រាក់បៀវត្សដែលបានទទួលតាមប្រភពបរទេសមកគិត។

ខ. ឥណទានពន្ធត្រូវបានកំណត់ដាច់ដោយឡែកពីគ្នា សម្រាប់ប្រាក់ពន្ធដែលបានបង់ដោយនិវាសនជនកម្ពុជានៅប្រទេសក្រៅនីមួយៗ។ ផ្នែកទី៤.១ នៃប្រកាស ពបវ បង្ហាញពីការសុំឥណទានពន្ធបរទេស គឺត្រូវកម្រិតយកចំនួនដែលតិចជាងរវាង៖

i. ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅនោះ ឬ

ii. ចំនួនដែលបានមកពីការដែលយកប្រាក់ពន្ធលើប្រាក់បៀវត្សសរុប ពីគ្រប់ប្រភពក្នុងរយៈពេលជាមួយគ្នា ដែលគណនាតាមអត្រាកំណើនតាមថ្នាក់ដែលអនុវត្តចំពោះប្រាក់បៀវត្សនិវាសនជនកម្ពុជា ទៅគុណនឹងផលចែករវាងប្រាក់បៀវត្សដែលទទួលបាននៅក្រៅប្រទេសនោះ និងប្រាក់បៀវត្សសរុបពីគ្រប់ប្រភព។

**រូបមន្តៈ**

ចំនួនទឹកប្រាក់នៅចំណុចទី ii អាចបង្ហាញដូចរូបមន្តខាងក្រោម៖

**[ចំនួនពបវលើប្រាក់បៀវត្សសរុប] x [ប្រាក់បៀវត្សទទួលបានពីប្រទេសក្រៅ / ចំនួនប្រាក់បៀវត្សសរុប]**

**ដែល៖**

- ប្រាក់បៀវត្សសរុប = ប្រាក់បៀវត្សទទួលបានក្នុងកម្ពុជា + ប្រាក់បៀវត្សទទួលបានពីប្រទេសក្រៅ
- ចំនួន **ពបវ** (ពន្ធលើប្រាក់បៀវត្ស) លើប្រាក់បៀវត្សសរុប ត្រូវគណនាដោយប្រើអត្រាកំណើន 0% ទៅ២០% ដូចដែលអនុវត្តជាទូទៅលើប្រាក់បៀវត្សសម្រាប់និវាសនជនកម្ពុជា ដូចដែលមាន

ចែងក្នុងសេចក្ដីណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារលេខ០០២សហវ-អពដ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ ដោយអនុលោមតាមមាត្រា៩៧ថ្មី (ពីរ) នៃច្បាប់ស្ដីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧។

**ឧទាហរណ៍៖** លោក **ហិន រី** គឺជាពលរដ្ឋបារាំង ដែលបំពេញការងារឱ្យក្រុមហ៊ុនសាជីវកម្មមួយនៅក្នុងប្រទេសកម្ពុជាក្នុងរយៈពេល២ឆ្នាំ។ **ប្រាក់បៀវត្សរ៍ដុលរបស់គាត់**គឺ ១.០០០ដុល្លារ។ នៅក្នុងខែមករា ឆ្នាំ២០១៨ គាត់ត្រូវបានចាត់តាំងឱ្យទៅធ្វើការនៅក្រុមហ៊ុនបុត្រសម្ព័ន្ធមួយនៅប្រទេសថៃ។ គាត់បានទទួល**ប្រាក់បៀវត្សរ៍ដុលចំនួន ២.០០០ដុល្លារ** សម្រាប់បេសកកម្មនៅក្នុងប្រទេសថៃ ហើយក្រុមហ៊ុនបុត្រសម្ព័ន្ធនោះបានកាត់ប្រាក់ពន្ធចំនួន៥០០ដុល្លារ។

ដើម្បីកំណត់ពីឥណទានពន្ធបរទេសដែលអនុញ្ញាឱ្យកាត់កងបាន យើងត្រូវប្រៀបធៀបចំនួនទាំងពីរដែលបានកំណត់ខាងលើ។

- **ចំនួនទឹកប្រាក់ទី១** គឺពន្ធដែលត្រូវបង់ទៅក្រៅប្រទេស/បរទេស (ប្រទេសថៃ) ដែលមានចំនួន៥០០ដុល្លារ ឬ២.០០០.០០០រៀល (អត្រាប្ដូរប្រាក់ផ្លូវការ ១USD = ៤.០០០រៀល)។
- **ចំនួនទឹកប្រាក់ទីពីរ** គឺត្រូវគណនាដូចខាងក្រោម៖
  - ចំនួនប្រាក់បៀវត្សរ៍ដុលសរុបគឺ ៣.០០០ដុល្លារ (២.០០០ដុល្លា + ១.០០០ដុល្លា) ឬ ១២.០០០.០០០រៀល
  - អនុភាគ (ផលចែក) នៃប្រាក់បៀវត្សរ៍ ដែលទទួលបាននៅក្នុងប្រទេសថៃ នឹងប្រាក់បៀវត្សរ៍សរុបគឺ (២០០០ដុល្លារ / ៣០០០ដុល្លារ) = ២/៣
  - ពន្ធលើប្រាក់បៀវត្សរ៍សរុបគ្រប់ប្រភេទតាមប្រកាសអពដកម្ពុជា៖ [១២.០០០.០០០ x ១៥%] - ៥៨៥.០០០ = ១.២១៥.០០០រៀល
  - ចំនួនទឹកប្រាក់ទីពីរគឺ ២/៣ × ១.២១៥.០០០ = **៨១០.០០០រៀល**
  - ដូចនេះ ឥណទានពន្ធបរទេស ដែលអាចអះអាង ឬទាមទារយកបាន មានចំនួន **៨១០.០០០រៀល** ដែលចំនួននេះតិចជាងក្នុងចំណោមចំនួនទាំងពីរខាងលើ។

**កំណត់សម្គាល់ក្នុងការអនុវត្ត៖** នៅក្នុងការអនុវត្ត លំនាំនៃការគណនាឥណទានពន្ធបរទេស គឺមានភាពស្មុគស្មាញជាង ព្រោះនាពេលបច្ចុប្បន្នពុំមានទម្រង់ ឬគម្រូណាមួយសម្រាប់ការប្រកាសប្រាក់ចំណូល ដែលរកបាននៅក្រៅប្រទេសកម្ពុជាឡើយ។ ដូច្នេះហើយការគណនាត្រូវ គណនា ឬគិតទៅតាមករណីជាក់ស្ដែងនីមួយៗ៕

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម មានសារៈសំខាន់ក្នុងការជួយបង្កើនចំនូលថវិកាជាតិ និងចូលរួមចំណែកកាត់បន្ថយឱនភាពថវិកា ដែលកម្ពុជាកំពុងជួបប្រទះ នាពេលបច្ចុប្បន្ន។ ការប្រមូលពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម គឺជាមធ្យោបាយប្រមូលប្រាក់ពន្ធមួយរបស់រាជរដ្ឋាភិបាល ដែលតម្រូវឱ្យនិយោជិតបង់ពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ដែលខ្លួនទទួលបានប្រចាំខែទៅតាមកំណត់របស់អគ្គនាយកដ្ឋានពន្ធដារ ហើយនិយោជកមានតួនាទីជាអ្នករៀបចំកាត់ទុកពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម និងបង់ជូនរដ្ឋបាលសារពើពន្ធ យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ ក្រោយពីបានទូទាត់ប្រាក់បៀវត្ស និងប្រាក់អត្ថប្រយោជន៍បន្ថែមដល់និយោជិតរបស់ខ្លួនរួចរាល់ហើយ។

ក្នុងគោលបំណងជួយសម្រាលបន្ទុកចំណាយប្រចាំថ្ងៃរបស់មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ កម្មករនិយោជិត ចាប់តាំងពី ខែមករា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលចេញប្រកាសដាក់ឱ្យអនុវត្តការបើកប្រាក់បៀវត្ស០២ដងក្នុងមួយខែ ក៏ប៉ុន្តែមិនមានផលប៉ះពាល់ដល់ការប្រមូលពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែមទេ ដោយសារការបើកប្រាក់ខែលើកទី១ ធ្វើឡើងនៅក្នុងរង្វង់ថ្ងៃទី១៥ នៃខែនីមួយៗ ហើយចំនួនប្រាក់ដែលបានបើកស្មើនឹង ៥0% (ហាសិបភាគរយ) នៃប្រាក់ខែដុលរបស់និយោជិត ដែលត្រូវបានកំណត់ថាជាប្រាក់បៀវត្សបុរេប្រទាន (Salary Advance)។ នៅរៀងរាល់ចុងខែ ជាពេលកំណត់បើកប្រាក់បៀវត្សលើកទី២ ទើបនិយោជករៀបចំធ្វើប្រាក់បៀវត្សដុលបូករួមជាមួយប្រាក់អត្ថប្រយោជន៍បន្ថែមផ្សេងៗទៀត ហើយដកពន្ធកាត់ទុក និងដកប្រាក់បៀវត្សបុរេប្រទានចេញ នៅសល់ប៉ុន្មានទើបទូទាត់ឱ្យនិយោជិតជាលើកទី២។ ដូច្នេះការបើកប្រាក់បៀវត្ស០២ដងក្នុងមួយខែ មិនធ្វើឱ្យចំណេញ ឬមួយខាតបង់ចំនូលពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែមឡើយ។

ប្រាក់ដែលប្រមូលបានពីពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម គឺជាប្រភពចំណូលដ៏ធំមួយរបស់ជាតិ ដែលអាចយកទៅប្រើប្រាស់ដើម្បីបម្រើដល់ផលប្រយោជន៍សាធារណៈ ក៏ដូចជាដើម្បីអភិវឌ្ឍន៍ប្រទេសជាតិឱ្យបានរីកចម្រើនលូតលាស់ទៅមុខ។

ទោះជាមើលឃើញពីសារប្រយោជន៍របស់ពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ក៏រដ្ឋបាលសារពើពន្ធមិនអាចប្រមូលប្រាក់ពន្ធអោយបាន១០០%នៅឡើយទេ ដោយសារតែការយល់ដឹងពីកាតព្វកិច្ចរបស់បុគ្គលជាប់ពន្ធនៅកម្ពុជានៅមានកម្រិត។ ម្យ៉ាងទៀតបុគ្គលជាប់ពន្ធមួយចំនួននៅរក្សាគំនិតបង្វៀងពន្ធ ឬ/និង គេចវេសពន្ធ តាមដែលខ្លួនអាចធ្វើទៅបាន។

និយោជកមួយចំនួនមិនបានប្រកាសចំនួននិយោជិតពិតប្រាកដដែលខ្លួនបានទទួលឱ្យចូលបម្រើការងារ ដូច្នេះពួកគេអាចកេងយកប្រាក់ពន្ធនោះទុកជាប្រយោជន៍ខ្លួនឯង។

ដោយសារប្រាក់បៀវត្សនៅកម្ពុជាទាបជាងប្រាក់បៀវត្សនៅប្រទេសដទៃ ហេតុដូច្នេះប្រាក់ពន្ធដែលប្រមូលបានមានប្រហែលជា ២០% នៃប្រាក់ពន្ធសរុប បើប្រៀបធៀបនឹងប្រទេសដទៃគឺមានគម្លាតពីគ្នាឆ្ងាយណាស់។

ការស្រាវជ្រាវក៏បានរកឃើញផងដែរថា បញ្ហាចំណាកស្រុកនៅកម្ពុជា ក៏ជាមូលហេតុមួយដែលធ្វើឱ្យបាត់បង់ចំណូលពីពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ដោយសារតែប្រាក់បៀវត្សដែលពលរដ្ឋចំណាកស្រុកទទួលបានមានប្រភពបរទេស ព្រមទាំងធ្វើការនៅស្រុកគេ ហេតុដូច្នេះមិនជាប់កាតព្វកិច្ចបង់ពន្ធនៅកម្ពុជាឡើយ។

ដើម្បីពង្រឹងការប្រមូលពន្ធ អគ្គនាយកដ្ឋានពន្ធដារ បានធ្វើកំណែទម្រង់ប្រព័ន្ធពន្ធដារនៅកម្ពុជា និងព្យាយាមអនុវត្តយ៉ាងម៉ឺងម៉ាត់តាមច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិដ៏ទៃទៀតដែលរាជរដ្ឋាភិបាលដាក់ឱ្យ ជាមួយនេះផងដែរ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងធ្វើទំនើបកម្មប្រព័ន្ធទិន្នន័យពន្ធដាររបស់ខ្លួនតាមបែបឌីជីថល ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកបង់ពន្ធនានា ក៏ដូចជាបញ្ជ្រាបពីកាតព្វកិច្ចរបស់បុគ្គលជាប់ពន្ធឱ្យបានទូលំទូលាយ ដើម្បីសម្រេចគោលដៅកំណើនប្រាក់ពន្ធ និងសមភាពកាតព្វកិច្ចពន្ធតាមនិយាមអន្តរជាតិ៕

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការស្រាវជ្រាវដោយយកចិត្តទុកដាក់ ទៅលើការអនុវត្តការប្រមូលពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែមរួចមក យើងបានឃើញពីសារសំខាន់នៃពន្ធទាំងពីរប្រភេទខាងលើ ក្នុងការចូលរួមចំណែកអភិវឌ្ឍកម្ពុជា។

ទោះបីជាមើលឃើញពីសារៈប្រយោជន៍របស់ពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ក៏រដ្ឋបាលសារពើពន្ធមិនទាន់អាចប្រមូលប្រាក់ពន្ធឱ្យបាន ១០០% នៅឡើយ។ ហេតុដូច្នេះអគ្គនាយកដ្ឋានពន្ធដារ គួររៀបចំពង្រឹងការងារប្រមូលពន្ធដូចតទៅៈ

- ពង្រឹងការដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ ពិសេស លិខិតប្រកាសបង់ពន្ធលើប្រាក់បៀវត្ស ព្រមទាំងពន្ធលើអត្ថប្រយោជន៍បន្ថែម លិខិតប្រកាសបង់ពន្ធលើប្រាក់ចំណេញជាដើម។ល។
- រៀបចំលិខិបទដ្ឋានគតិយុត្តចាំបាច់នានា សម្រាប់ពង្រឹងការអនុវត្តឥណទានពន្ធបរទេស
- ពង្រឹងការផ្តល់សេវា ជូនអ្នកជាប់ពន្ធ តាមរយៈការដាក់ផែនការ រៀបចំសិក្ខាសាលា សម្រាប់ឆ្នាំបន្ទាប់។ ពង្រឹងការឆ្លើយតបឱ្យបានឆាប់រហ័សជូនអ្នកជាប់ពន្ធ ចំពោះបញ្ហាដែលបានលើកឡើង ព្រមទាំងជំរុញ និងពង្រឹងការប្រើប្រាស់ភ្នាក់ងារសេវាកម្មពន្ធដារ
- ពង្រឹងការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស តាមរយៈយន្តការចុះបញ្ជីជាឯកតោភាគី និងបន្តជំរុញសហគ្រាសដែលពុំទាន់បានមកធ្វើបច្ចុប្បន្នភាពព័ត៌មាន ឬចុះបញ្ជីក្នុងប្រព័ន្ធចាស់ ឱ្យមកធ្វើបច្ចុប្បន្នភាពបានគ្រប់ៗសហគ្រាស និងបន្តអនុវត្តន៍វិធានការច្បាប់ ចំពោះសហគ្រាសដែលមិនព្រមអនុវត្តន៍ច្បាប់
- ព្រមជាមួយនេះ បន្តលើកកម្ពស់ និងបញ្ជ្រាប នូវវប្បធម៌នៃការបង់ពន្ធ ឱ្យបានកាន់តែច្រើនថែមទៀត ជាពិសេសការអនុវត្តច្បាប់ស្តីពីសារពើពន្ធ នៅក្នុងចំណោមធុរជនគ្រប់មជ្ឈដ្ឋាន តាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីប្រព័ន្ធពន្ធដារកម្ពុជា
- បន្តនីតិវិធី នៃការចុះអង្កេតស្រាវជ្រាវ សហគ្រាសតាមដងផ្លូវ (Street Survey) ដើម្បីឱ្យសហគ្រាសដែលមិនបានចុះបញ្ជីត្រឹមត្រូវ ឬលាក់ខ្លួនមិនព្រមមកចុះបញ្ជីពន្ធដារ នៅក្នុងខណ្ឌនានា នៃរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ឱ្យមកចុះបញ្ជីពន្ធដារគ្រប់ៗគ្នា
- បន្តពង្រឹងការធ្វើសវនកម្មលើសហគ្រាស ដែលមានហានិភ័យខ្ពស់ ដែលព្យាយាមគេចវេសកាតព្វកិច្ចបង់ពន្ធតាមគ្រប់រូបភាព
- បន្តធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា ជាពិសេស រៀបចំអភិវឌ្ឍកម្មវិធី ការប្រមូលពន្ធគ្រប់ប្រភេទ តាមបច្ចេកវិទ្យាព័ត៌មាន

- បន្តអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវយុទ្ធសាស្ត្រគៀរគរចំណូល រយៈពេលមធ្យម របស់រាជរដ្ឋាភិបាល និងកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ
- ពង្រឹងអភិបាលកិច្ចល្អ របស់រដ្ឋបាលសារពើពន្ធ តាមរយៈការធ្វើកំណែទម្រង់ រចនាសម្ព័ន្ធការងារ និងប្រព័ន្ធការងារ ការពង្រឹងមុខងារ ភារកិច្ច របស់អង្គភាពក្រោមឱវាទទាំងអស់ ដើម្បីរៀបចំក្របខ័ណ្ឌប្រព័ន្ធការងារមួយ ដែលមានលក្ខណៈស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និងជួយជំរុញបង្កើនប្រសិទ្ធភាព និងផលិតភាពការងាររបស់អគ្គនាយកដ្ឋានពន្ធដារ
- បន្តអប់រំណែនាំ ពង្រឹងការអនុវត្តច្បាប់ និងសមត្ថភាពមន្ត្រីពន្ធដារគ្រប់លំដាប់ថ្នាក់ ពង្រឹងអភិបាលកិច្ចល្អ របស់រដ្ឋបាលសារពើពន្ធ ជាពិសេស ការកែប្រែផ្នត់គំនិត (Mindset) របស់មន្ត្រីរាជការពន្ធដារគ្រប់រូប ឱ្យយកចិត្តទុកដាក់អនុវត្តន៍ការងារ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ដោយឈរលើមនសិការវិជ្ជាជីវៈ និងស្មារតីតម្កល់ផលប្រយោជន៍ជាតិ ជាចម្បង ដោយចូលរួមអនុវត្តព្រមៗគ្នា នូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សំដៅធ្វើយ៉ាងណាធានាបាននូវប្រសិទ្ធភាព នៃការប្រមូលចំណូលពន្ធ ដោយផ្អែកលើអភិក្រម «**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល និង ព្យាបាលជំងឺ**» ដែលបានដាក់ចេញដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា៕

# ឯកសារពិគ្រោះ

# ឯកសារពិគ្រោះ


## ក. លិខិតបទដ្ឋានគតិយុត្ត

១. ច្បាប់សារពើពន្ធកម្ពុជា

២. ប្រកាសលេខ ៨៩៦ សហវ ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៦

៣. សេចក្តីណែនាំលេខ០០២ សហវ-អពដ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨

៤. សេចក្តីណែនាំលេខ០១៧ សហវ-អពដ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦

៥. សេចក្តីណែនាំលេខ០០២ សហវ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥

៦. ប្រកាសលេខ ១១៧៣ សហវ.ពដ.ប្រក. ស្តីពីពន្ធលើប្រាក់បៀវត្ស ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣

៨. សារាចរណែនាំលេខ០០២ សហវ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥

៩. ប្រកាសលេខ ៤៤២ កប/ប្រកខល ស្តីពីការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ចំនួនពីរដង ក្នុងមួយខែ ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១៨

## ខ. សៀវភៅ

១. **ទេព សុខ** នីតិថវិកា និងពន្ធដា ឆ្នាំ២០១៩ ភ្នំពេញ

២. **ថន សុខុម** សារពើពន្ធ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤ ភ្នំពេញ

៣. VDB Loi Cambodia សារពើពន្ធកម្ពុជា ឆ្នាំ២០១៤ ភ្នំពេញ

៤. **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** សៀវភៅណែនាំស្តីពីពន្ធលើប្រាក់បៀវត្ស ឆ្នាំ២០១៣ ភ្នំពេញ

## គ. គេហទំព័រ

១. http://tax.gov.kh/aboutus.php (25 April 2019)

២. http://mef.gov.kh/laws-and-regulation.html (25 April 2019)

៣. http://www.mlvt.gov.kh (25 April 2019)

# ឧបសម្ព័ន្ធ

# តារាងឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១

១ ច្បាប់សារពើពន្ធកម្ពុជា (ជំពូកទី២ ចាប់ពីមាត្រា៨០ ដល់មាត្រា៥៨)

## ឧបសម្ព័ន្ធ២

២ ប្រកាសលេខ ៨៩៦ សហវ ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៦

៣ វិញ្ញាបនបត្រ ចុះបញ្ជីពន្ធដារលើតម្លៃអាករបន្ថែម

៤ ប័ណ្ណពន្ធប៉ាតង់ប្រចាំឆ្នាំ

៥ កាតសម្គាល់លេខអត្តសញ្ញាណ អាករលើតម្លៃបន្ថែម

## ឧបសម្ព័ន្ធ៣

៦ សេចក្តីណែនាំលេខ០០២ សហវ-អពដ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨

៧ សេចក្តីណែនាំលេខ០១៧ សហវ-អពដ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦

៨ ប្រកាសលេខ ១១៧៣ សហវ.ពដ.ប្រក. ស្តីពីពន្ធលើប្រាក់បៀវត្ស ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៣

៩ សារាចរណែនាំលេខ០០២ សហវ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥

១០ សេចក្តីណែនាំលេខ០០២ សហវ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥

១១ លិខិតប្រកាសពន្ធ បពវ០១

១២ អាត្រាប្តូរប្រាក់ផ្លូវការ ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ

១៣ ប្រកាសលេខ ៨៤២ កប/ប្រកខល ស្តីពីការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ចំនួនពីរដង ក្នុងមួយខែ ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១៨

# ឧបសម្ព័ន្ធ១

# ច្បាប់

# ស្តីពី

# សារពើពន្ធ

ព្រះមហាក្សត្រ/រដ្ឋសភា

ព្រះរាជក្រម/ច្បាប់/នស.រកម.០២៩៧.០៣/២៤ កុម្ភៈ ១៩៩៧/ស្តីពីសារពើពន្ធ

# យើង

# ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

# រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

# និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

# ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២

- បានឃើញ ព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ ព្រះរាជក្រមលេខ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញ ព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ ព្រះរាជក្រមលេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីទេសរដ្ឋមន្ត្រីទទួលបន្ទុកទីតិសម្បទានិងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# ប្រកាសអោយប្រើ

៣- ប្រសិនបើបំណុលពន្ធលើប្រាក់ចំណេញតិចជាងបំណុលពន្ធអប្បបរមា :

ក- ឥណទានពន្ធរបស់អ្នកជាប់ពន្ធតាមកថាខ័ណ្ឌ២ មាត្រា៣៨នៃច្បាប់នេះ ត្រូវបានកាត់បន្ថយដោយទឹកប្រាក់លំអៀងខាងលើ

ខ- ឥណទានពន្ធដែលបានកាត់បន្ថយចុះក្នុងការអនុវត្តតាមវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌនេះ ត្រូវចាត់ជាការទូទាត់ប្រាក់ពន្ធអប្បបរមាសំរាប់ឆ្នាំជាប់ពន្ធ ។

## ជំពូកទី ២

## បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស

### ផ្នែកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា៤០:** បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស ដូចមានចែងក្នុង ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស.៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៤ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ ។

**មាត្រា៤១:** ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្សដែលបានទទួលក្របខ័ណ្ឌនៃការបំពេញសកម្មភាពបំរើការងារ ។

រូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា និងប្រាក់បៀវត្សប្រភពបរទេស ។

រូបវន្តបុគ្គលអនិវាសនជន ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា ។

**មាត្រា៤២:** សំរាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស :

១- ពាក្យ "និវាសនជន" ក្នុងករណីដែលប្រើចំពោះនិយោជិត អ្នកជាប់ពន្ធ ឬរូបវន្តបុគ្គល មានន័យថាដែលស្នាក់នៅ ឬមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា លើសពី១៨២ថ្ងៃនៅក្នុងឆ្នាំប្រតិទិន ។

២- ពាក្យ "អនិវាសនជន" មានន័យថាដែលមិនមែនជានិវាសនជន ។

៣- វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយ ការប្រើពាក្យនិយោជិត អ្នកជាប់ពន្ធ និងរូបវន្តបុគ្គល គឺសំដៅដល់ទាំងនិវាសនជន និងអនិវាសនជន ដូចមានចែងក្នុងមាត្រានេះ ។

៤- ពាក្យ "និយោជក" រួមមានស្ថាប័នរដ្ឋ នីតិបុគ្គលនិវាសនជន ក្រុមអាជីវកម្មនិវាសនជន គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការមិនស្វែងរកចំណេញ ឬរូបវន្តបុគ្គលនិវាសនជនដែលប្រកបអាជីវកម្ម ។

៥- ពាក្យ "និយោជិត" សំដៅដល់រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្សអំពីសកម្មភាពបំរើការងាររបស់ខ្លួន រួមបញ្ចូលទាំងមន្ត្រីរាជការ មន្ត្រីជ្រើសតាំងដោយការបោះឆ្នោត និងអ្នកទទួលខុសត្រូវ ឬអភិបាលរបស់សហគ្រាសផង ។

៦- ពាក្យ "ប្រាក់បៀវត្សប្រភពកម្ពុជា" មានន័យថាប្រាក់បៀវត្សដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបំរើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដោយឡែកចំពោះប្រាក់បៀវត្ស ដែលអនិវាសនជនបានទទួលក្នុងការផ្តល់ជំនួយបច្ចេកទេស ត្រូវចាត់ទុកថាមានប្រភពនៅក្នុងប្រទេសដែល អ្នកទូទាត់ប្រាក់បៀវត្សនោះស្នាក់នៅ ។

៧- ពាក្យ "បរទេស" :

ក- ពេលណាប្រើជាមួយរូបវន្តបុគ្គល មានន័យថា ដែលជាអនិវាសនជន

ខ- ចំពោះការកំណត់ប្រភពប្រាក់ចំណូលមានន័យថា ក្រៅព្រះរាជាណាចក្រកម្ពុជា ។

៨- ពាក្យ "ប្រាក់បៀវត្ស" សំដៅដល់លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវ នានា និងអត្ថប្រយោជន៍បន្ថែម ដែលបានទូទាត់អោយដល់និយោជិត ឬដែលបានទូទាត់ ដើម្បី ជាប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិត ចំពោះការបំពេញសកម្មភាពបំរើការងារ ។

## ផ្នែកទី ២

## ប្រាក់បៀវត្សលើកលែងពន្ធ

**មាត្រា៤៣:** ការលើកលែងពន្ធលើប្រាក់បៀវត្សរបស់មន្ត្រីរាជការទូត និងមន្ត្រីបរទេសដទៃទៀតត្រូវបានកំណត់ដូចតទៅ :

១- ត្រូវបានលើកលែងពន្ធលើប្រាក់បៀវត្ស ចំពោះ :

ក- ប្រាក់បៀវត្សដែលមន្ត្រី និងនិយោជិតនៃបេសកកម្មទូត ឬកុងស៊ុលរបស់រដ្ឋាភិបាលបរទេសណាមួយ ដែលកាន់លិខិតឆ្លងដែនការទូត ឬផ្លូវការរបស់ប្រទេសនោះ បានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ខ- ប្រាក់បៀវត្សដែលតំណាងមន្ត្រី និងនិយោជិតបរទេសរបស់អង្គការអន្តរជាតិ និងរបស់ទីភ្នាក់ងារខាងសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលដទៃទៀត បានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- ការលើកលែងពន្ធក្នុងមាត្រានេះ ត្រូវឈរលើគោលការណ៍បដិការរវាងរដ្ឋាភិបាលដែលពាក់ព័ន្ធ ។

**មាត្រា៤៤:** ត្រូវបានលើកលែងពន្ធ :

១- ប្រាក់សំណងដោយពិតប្រាកដនូវចំណាយខាងវិជ្ជាជីវៈ ដែលបានចាយដោយនិយោជិតតាមសេចក្តី បង្គាប និងសំរាប់ជាប្រយោជន៍នៃនិយោជក ហើយដែលបានបំពេញល័ក្ខខ័ណ្ឌដូចតទៅ :

ក- បានចាយក្នុងផលប្រយោជន៍ផ្ទាល់ និងដាច់ខាតរបស់សហគ្រាស

ខ- មិនបង្ហាញលក្ខណៈហួសប្រមាណ ឬស្តុកស្តម្ភហួសហេតុ

គ- បានបង្ហាញជាភស្តុតាងដោយវិក្កយបត្ររាយលំអិត និងបានទូទាត់ស្រេចបាច់ ហើយដែលបានធ្វើក្នុងនាមអ្នកបានទទួលប្រាក់សំណងនូវចំណាយពិតប្រាកដ ។

២- ប្រាក់បំណាច់នៃការបញ្ឈប់លែងអោយធ្វើការក្នុងក៏រិតដែលបានបញ្ញត្តិក្នុង ច្បាប់ការងារ ។

៣- លាភការបន្ថែមមានលក្ខណៈខាងសង្គមកិច្ច ក្នុងករណីដែលបានបញ្ញត្តិក្នុងច្បាប់ការងារ ។

៤- ការផ្គត់ផ្គង់អោយដោយឥតយកថ្លៃ ឬយកថ្លៃទាបជាងថ្លៃដើមនូវឯកសណ្ឋាន ឬបរិក្ខារសំរាប់វិជ្ជាជីវៈពិសេស ។

៥- ប្រាក់បំណាច់ម៉ោការសំរាប់ចំណាយបេសកកម្ម និងការធ្វើដំណើរ ។ ប្រាក់បំណាច់នេះមិនត្រូវត្រួតគ្នាជាមួយប្រាក់សំណងពិតប្រាកដ នូវចំណាយដូចមានចែងក្នុងមាត្រានេះឡើយ ។

## ផ្នែកទី ៣

### មូលដ្ឋានគិតពន្ធប្រចាំខែ ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងការកំណត់ប្រាក់ពន្ធប្រចាំខែ

**មាត្រា៤៥:** វៀរលែងតែអត្ថប្រយោជន៍បន្ថែមដែលត្រូវកំណត់ពន្ធតាមមាត្រា៤៨នៃច្បាប់នេះ មូលដ្ឋានគិតពន្ធប្រចាំខែរបស់និវាសនជន គឺជាប្រាក់បៀវត្សជាប់ពន្ធដោយផាត់ចេញនូវ :

១- ប្រាក់កាត់ទុកដែលជាកាតព្វកិច្ចក្នុងការប្រតិបត្តិការតាមច្បាប់ការងារ ដើម្បីបង្កើតបេឡាសោធន និងធានាសុខុមាលភាពសង្គម ។

២- ការទូទាត់នានា ដែលត្រូវបានលើកលែងពន្ធដូចមានចែងក្នុងមាត្រា៤៤នៃច្បាប់នេះ ។

**មាត្រា៤៦:** ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ ត្រូវបានកំណត់ដូចតទៅ :

១- ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែរបស់និយោជិតនិវាសនជនរួមមាន:

ក- ប្រាក់បៀវត្សដែលបានទទួលពីប្រភពកម្ពុជា

ខ- ប្រាក់បៀវត្សដែលបានទទួលពីប្រភពបរទេស

គ- ប្រាក់បុរេប្រទាន ប្រាក់អោយខ្ចី ឬប្រាក់រំដោះដែលនិយោជកបានបើកអោយនិយោជិត ។ ប្រាក់បុរេប្រទាន ប្រាក់អោយខ្ចី ឬប្រាក់រំដោះត្រូវបូកបន្ថែមលើបៀវត្សជាប់ពន្ធនៃខែដែលប្រាក់ទាំងនោះបានបើក ហើយត្រូវកាត់បន្ថយពីប្រាក់បៀវត្សក្នុងខែដែលនិយោជិតបានបង់សងវិញ ។

២- ផ្អែកលើការបង្ហាញភស្តុតាងនៃស្ថានភាពគ្រួសារ និយោជិតនិវាសនជនណាមួយដែលមាន :

ក- កូនស្ថិតក្នុងបន្ទុកនាពេលដែលត្រូវបង់ពន្ធ ត្រូវបានទទួលការបន្ថយមូលដ្ឋានកំណត់ពន្ធចំនួន ៧៥.០០០ រៀល( ប្រាំពីរម៉ឺនប្រាំពាន់រៀល) ក្នុងកូនម្នាក់ៗក្នុងមួយខែ ។

ខ- សហព័ទ្ធដែលធ្វើការតែជាមេផ្ទះ ត្រូវបានទទួលនូវការបន្ថយមូលដ្ឋានកំណត់ពន្ធចំនួន ៧៥.០០០ រៀល ( ប្រាំពីរម៉ឺនប្រាំពាន់រៀល) សំរាប់តែម្នាក់ក្នុងមួយខែ ។

៣- ចំពោះអ្នកជាប់ពន្ធអនិវាសនជន ប្រាក់បៀវត្សជាប់ពន្ធរួមមានប្រាក់បៀវត្សប្រភពកម្ពុជា ដែលត្រូវជាប់ពន្ធតាមបទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះ ។

**មាត្រា៤៧:** សំរាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងត្រូវកាត់ទុកដោយនិយោជក តាមអត្រាកំណើនតាមថ្នាក់ដូចតទៅ :

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០៛ ០០ | ដល់ | ៥០០.០០០៛ ០០ | 0% |

| | | | | |
|---|---|---|---|---|
| ពី | ៥០០.០០១៛ ០០ | ដល់ | ១.២៥០.០០០៛ ០០ | ៥% |
| ពី | ១.២៥០.០០១៛ ០០ | ដល់ | ៨.៥០០.០០០៛ ០០ | ១០% |
| ពី | ៨.៥០០.០០១៛ ០០ | ដល់ | ១២.៥០០.០០០៛ ០០ | ១៥% |
| | | លើសពី | ១២.៥០០.០០០៛ ០០ | ២០% |

**មាត្រា៤៨:** ចំពោះអត្ថប្រយោជន៍បន្ថែម ជារៀងរាល់ខែនិយោជកត្រូវកាត់ទុក និងបង់ប្រាក់ពន្ធតាមកាលកំណត់ តាមអត្រា២០ភាគរយនៃតំលៃសរុបរបស់អត្ថប្រយោជន៍បន្ថែម ដែលបានផ្តល់អោយនិយោជិតទាំងអស់ ។ តំលៃនៃអត្ថប្រយោជន៍បន្ថែម គឺជាតំលៃទីផ្សាររួមទាំងពន្ធអាករទាំងអស់ ។

**មាត្រា៤៩:** វៀរលែងតែអត្ថប្រយោជន៍បន្ថែមដែលត្រូវកំណត់ពន្ធតាមមាត្រា៤៨នៃច្បាប់នេះ សំរាប់អ្នកជាប់ពន្ធអនិវាសនជន ប្រាក់ពន្ធត្រូវកាត់ទុកដោយអ្នកបើកប្រាក់អោយតាមអត្រា ១៥ ភាគរយលើរាល់ការទូទាត់ប្រាក់បៀវត្សជាប់ពន្ធដែលមានចែងក្នុងកថាខ័ណ្ឌ៣ មាត្រា៤៦នៃច្បាប់នេះ។ ពន្ធកាត់ទុកគឺជាពន្ធចុងក្រោយនៃពន្ធលើប្រាក់បៀវត្សសំរាប់អនិវាសនជនជាអ្នកទទួលប្រាក់បៀវត្ស ។

**មាត្រា៥០:** អ្នកជាប់ពន្ធនិវាសនជនដែលបានទទួលប្រាក់បៀវត្សប្រភពបរទេស និងបានបង់ពន្ធតាមច្បាប់ពន្ធដារបរទេស ត្រូវបានទទួលនូវឥណទានពន្ធសំរាប់កាត់កងពីប្រាក់ពន្ធលើប្រាក់បៀវត្ស ដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែលុះណាតែមានការបង្ហាញឯកសារបញ្ជាក់អំពីការបង់ពន្ធនៅបរទេសនោះ ។

ក- ដើម្បីគណនាប្រាក់ពន្ធដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា មុនពេលកាត់ឥណទានពន្ធនេះ ត្រូវយកចំនួនសរុបប្រាក់បៀវត្សដែលបានទទួលអំពីប្រភពកម្ពុជា និងប្រភពបរទេសមកគិត

ខ- ឥណទានពន្ធ ត្រូវបានកំណត់ដាច់ដោយឡែកពីគ្នា សំរាប់ប្រាក់ពន្ធដែលបានបង់ដោយនិវាសនជនកម្ពុជានៅប្រទេសក្រៅនីមួយៗ ។ ប៉ុន្តែឥណទានពន្ធផ្តល់អោយសំរាប់ពន្ធលើប្រាក់បៀវត្សដែលបានបង់នៅប្រទេសក្រៅ គឺជាចំនួនដែលទាបជាងគេក្នុងចំណោម :

- ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយ

- ចំនួនដែលបានមកពីការយកប្រាក់ពន្ធលើប្រាក់បៀវត្សសរុបពីគ្រប់ប្រភពក្នុងរយៈពេលជាមួយគ្នា ដែលគណនាតាមអត្រាកំណើនតាមថ្នាក់ក្នុងមាត្រា៤៧នៃច្បាប់នេះ ទៅគុណនឹងផលចែករវាងប្រាក់បៀវត្សដែលបានទទួលនៅប្រទេសក្រៅនោះ និងប្រាក់បៀវត្សសរុបពីគ្រប់ប្រភព ។

ការបង្វិលសងឥណទានពន្ធបរទេសអាចធ្វើទៅបាន លុះណាតែអ្នកជាប់ពន្ធនិវាសនជនបានបំពេញបែបបទព្រមទាំងផ្តល់ឯកសារនានាកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេសសេចក្តីបញ្ជាក់របស់និយោជកនិងរដ្ឋបាលសារពើពន្ធនៃទីកន្លែងបំរើការងារនៅឯបរទេស ។

## ផ្នែកទី ៤

### កាតព្វកិច្ចរបស់និយោជក និងនិយោជិត

**មាត្រា៥១:** ការបើកបៀវត្ស បង្កើតជាហេតុបណ្តាលអោយជាប់ពន្ធ ។

**មាត្រា៥២:** បំណុលពន្ធ និងកាតព្វកិច្ចកាត់ទុកប្រាក់ពន្ធត្រូវបានកំណត់ដូចតទៅ:

១- ពន្ធនេះ គឺជាបំណុលរបស់រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្ស រួមទាំងរូបវន្តបុគ្គលបរទេសផងវៀរលែងតែមានបទប្បញ្ញត្តិផ្ទុយដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ។

២- ពន្ធលើប្រាក់បៀវត្សត្រូវប្រមូលតាមរបៀបកាត់ទុកជាមុនជារៀងរាល់ខែ ដោយនិយោជកនៅរាល់ពេលបើកប្រាក់បៀវត្ស ។

៣- ប្រសិនបើនិយោជកស្នាក់នៅបរទេស តំណាងសារពើពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនិយោជកបានចាត់តាំង គឺជាអ្នកទទួលភារៈកាត់ទុកពន្ធលើប្រាក់បៀវត្សមុនពេលបើកប្រាក់បៀវត្សទៅអោយនិយោជិត និងបង្វែរប្រាក់ពន្ធទាំងនោះជូនរដ្ឋ ។

៤- និយោជក ឬតំណាងនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់និយោជកបរទេស ហើយនិងនិយោជិតត្រូវទទួលខុសត្រូវរួមគ្នាក្នុងការបង់ពន្ធលើប្រាក់បៀវត្សក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពុំកំណត់ថាប្រាក់បៀវត្សបានបើកអោយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេសឡើយ ។ ក្នុងករណីមិនបានកាត់ទុកប្រាក់ពន្ធលើប្រាក់បៀវត្ស និយោជកត្រូវទទួលខុសត្រូវចំពោះច្បាប់នេះ ទោះបីជាប្រាក់ពន្ធត្រូវបានបង់ដោយនិយោជិតរួចហើយក្តី ។

**មាត្រា៥៣:** ប្រាក់ពន្ធកាត់ទុកដែលទាក់ទងដល់ការបើកប្រាក់បៀវត្សធ្វើឡើងក្នុងខែណាមួយ ត្រូវបង់យ៉ាងយឺតបំផុតនៅថ្ងៃទី១៥ នៃខែបន្ទាប់ ជូនទៅរដ្ឋបាលសារពើពន្ធនៅទីកន្លែងនៃលំនៅដ្ឋាន ឬគ្រឹះស្ថានជាគោលដើមនៃអ្នកទទួលភារៈកាត់ទុកប្រាក់ពន្ធនេះ ។

**មាត្រា៥៤:** គ្រប់និយោជកដែលបើកប្រាក់បៀវត្សត្រូវជាប់ពន្ធ ត្រូវទទួលបំពេញភារកិច្ចៈ

១- កាត់ទុកប្រាក់ពន្ធមុនពេលបើកបៀវត្ស ។

២- រាយការណ៍ជូនរដ្ឋបាលសារពើពន្ធ និងនិយោជិត អំពីស្ថានភាពប្រាក់ពន្ធដែលបានកាត់ទុក ។

៣- កាន់កាប់ និងថែរក្សាបញ្ជីការដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៣

### បទប្បញ្ញត្តិស្តីពីអាករលើតំលៃបន្ថែម

## ផ្នែកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា៥៥:** ចាប់តាំងពីថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៨ តទៅ នឹងត្រូវបានបង្កើតអាករលើតំលៃបន្ថែមចំពោះការផ្គត់ផ្គង់ជាប់អាករ ដើម្បីជាប្រយោជន៍ដល់ថវិការដ្ឋ ។

**មាត្រា៥៦:** សំរាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីអាករលើតំលៃបន្ថែម :

១- ពាក្យ "ទំនិញ" សំដៅដល់ទ្រព្យរូបី ក្រៅពីដីធ្លី និងប្រាក់កាស ។

២- ពាក្យ "សេវា" សំដៅដល់ការផ្តល់អ្វីមួយដែលមានតំលៃក្រៅពីទំនិញ ដីធ្លី និងប្រាក់កាស ។

៣- ពាក្យ "ការផ្គត់ផ្គង់ទំនិញ" សំដៅដល់ការផ្ទេរសិទ្ធិប្រើប្រាស់ ឬសិទ្ធិចាត់ចែងក្នុងឋានៈជាម្ចាស់កម្មសិទ្ធិទំនិញ ទោះបីមានសំណង ឬគ្មានសំណងក្តី ។ ការផ្គត់ផ្គង់សេវាបន្ទាប់បន្សំដែលទាក់ទិននឹងការផ្គត់ផ្គង់ទំនិញ ត្រូវចាត់ទុកដូចជាការផ្គត់ផ្គង់ទំនិញ ។

៤- ពាក្យ "ការផ្គត់ផ្គង់សេវា" សំដៅដល់ការផ្គត់ផ្គង់ដែលមិនមែនជាការផ្គត់ផ្គង់ទំនិញ ដីធ្លី ឬប្រាក់កាសដែលធ្វើឡើងដើម្បីបានទទួលសំណងអ្វីមួយ ។ ការផ្គត់ផ្គង់ទំនិញបន្ទាប់បន្សំដែលទាក់ទិននឹងការផ្គត់ផ្គង់ សេវាត្រូវចាត់ទុកដូចជាការផ្គត់ផ្គង់សេវា ។

# ឧបសម្ព័ន្ធ២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៤៨៦ សហវ

# ប្រកាស
## ស្តីពី
## ការចុះបញ្ជីពន្ធដារ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការ ប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- បានឃើញប្រកាសលេខ ១៨១៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានពន្ធដារ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## សម្រេច

### ប្រការ ១.- គោលបំណង

ប្រកាសនេះមានគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការចុះបញ្ជីពន្ធដារ ស្របតាមមាត្រា ១០១ នៃច្បាប់ស្តីពីសារពើពន្ធ។

### ប្រការ ២.- គោលដៅ

ប្រកាសនេះមានគោលដៅដូចខាងក្រោម÷

- ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីពន្ធដារ ដើម្បីគ្រប់គ្រង ឱ្យបានកាន់តែប្រសើរឡើងនូវទិន្នន័យរបស់អ្នកជាប់ពន្ធ
- គាំទ្រដល់ការផ្តល់សេវាដល់អ្នកជាប់ពន្ធឱ្យបានកាន់តែល្អប្រសើរ
- គាំទ្រដល់ការគ្រប់គ្រងការដាក់លិខិតប្រកាស ការធ្វើសវនកម្ម និងការប្រមូលបំណុលពន្ធឱ្យកាន់តែមានតម្លាភាព និងប្រសិទ្ធភាព។

### ប្រការ ៣.- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធ ដែលធ្វើសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ ៤.- និយមន័យ

សម្រាប់គោលដៅនៃប្រកាសនេះ ÷

- ពាក្យ "**ការចុះបញ្ជីពន្ធដារ**" សំដៅដល់ការចុះបញ្ជី អ្នកជាប់ពន្ធទាំងឡាយដែលធ្វើសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ពាក្យ "**អ្នកជាប់ពន្ធ**" សំដៅដល់បុគ្គលទាំងឡាយដែលមានកាតព្វកិច្ចត្រូវបង់ពន្ធ។
- ពាក្យ "**សកម្មភាពសេដ្ឋកិច្ច**" សំដៅដល់សកម្មភាពរបស់បុគ្គលដែលធ្វើ ជានិច្ចកាលជាប់បន្ត ឬម្តងម្កាលមួយគ្រា ដើម្បីរក ឬមិនរកចំណេញ ក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញឬសេវាឱ្យដល់បុគ្គលដទៃ ក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។
- ពាក្យ "**អាជីវកម្ម**" សំដៅដល់សកម្មភាពរបស់បុគ្គលដែលមានគោលដៅទាញយកប្រាក់ចំណូលពីការផលិតនិងលក់ទំនិញ ការផ្គត់ផ្គង់សេវា ភតិសន្យា ការជួលឬការលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងទៀត។

### ប្រការ ៥.- កាតព្វកិច្ចចុះបញ្ជីពន្ធដារ

បុគ្គលទាំងឡាយ ត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតចេញដោយ ក្រសួង ឬស្ថាប័នពាក់ព័ន្ធ។

### ប្រការ ៦.- ការស្នើសុំចុះបញ្ជីពន្ធដារ

បុគ្គលទាំងឡាយ ដែលមានកាតព្វកិច្ចចុះបញ្ជីពន្ធដារដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ ត្រូវធ្វើការស្នើសុំចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬតាមប្រព័ន្ធអេឡិកត្រូនិក (E-registration) ដោយត្រូវបំពេញ

ទម្រង់ចុះបញ្ជីដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ និងតម្រូវឱ្យភ្ជាប់មកជាមួយនូវឯកសារដូចមានកំណត់ក្នុងប្រការ៧ នៃប្រកាសនេះ។

**ប្រការ ៧.- ឯកសារ និងការតម្រូវ សម្រាប់ការចុះបញ្ជីពន្ធដារ**

**១- អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ**

**ក. ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ**

ប្រធាន ឬអ្នកតំណាងរបស់ ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ ត្រូវបានតម្រូវឱ្យបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារទាំងឡាយដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ចដូចខាងក្រោម÷

- **ឯកសារចុះបញ្ជីចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ**
  - លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ឬ/និង
  - លក្ខន្តិកៈ ឬអនុស្សរណៈយោគយល់គ្នា ជាមួយក្រសួង ស្ថាប័ន មានសមត្ថកិច្ច (បើមាន)
- **ឯកសារបញ្ជាក់អត្តសញ្ញាណ ប្រធានឬអ្នកតំណាង**
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
  - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល០៣ខែ ដែលមានទំហំ ៣៥ x ៤៥មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះនិងចុះហត្ថលេខាម្ចាស់រូបថត នៅខាងខ្នង
- **ឯកសារបញ្ជាក់ទីតាំង**
  - ប័ណ្ណកម្មសិទ្ធិទីតាំង ឬកិច្ចសន្យាជួលទីតាំងការិយាល័យ
  - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ (បើមាន)

**ខ. សហគ្រាសឯកបុគ្គល និងសហគ្រាសនីតិបុគ្គល**

ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាស ត្រូវបានតម្រូវឱ្យមកថតរូប ស្កេនម្រាមដៃដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ។

ករណីប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាសដែលមានសញ្ជាតិបរទេស ហើយស្នាក់នៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលមិនអាចអញ្ជើញមកថតរូប ស្កេនម្រាមដៃ ត្រូវធ្វើលិខិតផ្ទេរសិទ្ធិឱ្យអ្នកតំណាងណាមួយនៅក្នុងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដែលបានទទួលស្គាល់ដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ មកថតរូបនិងស្កេនម្រាមដៃជំនួសបាន និងត្រូវសហការផ្តល់នូវឯកសារពាក់ព័ន្ធ ដែលមានចែងក្នុងប្រការនេះ ដើម្បីទទួលបាននូវប័ណ្ណពន្ធប៉ាតង់ ឬ/និងវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬ/និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ។

ចំពោះប្រធានក្រុមប្រឹក្សាភិបាលឬម្ចាស់សហគ្រាសមានសញ្ជាតិបរទេស តែស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រធានក្រុមប្រឹក្សាភិបាលឬម្ចាស់សហគ្រាសមានសញ្ជាតិខ្មែរ ត្រូវបានតម្រូវឱ្យមកថតរូប និងស្កេនម្រាមដៃ និងត្រូវសហការផ្តល់នូវឯកសារពាក់ព័ន្ធ ដែលមានចែងក្នុងប្រការនេះ ដើម្បីទទួលបាននូវ

ប័ណ្ណពន្ធប៉ាតង់ ឬ/និងវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬ/និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ។

ក្នុងករណីចាំបាច់ អ្នកជាប់ពន្ធអាចស្នើសុំឱ្យរដ្ឋបាលសារពើពន្ធផ្តល់សេវាទៅថតរូប និងស្កេនម្រាមដៃ ដល់ទីតាំងសហគ្រាស ឬទីកន្លែងសមស្របណាមួយ។

ប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធិករឬម្ចាស់ភាគហ៊ុន បណ្ណាធិការ ឬអ្នកតំណាង ត្រូវបានតម្រូវឱ្យបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារទាំងឡាយដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ចដូចខាងក្រោម÷

- **ឯកសារចុះបញ្ជីចេញដោយ ក្រសួង ឬស្ថាប័នពាក់ព័ន្ធ**
  - លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ឬ/និង
  - លិខិតទទួលចុះបញ្ជីនូវការបង្កើតសាខា ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ (សម្រាប់ការចុះបញ្ជីសាខា) ឬ/និង
  - លក្ខន្តិកៈក្រុមហ៊ុនសម្រាប់នីតិបុគ្គល ឬ/និង
  - ព័ត៌មានគណនីធនាគាររបស់សហគ្រាស ដូចជាលិខិតបញ្ជាក់ គណនីធនាគារ របាយការណ៍ធនាគារ ឬសៀវភៅគណនី ដែលចេញដោយធនាគារ។
- **ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធករ ឬម្ចាស់ភាគហ៊ុន បណ្ណាធិការ អ្នកតំណាង និងអ្នកគ្រប់គ្រងសាខា**
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
  - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ៣ខែ ដែលមានទំហំ ៣៥ x ៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន ០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធានក្រុមប្រឹក្សាភិបាល។
- **ឯកសារបញ្ជាក់ទីតាំងទីចាត់ការសហគ្រាស អាជីវកម្មគោលដើម សាខាសហគ្រាស និងឃ្លាំង**
  - ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
  - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ
- **ឯកសារផ្សេងៗ**
  - វិញ្ញាបនបត្រចុះបញ្ជីរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ឬគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត (សម្រាប់ គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់)
  - អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច (បើមាន)។

**គ. សមាគម និងអង្គការនានា**

ប្រធានសមាគម ប្រធានអង្គការនានាដែលធ្វើអាជីវកម្ម ឬអ្នកតំណាងណាមួយដែលបានទទួលស្គាល់ដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ត្រូវបានតម្រូវឱ្យមកថតរូប និងស្កេនម្រាមដៃដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ និងតម្រូវឱ្យបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារទាំងឡាយដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ចដូចខាងក្រោម÷

- **ឯកសារចុះបញ្ជីចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ**

- លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ឬ/និង
- លក្ខន្តិកៈ ឬអនុស្សរណៈយោគយល់គ្នា ជាមួយក្រសួង ស្ថាប័ន មានសមត្ថកិច្ច ឬ/និង
- ព័ត៌មានគណនីធនាគារ ដូចជាលិខិតបញ្ជាក់គណនីធនាគារ របាយការណ៍ធនាគារ ឬសៀវភៅគណនី ដែលចេញដោយធនាគារ (សម្រាប់តែសមាគម ឬអង្គការនានា ដែលធ្វើអាជីវកម្ម)

- **ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ប្រធាន ឬអ្នកតំណាង**
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
  - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ខែ ដែលមានទំហំ ៣៥ x ៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន ០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធាន ឬអ្នកតំណាង សមាគម ឬអង្គការនានា។
- **ឯកសារបញ្ជាក់ទីតាំង**
  - ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងការិយាល័យ
  - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ (បើមាន)

## ២- អ្នកជាប់ពន្ធដទៃទៀត

អ្នកជាប់ពន្ធតូច ឬបុគ្គលទាំងឡាយណាដែលមានសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០ លានរៀល ឬមានផលរបរក្នុងរយៈពេល០៣ខែណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តក្រោម ៦០ លានរៀល ត្រូវបានតម្រូវឱ្យបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ និងភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម ឬច្បាប់ថតចម្លងនៃឯកសារទាំងឡាយដែលមានបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច ដូចខាងក្រោម ÷

- **ឯកសារចុះបញ្ជីចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ**
  - លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជីចេញដោយ ក្រសួង ស្ថាប័នពាក់ព័ន្ធ (បើមាន)
- **ឯកសារបញ្ជាក់អត្តសញ្ញាណរបស់កម្មសិទ្ធិករ**
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
  - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ខែ ដែលមានទំហំ ៣៥x ៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន ០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះ និងចុះហត្ថលេខាទទួលខុសត្រូវដោយម្ចាស់រូបថត។
- **ឯកសារបញ្ជាក់ទីតាំងអាជីវកម្មដ្ឋាន**
  - ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
  - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ (បើមាន)

## ៣- ការប្រើប្រាស់អាសយដ្ឋានក្នុងការចុះបញ្ជីពន្ធដារ និងតម្រូវការឯកសារភ្ជាប់បន្ថែម

សម្រាប់គោលដៅនៃការចុះបញ្ជីពន្ធដារ អាសយដ្ឋាននៃទីតាំងរបស់ស្ថាប័ន ឬទីចាត់ការសហគ្រាស ឬសាខាសហគ្រាស ឬសមាគម ឬអង្គការនានា ដែលគ្មានអគារ (ដីទំនេរ) ឬមានសំណង់ទើបតែចាប់ផ្តើមសាងសង់

មិនអាចប្រើប្រាស់បាន មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ជាអាសយដ្ឋានសម្រាប់ការចុះបញ្ជីពន្ធដារបានឡើយ វៀរលែងតែមានការយល់ព្រមពីអគ្គនាយកដ្ឋានពន្ធដារ។

អ្នកជាប់ពន្ធដែលមានអាសយដ្ឋានស្នាក់នៅ ខុសពីអាសយដ្ឋានក្នុងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន អ្នកជាប់ពន្ធត្រូវភ្ជាប់បន្ថែមនូវសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ៨.- ការស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់សហគ្រាសដែលបានចុះបញ្ជី**

១. អនុលោមតាមមាត្រា ១០១ នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធបានចុះបញ្ជីពន្ធដាររួចហើយ ត្រូវបានតម្រូវឱ្យធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ក្នុងករណីដែលព័ត៌មានណាមួយក្នុងចំណោមព័ត៌មានខាងក្រោមនេះត្រូវបានផ្លាស់ប្តូរ÷

ក. នាមករណ៍សហគ្រាស

ខ. អាសយដ្ឋានទីចាត់ការ កន្លែងប្រកបអាជីវកម្មជាគោលដើម ឬសាខា ឃ្លាំងរបស់សគ្រាស

គ. អាសយដ្ឋានម្ចាស់សហគ្រាស អភិបាល ឬបណ្ណាធិការ របស់សហគ្រាស

ឃ. ទ្រង់ទ្រាយគតិយុត្តរបស់សហគ្រាស

ង. កម្មវត្ថុអាជីវកម្ម

ច. ការផ្ទេរ ការបញ្ឈប់អាជីវកម្ម

ឆ. សមាសភាពអ្នកគ្រប់គ្រង

ជ. អ្នកទទួលបន្ទុកកិច្ចការពន្ធ

ឈ. លេខគណនីធនាគារសហគ្រាស

ញ. លេខទំនាក់ទំនង (លេខទូរស័ព្ទ សារអេឡិចត្រូនិក)។

២. អ្នកជាប់ពន្ធត្រូវស្នើសុំមករដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីមានការផ្លាស់ប្តូរព័ត៌មានដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការនេះ ដើម្បីធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដារឡើងវិញ ដោយត្រូវគោរពតាមលក្ខខណ្ឌ និងភ្ជាប់មកនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារចុងក្រោយនៃឯកសារនានាដែលបានតម្រូវក្នុងប្រការ៧ នៃប្រកាសនេះ។

៣. ចំពោះអ្នកជាប់ពន្ធដែលមានការផ្លាស់ប្តូរអាសយដ្ឋានទីចាត់ការសហគ្រាស ឬទ្រង់ទ្រាយគតិយុត្តរបស់សហគ្រាស ដែលនាំឱ្យមានការផ្លាស់ប្តូរពីការគ្រប់គ្រងរបស់អង្គភាពពន្ធដារមួយ ទៅអង្គភាពពន្ធដារមួយទៀត ត្រូវធ្វើការស្នើសុំផ្លាស់ប្តូរអង្គភាពទៅតាមទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសាពើពន្ធ។

៤. ចំពោះអ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារមុនថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤ ប្រធានស្ថាប័នរដ្ឋ ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាស ប្រធានអង្គការមិនមែនរដ្ឋាភិបាល ត្រូវមកធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដារឡើងវិញ ដោយត្រូវគោរពតាមលក្ខខណ្ឌ និងភ្ជាប់មកនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារចុងក្រោយនៃឯកសារនានាដែលបានតម្រូវក្នុងប្រការ៧ នៃប្រកាសនេះ។

**ប្រការ៩.- កម្រៃសេវាចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស**

១. កម្រៃសេវាចុះបញ្ជីពន្ធដារមានដូចខាងក្រោម÷

- ០ រៀល សម្រាប់ស្ថាប័នរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ ដែលបានស្នើសុំ ដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌ១ នៃប្រការ៧ នៃប្រកាសនេះ
- ២០ ០០០ រៀល សម្រាប់អ្នកជាប់ពន្ធតូច និងអ្នកជាប់ពន្ធដែលមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០ លានរៀល ឬមានផលរបរក្នុងរយៈពេល ០៣ ខែ ណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តក្រោម ៦០លានរៀល ដែលបានស្នើសុំដូចមានចែងក្នុងកថាខណ្ឌ២ នៃប្រការ៧ នៃប្រកាសនេះ
- ៤០០ ០០០ រៀល សម្រាប់អ្នកជាប់ពន្ធមធ្យម អ្នកជាប់ពន្ធធំ សមាគម និងអង្គការនានា ដែលបានស្នើសុំ ដូចមានចែងក្នុងវាក្យខណ្ឌ ខ និង វាក្យខណ្ឌ គ នៃកថាខណ្ឌ១ នៃប្រការ៧ នៃប្រកាសនេះ។

២. កម្រៃសេវាធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសដូចមានចែងក្នុងប្រការ ៨ នៃប្រកាសនេះមានដូចខាងក្រោម÷

- ០ រៀល សម្រាប់ស្ថាប័នរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ
- ១០ ០០០ រៀល សម្រាប់អ្នកជាប់ពន្ធតូច ឬបុគ្គលទាំងឡាយណាដែលមានសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០ លានរៀល ឬមានផលរបរក្នុងរយៈពេល០៣ខែណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តក្រោម ៦០ លានរៀល
- ២០០ ០០០ រៀល សម្រាប់អ្នកជាប់ពន្ធមធ្យម អ្នកជាប់ពន្ធធំ សមាគម និងអង្គការនានា។

៣. កម្រៃសេវាដូចមានចែងក្នុងកថាខណ្ឌ២ នៃប្រការ៩ នៃប្រការនេះ ត្រូវអនុវត្តផងដែរចំពោះអ្នកជាប់ពន្ធដែលមានការផ្លាស់ប្តូរព័ត៌មាននៅលើប័ណ្ណពន្ធប៉ាតង់ ឬវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬលិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ ឬស្នើសុំបោះពុម្ពឡើងវិញនូវ ប័ណ្ណពន្ធប៉ាតង់ ឬវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬលិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ។ ដោយឡែកការស្នើសុំបោះពុម្ពប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារឡើងវិញ អ្នកជាប់ពន្ធត្រូវបានតម្រូវឱ្យបង់កម្រៃសេវា ចំនួន ៥ ០០០ រៀល។

**ប្រការ ១០.-ការបញ្ជាក់ការទទួលសំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារ**

រដ្ឋបាលសារពើពន្ធ ត្រូវចេញលិខិតបញ្ជាក់ការទទួលសំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារ ដោយបញ្ជាក់កាលបរិច្ឆេទទទួលសំណុំឯកសារបន្ទាប់ពីបានពិនិត្យឃើញថា សំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារនោះត្រឹមត្រូវ និងគ្រប់គ្រាន់តាមការកំណត់ក្នុងប្រការ៧ នៃប្រកាសនេះ។

**ប្រការ១១.- រយៈពេលទទួលបានការចុះបញ្ជីពន្ធដារ ឬការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស**

១. អ្នកជាប់ពន្ធអាចទទួលបានសេចក្តីសម្រេចចុះបញ្ជីពន្ធដារ ឬការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសក្នុងរយៈពេល÷

- ០១ថ្ងៃ ទៅ ០៧ថ្ងៃ នៃថ្ងៃធ្វើការ ចំពោះការចុះបញ្ជីតាមរយៈប្រព័ន្ធអេឡិកត្រូនិក (E-registration)

- ០៧ថ្ងៃ ទៅ ១០ថ្ងៃ នៃថ្ងៃធ្វើការ ចំពោះការចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ។

២. ក្រោយពេលចុះបញ្ជីពន្ធដារ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសរួចរាល់ រដ្ឋបាលសារពើពន្ធត្រូវចុះដល់ទីតាំងផ្ទាល់របស់សហគ្រាស ដើម្បីថតរូបទីតាំង និងកត់ត្រាទិន្នន័យរបស់ទីតាំងសហគ្រាស (GPS) ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ និងប្រគល់ឯកសារផ្លូវការដែលបានចេញដោយរដ្ឋបាលសារពើពន្ធ ដោយមានការចុះហត្ថលេខាទទួលត្រឹមត្រូវពីអ្នកជាប់ពន្ធ។

៣. ឯកសារផ្លូវការ នៃការចុះបញ្ជីពន្ធដារ ឬការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសដែលត្រូវប្រគល់ទទួលមានដូចខាងក្រោម÷

**ក. ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលនានា គណបក្សនយោបាយ សមាគម អង្គការនានា ដែលមិនប្រកបអាជីវកម្ម**

- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬ/និង
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ឬ/និង
- លិខិតជូនដំណឹងស្តីពីការដាក់លិខិតប្រកាសពន្ធ

**ខ. សហគ្រាសឯកបុគ្គល សហគ្រាសនីតិបុគ្គល សមាគម និងអង្គការនានា ដែលប្រកបអាជីវកម្ម**

- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬ/និង
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ឬ/និង
- ប័ណ្ណពន្ធប៉ាតង់ ឬ/និង
- លិខិតជូនដំណឹងស្តីពីការដាក់លិខិតប្រកាសពន្ធ

**គ. អ្នកជាប់ពន្ធដែលមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០លានរៀល ឬមានផលរបរក្នុងរយៈពេលបីខែណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តក្រោម ៦០លានរៀល**

- លិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ ឬ/និង
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ

**ប្រការ ១២.- សិទ្ធិរបស់រដ្ឋបាលសារពើពន្ធ**

អនុលោមតាមមាត្រា១០៣ នៃច្បាប់ស្តីពីសារពើពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជីជាឯកតោភាគីចំពោះ អ្នកជាប់ពន្ធដែលច្បាប់បានកំណត់ឱ្យចុះបញ្ជី ហើយពុំបានមកចុះបញ្ជី។ ក្នុងករណីនេះរដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី និងកំណត់នូវអ្នកតំណាងណាមួយរបស់សហគ្រាស ដើម្បីមកថតរូបនិងស្កែនស្រាមដៃដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ។

ក្នុងករណីដែលប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធិករឬម្ចាស់ភាគហ៊ុន ប្រធានអង្គការនានា និងអ្នកតំណាង មានការទាក់ទិននឹងការគ្រប់គ្រងសហគ្រាស ឬសមាគម ឬអង្គការនានា ដទៃទៀតដែលមានជំពាក់បំណុលពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិបដិសេធការចុះបញ្ជីពន្ធដារ។

**ប្រការ ១៣.- សិទ្ធិរបស់អ្នកជាប់ពន្ធ**

អ្នកជាប់ពន្ធមានសិទ្ធិដាក់បណ្តឹងតវ៉ាទៅអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីស្នើសុំឱ្យពិនិត្យ

ឡើងវិញ លើការបដិសេធការចុះបញ្ជី។ ក្នុងករណីអ្នកជាប់ពន្ធមិនយល់ព្រមលើសេចក្ដីសម្រេចរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អ្នកជាប់ពន្ធអាចប្ដឹងតវ៉ាទៅគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ។

**ប្រការ ១៤.- ទោសទណ្ឌ**

ការមិនបានចុះបញ្ជីពន្ធដារ មិនបានធ្វើបច្ចុប្បន្នភាពព័ត៌មាន ឬការមិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្ដូរដូចមានចែងក្នុងប្រការ៥ និងប្រការ៨ នៃប្រកាសនេះ ត្រូវចាត់ទុកថាបានប្រព្រឹត្តអំពើរំលងស្មុះលើបទប្បញ្ញត្តិស្ដីពីពន្ធដារ និងត្រូវរងទោសទណ្ឌតាមច្បាប់ស្ដីពីសារពើពន្ធ។

**ប្រការ ១៥.-និរាករណ៍**

ប្រកាសលេខ ១១៣៩ សហវ.ប្រក ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៤ ស្ដីពីការចុះបញ្ជីពន្ធដារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៦.- ការអនុវត្តប្រកាស**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអ្នកជាប់ពន្ធដែលមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ១៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

លេខ/ N° VATM201806495 អពជ



# វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ
## (អាករលើតម្លៃបន្ថែម-អតប)

អគ្គនាយកដ្ឋានពន្ធដារ សូមបញ្ជាក់ថា
សហគ្រាសឈ្មោះ **ជេនេរ៉ល អេវីអេសិន សឺវីស (ខេមបូឌា) ឯ.ក**
អាសយដ្ឋានៈ # ផ្លូវ ភូមិ មណ្ឌល៣ សង្កាត់ ស្លក្រាម ក្រុង សៀមរាប ខេត្ត សៀមរាប
បានចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារដែលមានលេខអត្តសញ្ញាណកម្មសារពើពន្ធ អតប B116-901802454
និងមានសកម្មភាពអាជីវកម្មចម្បង **សេវាជួលសម្ភារ និងកម្លាំងពលកម្មលើវិស័យអាកាសចរណ៍**
ស្របតាមមាត្រា ៧៦ នៃច្បាប់ស្តីពីសារពើពន្ធ
ការចុះបញ្ជីនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃ ១៥ ខែមិថុនា ឆ្នាំ២០១៨ តទៅ។

**CERTIFICATE OF TAX REGISTRATION (VALUE ADDED TAX-VAT)**

GENERAL DEPARTMENT OF TAXATION certifies that

**GENERAL AVIATION SERVICES (CAMBODIA) CO., LTD.**

is registered VAT TIN **B116-901802454**

with its main business activity(ies): **Equipment rental and labor service on airlines sector**

In accordance with article 76 of the Law on Taxation, this registration is valid from 15-June-2018 onward.

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨
Phnom Penh,15 June 2018

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**
Delegate of Royal Government
In Charge as Director General of General Department of Taxation

អគ្គនាយកដ្ឋាន ពន្ធដារ

**គង់ វិបុល**

SN: 0250526

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

លេខ/ N° PTM2019012745 អពដ



# ប័ណ្ណពន្ធប៉ាតង់ ឆ្នាំ ២០១៩
## អ្នកជាប់ពន្ធមធ្យម

ឈ្មោះសហគ្រាស៖ ជេនេរ៉ល អេវីអេសិន សឺវីស (ខេមបូឌា) ឯ.ក
លេខអត្តសញ្ញាណកម្មសារពើពន្ធ៖ B116-901802454
ចុះបញ្ជីនៅ៖ អគ្គនាយកដ្ឋានពន្ធដារ ស្ថិតនៅក្រោមការគ្រប់គ្រង៖ សាខាពន្ធដារខេត្តសៀមរាប
ទ្រង់ទ្រាយសហគ្រាស៖ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត
សកម្មភាពអាជីវកម្មចម្បង៖ សេវាជួលសម្ភារ និងកម្លាំងពលកម្មលើវិស័យអាកាសចរណ៍
អាសយដ្ឋានសហគ្រាស៖ # ផ្លូវ ភូមិ មណ្ឌល៣ សង្កាត់ ស្លក្រាម ក្រុង សៀមរាប ខេត្ត សៀមរាប
ឈ្មោះម្ចាស់សហគ្រាស៖ សាង សុជីវិត សញ្ជាតិ៖ ខ្មែរ

# PATENT TAX 2019
Medium Taxpayer

Company's name : **GENERAL AVIATION SERVICES (CAMBODIA) CO., LTD.**
Tax Identification Number (TIN) : B116-901802454
Registered at : General Department of Taxation Under : SIEM REAP TAX BRANCH
Main business activity(ies) : Equipment rental and labor service on airlines sector
Forms of business : Private limited company
Owner's name : **SANG SOCHIVITH** Nationality: Cambodian

ទឹកប្រាក់ពន្ធប៉ាតង់ ២០១៩
១.២០០.០០០ រៀល

លេខ SN : 003431696

អគ្គនាយកដ្ឋានពន្ធដារ
General Department of Taxation
បោះពុម្ពនៅ / Printed at
សាខាពន្ធដារខេត្តសៀមរាប
Siem Reap Tax Branch

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៩
Phnom Penh, 17 January 2019

បញ្ជាក់ ៖ ប័ណ្ណប៉ាតង់នេះត្រូវដាក់តាំង ឬព្យួរ នៅទីកន្លែងប្រកបអាជីវកម្ម។
Note : This patent tax must be hanged or displayed at the company's office.



ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ
TAX REGISTRATION IDENTIFICATION CARD

ឈ្មោះសហគ្រាស : អាល់ហ្វា សីបផ្លាយ & ឌីស្ទ្រីប៊្យូសិន ឯ.ក
Name in Latin : ALPHA SUPPLIES & DISTRIBUTIONS CO., LTD.
លេខអត្តសញ្ញាណកម្មសារពើពន្ធ (TIN) : K010-901901687
សាខាពន្ធដារខណ្ឌពោធិ៍សែនជ័យ / Por Senchey Tax Branch
ថ្ងៃខែឆ្នាំចុះបញ្ជី / Registered Date : 08 មេសា 2019 / 08 Apr 2019



- ប័ណ្ណសម្គាល់នេះសម្រាប់ប្រើប្រាស់ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ ។
- ត្រូវបង្ហាញប័ណ្ណសម្គាល់នេះគ្រប់ពេលបង់ពន្ធ ឬនៅពេលនាំចូលទំនិញ ។
- ត្រូវបង្ហាញប័ណ្ណសម្គាល់នេះជូនមន្ត្រីរាជការពន្ធដារនៅពេលដែលមានការចុះត្រួតពិនិត្យកិច្ចការសារពើពន្ធ ។
- ករណីបាត់ ឬខូច ត្រូវរាយការណ៍ជូនអគ្គនាយកដ្ឋានពន្ធដារដើម្បីធ្វើថ្មី ។

GDT-REG000092265

អគ្គនាយកដ្ឋានពន្ធដារ អាគារកែងមហាវិថីសហព័ន្ធរុស្ស៊ី និង ម៉ៅសេទុង សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ (+855) 23 886 708 ទូរសារ (+855) 23 886 700
Email: gdt@tax.gov.kh Website: www.tax.gov.kh

# ឧបសម្ព័ន្ធ៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.០០២......សហវ.ឝ១ ២

# សេចក្តីណែនាំ
# ស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី

អនុលោមតាមមាត្រា៤៧ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំ ដូចតទៅ÷

## ១. រយៈពេលអនុវត្តនិងអត្រាកំណើនតាមថ្នាក់ថ្មី

គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជន ស្ថាប័នរដ្ឋ និងអង្គការនានា ដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ពន្ធលើប្រាក់បៀវត្ស (ពបវ) ត្រូវអនុវត្តអត្រាកំណើនតាមថ្នាក់ថ្មីចំពោះប្រាក់បៀវត្ស ដែលបើកជូននិយោជិតចាប់ពីខែមករា ឆ្នាំ២០១៨ តរៀងទៅ ដែលនឹងត្រូវដាក់លិខិតប្រកាសបង់ប្រាក់ពន្ធប្រចាំខែនីមួយៗ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់។

តារាងអត្រាកំណើនតាមថ្នាក់ថ្មីមានដូចខាងក្រោម ÷

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០៛ | ដល់ | ១ ២០០ ០០០៛ | ០% |
| ពី | ១ ២០០ ០០១៛ | ដល់ | ២ ០០០ ០០០៛ | ៥% |
| ពី | ២ ០០០ ០០១៛ | ដល់ | ៨ ៥០០ ០០០៛ | ១០% |
| ពី | ៨ ៥០០ ០០១៛ | ដល់ | ១២ ៥០០ ០០០៛ | ១៥% |
| | | លើសពី | ១២ ៥០០ ០០០៛ | ២០% |

## ២. ទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក

ផ្អែកលើការបង្ហាញភ័ស្តុតាងនៃស្ថានភាពគ្រួសារ មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ ត្រូវបានអនុញ្ញាតឱ្យកាត់បន្ថយមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សចំពោះកូនក្នុងបន្ទុក និងសហព័ទ្ធជាមេផ្ទះ ក្នុងម្នាក់ៗ ១៥០ ០០០ រៀល ក្នុងមួយខែ។ ការកាត់បន្ថយនេះ ធ្វើឱ្យមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សកាន់តែទាប ដែលនាំឱ្យមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ និងដែលមានប្រាក់បៀវត្សក្នុងរង្វង់ពី ១ ២០០ ០០១ រៀល ដល់ ១ ៦០០ ០០០រៀល (ប្រមាណពី៣០០ ទៅ ៤០០ ដុល្លារអាមេរិក) អាចនឹងរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## ៣. ការគណនាពន្ធលើប្រាក់បៀវត្ស

យោងតាមមាត្រា៤២ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ពាក្យ "ប្រាក់បៀវត្ស" សំដៅដល់បៀវត្ស លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែមដែលបានទូទាត់ឱ្យដល់និយោជិត ឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិត ចំពោះការបំពេញសកម្មភាពបម្រើការងារ។

ដើម្បីគណនាពន្ធលើប្រាក់បៀវត្សរបស់និយោជិតនិវាសជន ត្រូវរកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សដោយយកចំនួនប្រាក់បៀវត្សជាប់ពន្ធសរុប ដកចេញនូវ ទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក។ ដោយឡែក ចំពោះកម្មករនិយោជិត រោងចក្រ សហគ្រាស ប្រាក់បៀវត្សជាប់ពន្ធ ត្រូវបានអនុញ្ញាតឱ្យដកចេញបន្ថែមទៀតនូវប្រាក់ឧបត្ថម្ភដែលទទួលបានពីការបំពេញការងារ ដូចមានចែងក្នុងសារាចរលេខ ០១១ សហវ ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែម។

បន្ទាប់មក ត្រូវពិនិត្យមើលថាតើមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សស្ថិតក្នុងថ្នាក់អត្រាពន្ធណាមួយ ទើបយកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សនោះ ទៅគុណនឹងអត្រាពន្ធ ហើយដកចេញនូវលម្អៀងលើសប្រាក់ពន្ធសម្រាប់ថ្នាក់អត្រាពន្ធនោះ។ លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ គឺជាផលបូកនៃពន្ធលើប្រាក់បៀវត្សដែលបានលើកលែងចំពោះប្រាក់បៀវត្ស ១ ២០០ ០០០ រៀល ដំបូង និងលម្អៀងលើសនៃប្រាក់ពន្ធតាមថ្នាក់នីមួយៗ។

តារាងអត្រាកំណើនតាមថ្នាក់និងលម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ÷

| **គាគបៀវត្សជាប់ពន្ធប្រចាំខែ** | | | | **អត្រា** | **លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ** |
|---|---|---|---|---|---|
| ពី | ០៛ | ដល់ | ១ ២០០ ០០០៛ | ០ % | ០ ៛ |
| ពី | ១ ២០០ ០០១៛ | ដល់ | ២ ០០០ ០០០៛ | ៥ % | ៦០ ០០០ ៛ |
| ពី | ២ ០០០ ០០១៛ | ដល់ | ៨ ៥០០ ០០០៛ | ១០ % | ១៦០ ០០០ ៛ |
| ពី | ៨ ៥០០ ០០១៛ | ដល់ | ១២ ៥០០ ០០០៛ | ១៥ % | ៥៨៥ ០០០ ៛ |
| | | លើសពី | ១២ ៥០០ ០០០៛ | ២០ % | ១ ២១០ ០០០ ៛ |

**រូបមន្ត÷**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ x សហព័ទ្ធនិងចំនួនកូនក្នុងបន្ទុក

មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស(មពបវ) = ប្រាក់បៀវត្សជាប់ពន្ធ (បវ) - ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក

ពន្ធលើប្រាក់បៀវត្ស(ពបវ) = មូលដ្ឋានគិត ពបវ x អត្រាពន្ធ - លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ(លបព)

**កំណត់សម្គាល់÷**

ចំពោះកម្មករនិយោជិត រោងចក្រ សហគ្រាស ប្រសិនបើប្រាក់បៀវត្សជាប់ពន្ធ (បវ) មានរួមបញ្ចូលនូវប្រាក់ឧបត្ថម្ភដែលទទួលបានពីការបំពេញការងារ ប្រាក់ឧបត្ថម្ភនោះត្រូវបានអនុញ្ញាតឱ្យដកចេញពីប្រាក់បៀវត្សជាប់ពន្ធ (បវ)។

**ឧទាហរណ៍ទី១** ÷ កម្មករនិយោជិត រោងចក្រ សហគ្រាស ម្នាក់មានប្រាក់បៀវត្ស ១ ៨០០ ០០០ រៀល ដែលក្នុងនោះមានប្រាក់ឧបត្ថម្ភសោហ៊ុយធ្វើដំណើរនិងថ្លៃបាយសរុបចំនួន ១០០ ០០០ រៀល។

**ក. ករណីនៅលីវ**

មពបវ = ១ ៨០០ ០០០៛ - ១០០ ០០០៛ = ១ ៧០០ ០០០៛ (ត្រូវជាប់ពន្ធតាមអត្រា ៥%)

លបព = ៦០ ០០០៛

ពបវ = (១ ៧០០ ០០០៛ x ៥%) - ៦០ ០០០៛ = **២៥ ០០០៛**

**ខ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣ ក្នុងបន្ទុក**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ X ៤ = ៦០០ ០០០៛

មពបវ = ១ ៨០០ ០០០៛ - ១០០ ០០០៛- ៦០០ ០០០៛ = ១ ១០០ ០០០៛ (ត្រូវជាប់ពន្ធតាមអត្រា ០%)

លបព = ០៛

ពបវ = (១ ១០០ ០០០៛ x ០%) - ០៛ = **០៛**

**ឧទាហរណ៍ទី២** ÷ អ្នកគ្រប់គ្រងក្រុមហ៊ុនម្នាក់មានប្រាក់បៀវត្ស ៨ ៦០០ ០០០ រៀល

**ក. ករណីនៅលីវ**

មពបវ = ៨ ៦០០ ០០០៛ (ជាប់ពន្ធតាមអត្រា ១៥%)

លបព = ៥៨៥ ០០០៛

ពបវ = (៨ ៦០០ ០០០៛ x ១៥%) - ៥៨៥ ០០០៛ = **៧០៥ ០០០៛**

**ខ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ X ៤ = ៦០០ ០០០៛

មពបវ = ៨ ៦០០ ០០០៛ - ៦០០ ០០០៛ = ៨ ០០០ ០០០៛ (ជាប់ពន្ធតាមអត្រា ១០%)

លបព = ១៦០ ០០០៛

ពបវ = (៨ ០០០ ០០០៛ x ១០%) - ១៦០ ០០០៛ = **៦៤០ ០០០៛**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជន ស្ថាប័នរដ្ឋ និងអង្គការនានាដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ប្រាក់ពន្ធលើប្រាក់បៀវត្ស នឹងយកចិត្តទុកដាក់ចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ... ខែ... ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១៨

**[ឧបនាយករដ្ឋមន្ត្រី] សាស្ត្រាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- គ្រប់ក្រសួង ស្ថាប័ន
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០១៧.......សហវ.អគព

## សេចក្តីណែនាំ
## ស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី

អនុលោមតាមមាត្រា៤៧ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំ ដូចតទៅ÷

### ១. រយៈពេលអនុវត្តនិងអត្រាកំណើនតាមថ្នាក់ថ្មី

គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ស្ថាប័នរដ្ឋ និងអង្គការនានា ដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ពន្ធលើប្រាក់បៀវត្ស (ពបវ) ត្រូវចាប់អនុវត្តអត្រាកំណើនតាមថ្នាក់ថ្មីចំពោះប្រាក់បៀវត្ស ដែលបើកជូននិយោជិតក្នុងខែមករា ឆ្នាំ២០១៧ ដែលនឹងត្រូវដាក់លិខិតប្រកាសបង់ប្រាក់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃ ទី២០ នៃ ខែកុម្ភៈ ឆ្នាំ២០១៧។

តារាងអត្រាកំណើនតាមថ្នាក់ថ្មីមានដូចខាងក្រោម ÷

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០ ៛ | ដល់ | ១ ០០០ ០០០ ៛ | 0% |
| ពី | ១ ០០០ ០០១ ៛ | ដល់ | ១ ៥០០ ០០០ ៛ | ៥% |
| ពី | ១ ៥០០ ០០១ ៛ | ដល់ | ៨ ៥០០ ០០០ ៛ | ១0% |
| ពី | ៨ ៥០០ ០០១ ៛ | ដល់ | ១២ ៥០០ ០០០ ៛ | ១៥% |
| | | លើសពី | ១២ ៥០០ ០០០ ៛ | ២0% |

### ២. ទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក

ផ្អែកលើការបង្ហាញភស្តុតាងនៃស្ថានភាពគ្រួសារ ដើម្បីសម្រួលជីវភាពរស់នៅរបស់មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ រាជរដ្ឋាភិបាលក៏បានសម្រេចធ្វើការដំឡើងកម្រិតកាត់បន្ថយមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សចំពោះកូនក្នុងបន្ទុក និងសហព័ទ្ធជាមេផ្ទះ ក្នុងម្នាក់ៗពី ៧៥ ០០០ រៀល ដល់ ១៥០ ០០០ រៀល ក្នុងមួយខែ (កើនឡើងពីរដង)។ ការដំឡើងកម្រិតកាត់បន្ថយនេះ ធ្វើឱ្យមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សកាន់តែតិចដែលនាំឱ្យមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ និងដែលមានប្រាក់បៀវត្សលើសពី ១ ០០០ ០០០ រៀល អាចនឹងរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស។

៥៩



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

### ៣. ការគណនាពន្ធលើប្រាក់បៀវត្ស

ក- យោងតាមមាត្រា៤២ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ពាក្យ "ប្រាក់បៀវត្ស" សំដៅដល់បៀវត្ស លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែមដែលបានទូទាត់ឱ្យដល់និយោជិត ឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិត ចំពោះ ការបំពេញសកម្មភាពបំរើការងារ។

ខ- ប្រាក់ឧបត្ថម្ភមួយចំនួនដែលកម្មករនិយោជិត រោងចក្រ សហគ្រាស ទទួលបានពីការបំពេញការងារដូចមានចែងក្នុងសារាចរលេខ ០០១ សហវ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែម ត្រូវបានអនុញ្ញាតឱ្យដកចេញពីមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស និងមិនមែនជាកម្មវត្ថុនៃពន្ធលើអត្ថប្រយោជន៍បន្ថែមទេ។

គ- ដើម្បីគណនាពន្ធលើប្រាក់បៀវត្សរបស់និយោជិតនិវាសជន ត្រូវរកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សដោយយកចំនួនប្រាក់បៀវត្សសរុប ក្រៅពីប្រាក់រង្វាន់ និងប្រាក់ឧបត្ថម្ភ ដូចមានក្នុងចំណុច ខ ខាងលើ ដកចេញនូវ ទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក។ បន្ទាប់មក ត្រូវពិនិត្យមើលថាតើមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សស្ថិតក្នុងថ្នាក់អត្រាពន្ធណាមួយ ទើបយកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សនោះ ទៅគុណនឹងអត្រាពន្ធ ហើយដកចេញនូវលម្អៀងលើសប្រាក់ពន្ធ សម្រាប់ថ្នាក់អត្រាពន្ធនោះ។ លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ គឺជាផលបូកនៃពន្ធលើប្រាក់បៀវត្សដែលបានលើកលែងចំពោះប្រាក់បៀវត្ស ១ ០០០ ០០០ រៀលដំបូង និងលម្អៀងលើសនៃប្រាក់ពន្ធតាមថ្នាក់នីមួយៗ។

ឃ- តារាងអត្រាកំណើនតាមថ្នាក់និងលម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ÷

| **ភាគបៀវត្សជាប់ពន្ធប្រចាំខែ** | | | | **អត្រា** | **លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ** |
|---|---|---|---|---|---|
| ពី | ០ ៛ | ដល់ | ១ ០០០ ០០០ ៛ | ០ % | ០ ៛ |
| ពី | ១ ០០០ ០០១ ៛ | ដល់ | ១ ៥០០ ០០០ ៛ | ៥ % | ៥០ ០០០ ៛ |
| ពី | ១ ៥០០ ០០១ ៛ | ដល់ | ៨ ៥០០ ០០០ ៛ | ១០ % | ១២៥ ០០០ ៛ |
| ពី | ៨ ៥០០ ០០១ ៛ | ដល់ | ១២ ៥០០ ០០០ ៛ | ១៥ % | ៥៥០ ០០០ ៛ |
| | | លើសពី | ១២ ៥០០ ០០០ ៛ | ២០ % | ១ ១៧៥ ០០០ ៛ |

**រូបមន្ត÷**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ x សហព័ទ្ធនិងចំនួនកូនក្នុងបន្ទុក

មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស(មពបវ) = ប្រាក់បៀវត្សជាប់ពន្ធ (បវ) - ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក

ពន្ធលើប្រាក់បៀវត្ស(ពបវ) = មូលដ្ឋានគិត ពបវ x អត្រាពន្ធ - លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ(លបព)

**ឧទាហរណ៍ទី១÷** កម្មករនិយោជិតម្នាក់មានប្រាក់បៀវត្ស ២ ០០០ ០០០ រៀល

ក. ករណីនៅលីវ

មពបវ = ២ ០០០ ០០០៛ ជាប់ពន្ធក្នុងអត្រា ១០%

លបព = ១២៥ ០០០៛

ពបវ = (២ ០០០ ០០០៛ x ១០%) - ១២៥ ០០០៛ = ៧៥ ០០០៛

**ខ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣ ក្នុងបន្ទុក**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ X ៤ = ៦០០ ០០០៛

មពបវ = ២ ០០០ ០០០៛ - ៦០០ ០០០៛ = ១ ៤០០ ០០០៛ ជាប់ពន្ធក្នុងអត្រា ៥%

លបព = ៥០ ០០០៛

ពបវ = (១ ៤០០ ០០០៛ x ៥%) - ៥០ ០០០៛ = **២០ ០០០៛**

**គ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៦ ក្នុងបន្ទុក**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ X ៧ = ១ ០៥០ ០០០៛

មពបវ = ២ ០០០ ០០០៛ - ១ ០៥០ ០០០៛ = ៩៥០ ០០០៛ ជាប់ពន្ធក្នុងអត្រា ០%

ពបវ = ០៛

**ឧទាហរណ៍ទី២÷** កម្មករនិយោជិតម្នាក់មានប្រាក់បៀវត្ស ១២ ៦០០ ០០០ រៀល

**ក. ករណីនៅលីវ**

មពបវ = ១២ ៦០០ ០០០៛ ជាប់ពន្ធក្នុងអត្រា ២០%

លបព = ១ ១៧៥ ០០០៛

ពបវ = (១២ ៦០០ ០០០៛ x ២០%) - ១ ១៧៥ ០០០៛ = **១ ៣៤៥ ០០០៛**

**ខ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ X ៤ = ៦០០ ០០០៛

មពបវ = ១២ ៦០០ ០០០៛ - ៦០០ ០០០៛ = ១២ ០០០ ០០០៛ ជាប់ពន្ធក្នុងអត្រា ១៥%

លបព = ៥៥០ ០០០៛

ពបវ = (១២ ០០០ ០០០៛ x ១៥%) - ៥៥០ ០០០៛ = **១ ២៥០ ០០០៛**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជន ដែលប្រកបអាជីវកម្ម ស្ថាប័នរដ្ឋ និងអង្គការនានាដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ប្រាក់ពន្ធលើប្រាក់បៀវត្ស នឹងយកចិត្តទុកដាក់ចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាព។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- គ្រប់ក្រសួង ស្ថាប័ន
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៧........សហវ....

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៥

# សេចក្តីណែនាំ
## ស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្ស

អនុលោមតាមមាត្រា៤៧ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំដូចតទៅ÷

**១- រយៈពេលអនុវត្តនិងអត្រាកំណើនតាមថ្នាក់ថ្មី** (Application Period and New Progressive Tax Rates)

គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ស្ថាប័នរដ្ឋ និងអង្គការនានា ដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ពន្ធលើប្រាក់បៀវត្ស (ពបវ) ត្រូវចាប់អនុវត្តអត្រាកំណើនតាមថ្នាក់ថ្មីចំពោះប្រាក់បៀវត្សដែលបើកជូននិយោជិតក្នុងខែមករា ឆ្នាំ២០១៥ ដែលនឹងត្រូវដាក់លិខិតប្រកាសបង់ប្រាក់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៥។

តារាងអត្រាកំណើនតាមថ្នាក់ថ្មីសម្រាប់គិត ពបវ មានដូចខាងក្រោម ÷

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | 0 ៛ | ដល់ | ៨០០ ០០០ ៛ | 0% |
| ពី | ៨០០ ០០១ ៛ | ដល់ | ១ ២៥០ ០០០ ៛ | ៥% |
| ពី | ១ ២៥០ ០០១ ៛ | ដល់ | ៨ ៥០០ ០០០ ៛ | ១០% |
| ពី | ៨ ៥០០ ០០១ ៛ | ដល់ | ១២ ៥០០ ០០០ ៛ | ១៥% |
| | | លើសពី | ១២ ៥០០ ០០០ ៛ | ២០% |

**២- ទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក** (Allowance for spouse and dependent children)

ផ្អែកលើការបង្ហាញភស្តុតាងនៃស្ថានភាពគ្រួសារ និយោជិតនិវាសនជនត្រូវបានទទួលទាយជ្ជទានសម្រាប់កាត់បន្ថយមូលដ្ឋានគិតពន្ធសម្រាប់ខែនីមួយៗ ចំពោះសហព័ទ្ធដែលធ្វើតែជាមេផ្ទះតែម្នាក់ចំនួន ៧៥ ០០០ រៀល និងកូនស្ថិតក្នុងបន្ទុកនាពេលដែលត្រូវបង់ពន្ធ ក្នុងម្នាក់ៗ ចំនួន ៧៥ ០០០ រៀល។

និយោជិតនិវាសនជនដែលមានសហព័ទ្ធដែលមិនមែនជាមេផ្ទះ ទាយជ្ជទានចំនួន ៧៥ ០០០ រៀល ខាងលើនេះមិនត្រូវបានផ្តល់ឱ្យទេ ហើយប្រសិនបើសហព័ទ្ធទាំងសងខាង (ប្តីនិងប្រពន្ធ) មានប្រាក់បៀវត្សជាប់ពន្ធទាំងពីរនាក់ ទាយជ្ជទានសម្រាប់កូនក្នុងបន្ទុកត្រូវបានផ្តល់ឱ្យតែម្ខាងប៉ុណ្ណោះ (ប្តីឬប្រពន្ធ)។

**៣- ការគណនាពន្ធលើប្រាក់បៀវត្ស** (The calculation of the Tax on Salary)

ក្នុងការគណនាពន្ធលើប្រាក់បៀវត្ស (ពបវ) ត្រូវរកមូលដ្ឋានគិត ពបវ ដោយយកប្រាក់បៀវត្សជាប់ពន្ធរបស់និយោជិតនិវាសនជននោះ ទៅដកចេញនូវទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុកសិន ប្រសិនបើមាន។

បន្ទាប់មក ធ្វើការគណនាពន្ធលើប្រាក់បៀវត្ស ដោយយកមូលដ្ឋានគិតពន្ធ ដែលស្ថិតចំថ្នាក់អត្រាណាមួយ ទៅគុណនឹងអត្រានោះតែម្តង ដោយដកចេញនូវលម្អៀងលើសប្រាក់ពន្ធសម្រាប់ថ្នាក់នោះ។

ដូច្នេះ ពបវ = (មូលដ្ឋានគិតពន្ធ x អត្រាពន្ធ) - លម្អៀងលើសប្រាក់ពន្ធក្នុងថ្នាក់ដែលត្រូវកាត់ចេញ

ដែលក្នុងនោះ÷

១.មូលដ្ឋានគិតពន្ធ = ប្រាក់បៀវត្ស - ទាយជ្ជទាន

២.លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗត្រូវបានកំណត់ដូចខាងក្រោម÷

| **ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ** | **អត្រា** | **លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់** |
|---|---|---|
| ពី 0 ៛ ដល់ ៨00 000 ៛ | 0% | 0 ៛ |
| ពី ៨00 00១ ៛ ដល់ ១ ២៥0 000 ៛ | ៥% | ៤0 000 ៛ |
| ពី ១ ២៥0 00១ ៛ ដល់ ៨ ៥00 000 ៛ | ១0% | ១0២ ៥00 ៛ |
| ពី ៨ ៥00 00១ ៛ ដល់ ១២ ៥00 000 ៛ | ១៥% | ៥២៧ ៥00 ៛ |
| លើសពី ១២ ៥00 000 ៛ | ២0% | ១ ១៥២ ៥00 ៛ |

**ឧទាហរណ៍ទី១**- *និយោជិតម្នាក់មានប្រាក់បៀវត្ស ១ 000 000 រៀល*

១. ករណីនៅលីវ

មូលដ្ឋានគិតពន្ធ = ១ 000 000 - 0 = ១ 000 000 រៀល ត្រូវជាប់ពន្ធក្នុងអត្រា ៥%

ពបវ = (១ 000 000 x ៥%) - ៤0 000

= <u>១0 000</u> ៛

២. ករណីមានប្រពន្ធ

មូលដ្ឋានគិតពន្ធ = ១ 000 000 - ៧៥ 000 = ៩២៥ 000 រៀល ត្រូវជាប់ពន្ធក្នុងអត្រា ៥%

ពបវ = (៩២៥ 000 x ៥%) - ៤0 000

= <u>**៦ ២៥0**</u> ៛

៣. ករណីមានប្រពន្ធ និងកូន១

មូលដ្ឋានគិតពន្ធ = ១ 000 000 - (៧៥ 000 x ២) = ៨៥0 000 រៀល ត្រូវជាប់ពន្ធក្នុងអត្រា ៥%

ពបវ = (៨៥0 000 x ៥%) - ៤0 000

= <u>**២ ៥00**</u> ៛

៤. ករណីមានប្រពន្ធ និងកូន២

មូលដ្ឋានគិតពន្ធ = ១ 000 000 - (៧៥ 000 x ៣)= ៧៧៥ 000 រៀល ត្រូវជាប់ពន្ធក្នុងអត្រា 0%

នោះប្រាក់ពន្ធត្រូវបង់ក្នុងករណីនេះគឺ <u>0</u> ៛

**ឧទាហរណ៍ទី២**- *និយោជិតម្នាក់មានប្រាក់បៀវត្ស ៩ 000 000 រៀល*

១. ករណីនៅលីវ

មូលដ្ឋានគិតពន្ធ = ៩ 000 000 - 0 = ៩ 000 000 រៀល ត្រូវជាប់ពន្ធក្នុងអត្រា ១៥%

ពបវ = (៩ 000 000 x ១៥%) - ៥២៧ ៥00

= <u>**៨២២ ៥00**</u> ៛

២. ករណីមានប្រពន្ធ

មូលដ្ឋានគិតពន្ធ = ៩ 000 000 - ៧៥ 000 = ៨ ៩២៥ 000 ត្រូវជាប់ពន្ធក្នុងអត្រា ១៥%

ពបវ = (៨ ៩២៥ 000 x ១៥%) - ៥២៧ ៥00

= <u>៨១១ ២៥0</u> ៛

៣. ករណីមានប្រពន្ធ និងកូន១

មូលដ្ឋានគិតពន្ធ = ៩ 000 000 - (៧៥ 000 x ២) = ៨ ៨៥0 000 ត្រូវជាប់ពន្ធក្នុងអត្រា ១៥%

ពបវ = (៨ ៨៥0 000 x ១៥%) - ៥២៧ ៥00

= <u>៨00 000</u> ៛

៤. ករណីមានប្រពន្ធ និងកូន២

មូលដ្ឋានគិតពន្ធ = ៩ 000 000 - (៧៥ 000 x ៣) = ៨ ៧៧៥ 000 ត្រូវជាប់ពន្ធក្នុងអត្រា ១៥%

ពបវ = (៨ ៧៧៥ 000 x ១៥%) - ៥២៧ ៥00

= <u>៧៧៨ ៧៥0</u> ៛

វិធីសាស្ត្រសម្រាប់គណនាពន្ធលើប្រាក់បៀវត្សអាចមានរបៀបផ្សេងទៀត ប៉ុន្តែវិធីសាស្ត្រដូចបានបង្ហាញខាងលើនេះគឺជាវិធីសាស្ត្រសាមញ្ញងាយយល់។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ស្ថាប័នរដ្ឋ និងអង្គការនានាដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ពន្ធលើប្រាក់បៀវត្ស (ពបវ) ពិតជាយកចិត្តទុកដាក់ចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្ដីណែនាំនេះប្រកបដោយប្រសិទ្ធភាព។

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីអនុវត្ត"
- អង្គការ សហគ្រាស និងក្រុមហ៊ុននានា
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០២ សហវ.

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៥

## សារាចរណែនាំ

## ស្តីពី

## ការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម

អនុលោមតាមបទប្បញ្ញត្តិនៃជំពូកទី២ នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ខែកុម្ភៈឆ្នាំ១៩៩៧ និងប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស លេខ ១១៧៣ សហវ.ពដ.ប្រក ចុះថ្ងៃទី៣១ខែធ្នូឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឱ្យមានសង្គតិភាពក្នុងការអនុវត្តកាតព្វកិច្ចពន្ធលើប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភដូចខាងក្រោម ដែលនិយោជិត កម្មករ កម្មការិនី នៃរោងចក្រនានា ទទួលបានពីការបំពេញការងារ មិនត្រូវបានគិតបញ្ចូលក្នុងមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស និងមិនមែនជាកម្មវត្ថុនៃពន្ធលើអត្ថប្រយោជន៍បន្ថែមទេ។

១. សោហ៊ុយធ្វើដំណើរពីទីកន្លែងស្នាក់នៅទៅទីកន្លែងធ្វើការឬរោងចក្រ និងពីទីកន្លែងធ្វើការឬរោងចក្រទៅកន្លែងស្នាក់នៅ និងការឧបត្ថម្ភថ្លៃស្នាក់នៅឬការផ្តល់កន្លែងស្នាក់នៅក្នុងបរិវេណរោងចក្រ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ការងារ។

២. ប្រាក់ថ្លៃបាយដែលផ្តល់ឱ្យនិយោជិត កម្មករ កម្មការិនី ទាំងអស់ដោយគ្មានបែងចែកតាមតួនាទីឬមុខងារ រួមទាំងប្រាក់ថ្លៃបាយបន្ថែមម៉ោង។

៣. មូលនិធិបេឡាសន្តិសុខសង្គម ឬមូលនិធិសុខមាលភាពសង្គមក្នុងកម្រិតដែលបានបញ្ញត្តិក្នុងច្បាប់។

៤. ប្រាក់ធានារ៉ាប់រងសុខភាព ឬបុព្វលាភធានារ៉ាប់រងអាយុជីវិតឬសុខភាពដែលផ្តល់ឱ្យដល់ និយោជិត កម្មករ កម្មការិនី គ្រប់គ្នាដោយគ្មានការបែងចែកតាមតួនាទី ឬមុខងារ។

៥. ប្រាក់ឧបត្ថម្ភទារក ឬចំណាយទារកដ្ឋាន ដែលមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ការងារ។

៦. ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ឬប្រាក់បំណាច់នៃការបញ្ឈប់លែងឱ្យធ្វើការ ក្នុងកម្រិតដែលបានបញ្ញត្តិក្នុងច្បាប់ការងារ ។

អគ្គនាយកដ្ឋានពន្ធដារ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគ្រប់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវសហការអនុវត្តតាមខ្លឹមសារនៃសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ : ១១៧៣ សហវ. ពដ. ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៣

# ប្រកាស
## ស្តីពី
# ពន្ធលើប្រាក់បៀវត្ស

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០២/នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ឆ្នាំ១៩៩៤ និង ព្រះរាជក្រមលេខ ០៨/នស/៩៤ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ឆ្នាំង២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់វិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២៩ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញប្រកាសលេខ ៣៩៦ ប្រក.សហវ.ពដ ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០០៣ ស្តីពីពន្ធលើប្រាក់បៀវត្សរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់នៃការងារគ្រប់គ្រងប្រមូលពន្ធរបស់នាយកដ្ឋានពន្ធដារ

# សំរេច:

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### ផ្នែកទី១.១ .. ប្រាក់បៀវត្សរ៍ជាប់ពន្ធ

១- ដូចមានចែងក្នុងមាត្រា ៤១ នៃច្បាប់ស្តីពីសារពើពន្ធ (ចសព) ប្រាក់ចំណូលបៀវត្សទាំងអស់ដែលបានទទួលពីសកម្មភាពបំរើការងារនានាត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ហៅកាត់ថា ពបវ ដែលជាពន្ធប្រចាំខែ។ កថាខណ្ឌ១ នៃមាត្រា ៥២ នៃ ចសព បានចែងថា ពន្ធលើប្រាក់បៀវត្ស (ពបវ) គឺជាបំណុលរបស់រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្ស ។ ប្រាក់ពន្ធនេះត្រូវប្រមូលតាមរបៀបកាត់ទុកជាមុនដោយនិយោជកនៅពេលបើកប្រាក់បៀវត្ស។

២- កថាខណ្ឌ៨ នៃមាត្រា ៤២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ (ចវសព) បានកំណត់យ៉ាងទូលាយនូវនិយមន័យប្រាក់បៀវត្ស ដោយក្នុងនោះមានរួមបញ្ចូលទាំងលាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែមដែលបានទូទាត់ឱ្យដល់និយោជិត ឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិតចំពោះការបំពេញសកម្មភាពបំរើការងាររបស់និយោជិត វៀរលែងតែការទូទាត់នានាដែលត្រូវបានលើកលែងតាមមាត្រា៤៣ និង មាត្រា៤៤ នៃចសព។

### ផ្នែកទី១.២ .. ស្ថានភាពបំរើការងារ

១- បើប្រៀបធៀបទៅនឹងសកម្មភាពវិជ្ជាជីវៈ ឬសកម្មភាពនានាឯទៀត សកម្មភាពបំរើការងារមានលក្ខណៈសំគាល់តាមស្ថានភាពដែលនិយោជិតបំពេញសកម្មភាពបំរើការងាររបស់ខ្លួននៅក្រោមឱវាទរបស់និយោជក។ ត្រូវបានចាត់ទុកថាជានិយោជិត ហើយត្រូវជាប់ ពបវ បើសិនជារូបវន្តបុគ្គលណាម្នាក់នោះមានស្ថានភាពបំរើការងារស្របតាមល័ក្ខខ័ណ្ឌចំនួនពីរ ក្នុងចំណោមល័ក្ខខ័ណ្ឌទាំងឡាយខាងក្រោមនេះ:

- ក- គ្មានហានិភ័យនៃការមិនបានទទួលប្រាក់ទូទាត់ចំពោះសកម្មភាពបំរើការងាររបស់ខ្លួនឡើយ កាលបើរូបវន្តបុគ្គលនោះបានមកធ្វើការតាមទីកន្លែងដែលបានកំណត់ ហើយបានបំពេញការងារដូចមានចែងក្នុងកិច្ចព្រមព្រៀងបំរើការងារជាទូទៅមួយ ទោះធ្វើដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរក្តី
- ខ- រូបវន្តបុគ្គលមិនអាចកំណត់ពេលវេលា និង ទីកន្លែងសម្រាប់បំពេញសកម្មភាពបំរើការងារដោយខ្លួនឯងទេ
- គ- រូបវន្តបុគ្គលពុំចាំបាច់ចំណាយដើមទុនច្រើន ដើម្បីទិញឧបករណ៍ដែលត្រូវប្រើប្រាស់សម្រាប់បំពេញសកម្មភាពបំរើការងារ
- ឃ- រូបវន្តបុគ្គលមិនបំពេញសកម្មភាពបំរើការងារឱ្យបុគ្គលច្រើននាក់ទេក្នុងពេលតែមួយ។

### ផ្នែកទី១.៣ .. វិធានៃនិវាសនដ្ឋាន និងប្រភព

១- ការដាក់អនុវត្ត ពបវ ត្រូវកំណត់ទៅតាមស្ថានភាពនិវាសនដ្ឋានរបស់និយោជិត អ្នកជាប់ពន្ធ ឬរូបវន្តបុគ្គលដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រា ៤២ ថ្មីនៃចវសព។ សំរាប់គោលដៅនៃ ពបវ និយោជិត អ្នកជាប់ពន្ធ ឬរូបវន្តបុគ្គលដែលមាននិវាសនដ្ឋាន ឬមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ ថ្ងៃនៅក្នុងរយៈពេល ១២ ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត ត្រូវបានចាត់ទុកថាជានិវាសនជនកម្ពុជា។ សំរាប់លក្ខណៈវិនិច្ឆ័យនៃនិវាសនដ្ឋាននៅកម្ពុជា រូបវន្តបុគ្គលណាដែលមានលក្ខណៈស្រប

តាមលក្ខណៈវិនិច្ឆ័យចាប់ពីមួយឡើងទៅក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងបីដូចខាងក្រោម ត្រូវបានចាត់ទុកជានិវាសនជននៅព្រះរាជាណាចក្រកម្ពុជា ៖

ក- លក្ខណៈវិនិច្ឆ័យទី១ត្រូវបានកំណត់ទៅលើនិវាសនដ្ឋានរបស់រូបវន្តបុគ្គល។ រូបវន្តបុគ្គលមាននិវាសនដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើរូបវន្តបុគ្គលនោះមានជាកម្មសិទ្ធិ ឬជួល ឬភតិសន្យា ផ្ទះ អគារ បន្ទប់ជួល អន្តេវាសិកដ្ឋាន ។ល។ ដែលអាចប្រើប្រាស់បាន ហើយដែលរូបវន្តបុគ្គលនោះតែងតែស្នាក់នៅឬកាន់កាប់។

ខ- លក្ខណៈវិនិច្ឆ័យទី២ត្រូវបានកំណត់ទៅតាមកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់រូបវន្តបុគ្គលដែលជាការកំណត់តាមរូបភាពជាក់ស្តែងនៃការស្នាក់នៅដោយផ្អែកទៅលើកត្តានានាដូចជា មជ្ឈមណ្ឌលសេដ្ឋកិច្ចរបស់រូបវន្តបុគ្គល រយៈពេលស្នាក់នៅ ចរិតនៃការស្នាក់នៅ ទីកន្លែងដែលគ្រួសាររបស់រូបវន្តបុគ្គលនោះស្នាក់នៅ គណនីធនាគាររបស់រូបវន្តបុគ្គល ទីកន្លែងដែលរូបវន្ត បុគ្គលធ្វើសកម្មភាពសង្គមជាសំខាន់។

គ- លក្ខណៈវិនិច្ឆ័យទី៣គឺវត្តមានរបស់រូបវន្តបុគ្គលនៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ ថ្ងៃក្នុងមួយលើក ឬច្រើនលើកក្នុងរយៈពេល ១២ ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត។ ក្នុងការកំណត់ចំនួនថ្ងៃស្នាក់នៅ នៅក្នុងព្រះរាជាណាចក្រកម្ពុជា វត្តមានក្នុងចំណែកណាមួយនៃថ្ងៃត្រូវរាប់ថាជាមួយថ្ងៃពេញ។

២- ដូចមានចែងក្នុងមាត្រា ៤១ នៃចសព ចំពោះបុគ្គលជានិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រាក់បៀវត្សដែលបានទទួលនៅក្នុង និងនៅក្រៅព្រះរាជាណាចក្រកម្ពុជាត្រូវជាប់ ពបវ។

៣- ដូចមានចែងក្នុងមាត្រា ៤៩ ថ្មីនៃចវចសព ចំពោះបុគ្គលជាអនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រាក់បៀវត្សដែលបុគ្គលនេះបានទទួលអំពីសកម្មភាពបំរើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ ពបវ លើកលែងតែប្រាក់បៀវត្សណាដែលជាការទូទាត់សម្រាប់សេវាបច្ចេកទេស ឬសេវាផ្សេងទៀត ហើយអ្នកបើកប្រាក់បៀវត្សឱ្យគ្មានវត្តមានក្រោមរូបភាពជាគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានប្រតិបត្តិការជាក់លាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤- និយោជិតអាចរួចផុតពីកាតព្វកិច្ចបង់ ពបវ ដូចមានចែងក្នុងកថាខណ្ឌ៣ នៃផ្នែកនេះ កាលបើបានបំពេញល័ក្ខខ័ណ្ឌទាំង៣ ដូចតទៅ ៖

ក- និយោជិតមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនលើសពី ១៨២ ថ្ងៃក្នុងមួយលើក ឬច្រើនលើកក្នុងរយៈពេល ១២ ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត

ខ- និយោជិតទទួលប្រាក់បៀវត្សដែលត្រូវបានទូទាត់ដោយ ឬក្នុងនាមនិយោជកដែលមិនមែនជានិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា

គ- និយោជិតទទួលប្រាក់បៀវត្សដែលមិនមែនជាបន្ទុករបស់គ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានប្រតិបត្តិការជាក់លាក់ដែលនិយោជកបានបើកដំណើរការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៥- ដើម្បីកំណត់ថាជានិយោជិតដែលត្រូវជាប់ ពបវ រដ្ឋបាលសារពើពន្ធត្រូវលើកយកមកពិចារណានូវដើមហេតុនានាដូចជា ៖

ក- បុគ្គលអ្នកទទួលខុសត្រូវ ឬទទួលរ៉ាប់រងការខូចខាតចំពោះការងារដែលបានអនុវត្ត

ខ- បុគ្គលអ្នកមានសិទ្ធិបញ្ជានិយោជិត

គ- បុគ្គលអ្នកគ្រប់គ្រងទីកន្លែងបំពេញការងារ បុគ្គលអ្នកកំណត់មូលដ្ឋានផ្តល់លាភការ និងកំណត់ទំនាក់ទំនងផ្សេងទៀតជាមួយនិយោជក

ឃ- បុគ្គលអ្នកផ្គត់ផ្គង់សម្ភារៈ និង ឧបករណ៍ដែលនិយោជិតត្រូវប្រើប្រាស់

ង- បុគ្គលអ្នកកំណត់ចំនួន និងកម្រិតសមត្ថភាពរបស់និយោជិតដែលត្រូវជួលឱ្យបំរើការងារ។

៦- សម្រាប់គោលដៅនៃ ពបវ លក្ខណៈសម្បត្តិជានិវាសនជនត្រូវកំណត់តាមខ្លឹមសារនៃមាត្រា ៤២ ថ្មីនៃចវចសព ដោយមិនត្រូវគិតពីស្ថានភាពខាងអន្តោប្រវេសន៍ទេ។

## ផ្នែកទី១.៤ ៈ ប្រាក់បៀវត្សរ៍រួចពន្ធ

១- ដើម្បីបានរួចពី ពបវ ប្រាក់ជំណាច់នៃការបញ្ឈប់លែងឱ្យធ្វើការ និងលាភការបន្ថែមមានលក្ខណៈខាងសង្គមកិច្ច ដូចមានចែងក្នុងកថាខណ្ឌ២ និងកថាខណ្ឌ៣ នៃមាត្រា៤៤ នៃចសព ត្រូវស្ថិតក្នុងកម្រិត និងល័ក្ខខ័ណ្ឌនៃច្បាប់ការងារ។

២- ការផ្គត់ផ្គង់ឱ្យដោយឥតយកថ្លៃ ឬយកថ្លៃទាបជាងថ្លៃដើមនូវឯកសណ្ឋាន និងបរិក្ខារសម្រាប់វិជ្ជាជីវៈពិសេស ដូចមានចែងក្នុងកថាខណ្ឌ ៤ នៃមាត្រា ៤៤ នៃចសព ត្រូវបានលើកលែង ពបវ បើសិនជានិយោជិតត្រូវបង្វិលសម្ភារៈទាំងនោះសងទៅនិយោជកវិញនៅពេលឈប់បំរើការងារ។ ដោយឡែកចំពោះឯកសណ្ឋាន គឺត្រូវមានលក្ខណៈចាំបាច់សម្រាប់បំពេញការងារ និងត្រូវបានផ្តល់ឱ្យតាមបែបបទដូចគ្នាដល់និយោជិតទាំងអស់ដែលមានតួនាទីដូចគ្នា។

៣- ប្រាក់ជំណាច់ម៉ៅការសម្រាប់ចំណាយបេសកកម្ម និងការធ្វើដំណើរដែលត្រូវផ្តល់ឱ្យសម្រាប់ជំនួសរបបទូទាត់សងវិញនូវចំណាយពិតប្រាកដ ដូចមានចែងក្នុងកថាខណ្ឌ ៥ នៃមាត្រា ៤៤ នៃចសព មិនអាចលើសពីប្រាក់ឧបត្ថម្ភរបស់រដ្ឋសម្រាប់ការងារដូចគ្នាទេ។

## ផ្នែកទី១.៥ ៈ បុគ្គលិករបស់បេសកកម្មទូត និងរដ្ឋាភិបាលបរទេស

១- ប្រាក់បៀវត្ស និង អត្ថប្រយោជន៍បន្ថែមផ្សេងទៀតដែលមន្ត្រី និងនិយោជិតនៃបេសកកម្មទូត ឬកុងស៊ុលរបស់រដ្ឋាភិបាលបរទេសណាមួយដែលកាន់លិខិតឆ្លងដែនការទូត ឬផ្លូវការរបស់ប្រទេសនោះបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវជាប់ ពបវ ទេ ។

## ផ្នែកទី១.៦ ៈ និយោជិតអង្គការអន្តរជាតិ

១- ប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែមផ្សេងទៀតដែលបានផ្តល់ឱ្យអ្នកតំណាង មន្ត្រី និងនិយោជិតដែលត្រូវបានជួលឱ្យបំរើការងារដោយទីស្នាក់ការជាគោលដើម និងរបស់អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលបរទេសនានាសម្រាប់សកម្មភាពបំរើការងារជាផ្លូវការឱ្យអង្គការទាំងនេះ មិនត្រូវជាប់ ពបវ ទេ ។

## ផ្នែកទី១.៧ ៈ និយោជិតនៃគំរោងជំនួយបច្ចេកទេស

១- ក្រៅពីរូបវន្តបុគ្គលជានិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបំរើការងារក្នុងមុខងាររដ្ឋបាល ឬជំនួយការធម្មតានៅក្នុងគំរោងការជំនួយបច្ចេកទេសដែលត្រូវជាប់ ពបវ នោះ បណ្តានិយោជិតដែលមានចុះបញ្ជាក់នៅក្នុងឯកសារគំរោងការជំនួយបច្ចេកទេសរបស់អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលបរទេសណាមួយថាជាបុគ្គលិកជំនួយបច្ចេកទេស ត្រូវបានរួច ពបវ ក្រោយពេលដែលឯកសារគំរោងការបានទទួលការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២- បើសិនជាអង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសចុះកិច្ចព្រមព្រៀងប្រគល់ការអនុវត្តន៍គំរោងការទៅឱ្យអ្នកម៉ៅការណាមួយ និយោជិតរបស់អ្នកម៉ៅការដែលបំរើការងារជាបុគ្គលិកជំនួយបច្ចេកទេសដូចមានបញ្ជាក់នៅក្នុងឯកសារគំរោងការដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ១ នៃផ្នែកនេះ ត្រូវបានរួច ពបវ ។ អ្នកម៉ៅការត្រូវកត់ត្រាឱ្យបានច្បាស់លាស់អំពីការងាររបស់បុគ្គលិកជំនួយបច្ចេកទេស និងបែងចែកឱ្យដាច់គ្នាអំពីការងារក្រៅគំរោងការ ឬអំពីបុគ្គលិកផ្សេងទៀតរបស់ខ្លួន។

# ជំពូកទី២
# ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និង ការកំណត់ប្រាក់ពន្ធត្រូវកាត់ទុក

## ផ្នែកទី២.១ .៖ ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ

១- មូលដ្ឋានគិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ គឺជាទឹកប្រាក់ទូទាត់ទាំងអស់ ទោះជាសាច់ប្រាក់ក្តី ឬជាវត្ថុក្តី លើកលែងតែទឹកប្រាក់ទូទាត់ទាំងឡាយណាដែលត្រូវបានកំណត់ថាជាអត្ថប្រយោជន៍បន្ថែម ដូចមានចែងក្នុងជំពូកទី៣ នៃប្រកាសនេះ។

២- ដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រា ៤៦ នៃចសព ប្រាក់ទាំងអស់ដែលនិយោជកឱ្យនិយោជិតក្នុងរូបភាពជាប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចី ឬប្រាក់រំដោះ ត្រូវបូកបញ្ចូលក្នុងប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ នៃខែដែលប្រាក់ទាំងនោះត្រូវបានបើកឱ្យនិយោជិត។ ចំនួនប្រាក់ដែលត្រូវបូកបញ្ចូលក្នុងប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ គឺជាចំនួនប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចី ឬប្រាក់រំដោះមិនទាន់កាត់ទុកប្រាក់ពន្ធ។

៣- ប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចី ឬប្រាក់រំដោះដែលនិយោជិតទូទាត់សងវិញ ត្រូវកាត់បន្ថយពីប្រាក់បៀវត្សជាប់ពន្ធប្រចាំខែដែលនិយោជិតបានបង់សងវិញ។ ចំពោះប្រាក់កម្ចី ការកាត់បន្ថយត្រូវបានអនុញ្ញាតតែត្រឹមចំនួនប្រាក់ដើមតែប៉ុណ្ណោះ ឯការប្រាក់ត្រូវកត់ត្រាជាប្រាក់ចំណូលរបស់និយោជក។

៤- ចំពោះគ្រួសារមួយដែលឪពុក និងម្តាយមានប្រាក់បៀវត្សជាប់ពន្ធទាំងពីរនាក់ ការកាត់បន្ថយមូលដ្ឋានកំណត់ពន្ធសំរាប់កូនក្នុងបន្ទុក ដូចមានចែងក្នុងវាក្យខ័ណ្ឌ ក នៃកថាខណ្ឌ២ នៃមាត្រា៤៦ នៃចសព អាចអនុវត្តបានតែចំពោះប្រាក់បៀវត្សជាប់ពន្ធរបស់ឪពុក ឬម្តាយតែម្នាក់ប៉ុណ្ណោះ។

៥- ដូចមានចែងក្នុងកថាខណ្ឌ៤ នៃមាត្រា ៩២ នៃចសព ប្រាក់បៀវត្សប្រចាំខែរបស់រូបវន្តបុគ្គលនិវាសនជន ឬអនិវាសនជនត្រូវជាប់ ពបវ ទោះជាប្រាក់បៀវត្សនោះបើកនៅទីណាក៏ដោយ។

## ផ្នែកទី២.២ .៖ កូនក្នុងបន្ទុក

១- កូនក្នុងបន្ទុក គឺជាកូនរបស់និយោជិតដែលមានអាយុមិនលើសពី ១៤ ឆ្នាំ ឬជាកូនរបស់និយោជិតដែលជាសិស្ស ឬនិស្សិតមានអាយុមិនលើសពី ២៥ ឆ្នាំ កំពុងសិក្សាពេញម៉ោងនៅក្នុងគ្រឹះស្ថានសិក្សាដែលមានការទទួលស្គាល់ជាផ្លូវការ ។

២- កូនក្នុងបន្ទុកត្រូវមានសំបុត្រកំណើតបញ្ជាក់ត្រឹមត្រូវ។

៣- បើសិនជាកូនស្ថិតក្នុងបន្ទុកដែលមានអាយុលើសពី ១៤ ឆ្នាំ ដល់ ២៥ ឆ្នាំ ជាសិស្ស ឬនិស្សិតកំពុងសិក្សាពេញម៉ោងនៅក្នុងគ្រឹះស្ថានសិក្សាដែលមានការទទួលស្គាល់ជាផ្លូវការ និយោជកត្រូវបង្ហាញវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាដែលបញ្ជាក់យ៉ាងច្បាស់លាស់ថាកូននោះជាសិស្ស ឬនិស្សិតកំពុងសិក្សាពេញម៉ោងពិតប្រាកដមែន។

៤- រដ្ឋបាលសារពើពន្ធមានសិទ្ធិបដិសេធនូវវិញ្ញាបនប័ត្របញ្ជាក់ការសិក្សារបស់គ្រឹះស្ថានសិក្សាណាដែលកន្លងមកធ្លាប់បានចេញវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាក្លែងបន្លំ

៥- កូនស្ថិតក្នុងបន្ទុកនៅតែត្រូវបានចាត់ទុកថាជាកូនស្ថិតក្នុងបន្ទុកដដែល នៅក្នុងខែដែលកូននោះឈានចូលអាយុ ១៥ ឆ្នាំ ឬនៅក្នុងខែដែលសិស្ស ឬនិស្សិតបញ្ចប់ការសិក្សារបស់ខ្លួនឬឈានចូលអាយុ ២៦ ឆ្នាំ។

## ផ្នែកទី២.៣ .៖ ការកំណត់ប្រាក់ពន្ធប្រចាំខែដែលត្រូវកាត់ទុក

១- ក្នុងការកំណត់ប្រាក់ពន្ធប្រចាំខែដែលត្រូវកាត់ទុក និយោជកត្រូវប្រើអត្រាកំណើនតាមថ្នាក់ ដូចមានចែងក្នុងមាត្រា ៤៧ នៃ ចសព ឬតារាងរបៀបគណនា ពបវ របស់នាយកដ្ឋានពន្ធដារ ឬកាត់ទុកប្រាក់ពន្ធចំពោះអ្នកជាប់ពន្ធអនិវាសនជន ដូចមានចែងក្នុង មាត្រា ៤៩ថ្មី នៃចសព។

# ជំពូកទី៣
# អត្ថប្រយោជន៍បន្ថែម

## ផ្នែកទី៣.១ ៖ ការកំណត់អត្ថប្រយោជន៍បន្ថែម

១- ដូចមានចែងក្នុងកថាខណ្ឌ ៨ នៃមាត្រា ៤២ ថ្មីនៃចវចសព អត្ថប្រយោជន៍បន្ថែមរួមមានទំនិញ សេវា ឬអត្ថប្រយោជន៍ជាសាច់ប្រាក់ ឬជាវត្ថុផ្សេងទៀតដែលនិយោជកផ្តល់ឱ្យដោយផ្ទាល់ ឬដោយប្រយោលដល់រូបវន្តបុគ្គលចំពោះសកម្មភាពបំរើការងារដែលរូបវន្តបុគ្គលនោះបានបំពេញដើម្បីជាផលប្រយោជន៍ដល់និយោជក។

២- ដូចមានចែងក្នុងមាត្រា ៤៨ នៃចសព អត្ថប្រយោជន៍ដែលនិយោជកផ្តល់ឱ្យដោយផ្ទាល់ ឬតាមរយៈតតិយជនដល់រូបវន្តបុគ្គល ត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែម។ អត្ថប្រយោជន៍ទាំងនោះ ជាអាទិ៍មានៈ

- ក- យានជំនិះគ្រប់ប្រភេទ
- ខ- ម្ហូបអាហារ
- គ- លំនៅដ្ឋាន ការស្នាក់នៅ
- ឃ- ទឹក ភ្លើង ទូរស័ព្ទ
- ង- អ្នកបំរើការងារក្នុងលំនៅដ្ឋាន
- ច- ប្រាក់ឱ្យខ្ចីដោយគិតការប្រាក់ទាបជាងការប្រាក់ទីផ្សារ ។ អត្រាការប្រាក់ទីផ្សារដែលត្រូវយកមកអនុវត្តត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឆ- ការលក់ទំនិញចុះថ្លៃ
- ជ- ជំនួយផ្នែកអប់រំសម្រាប់និយោជិតដែលមិនមែនជាចំណែកណាមួយនៃកម្មវិធីបណ្តុះបណ្តាលទាក់ទិនផ្ទាល់ទៅនឹងការបំពេញការងាររបស់និយោជិតនោះ
- ឈ- ជំនួយផ្នែកអប់រំសម្រាប់កូនរបស់និយោជិត
- ញ- បុព្វលាភធានារ៉ាប់រងអាយុជីវិត ឬសុខភាព លើកលែងតែមានផ្តល់អត្ថប្រយោជន៍បន្ថែមដូចគ្នាឱ្យដល់និយោជិតគ្រប់គ្នាដោយគ្មានការបែងចែកតាមតួនាទី ឬ មុខងារ
- ដ- ចំណែកនៃការឧបត្ថម្ភលើចំណាយដែលមិនសមហេតុផលនិងមិនចាំបាច់សម្រាប់អាជីវកម្មរបស់និយោជក
- ឋ- ចំនួនប្រាក់បង់ចូលមូលនិធិសុខមាលភាពសង្គមដែលលើសពីកំរិតដែលច្បាប់បានអនុញ្ញាត
- ឌ- ចំនួនប្រាក់បង់ចូលបេឡាសោធនដែលលើសពី ១០ ភាគរយ នៃប្រាក់បៀវត្សប្រចាំខែគ្មានបូកអត្ថប្រយោជន៍បន្ថែមរបស់និយោជិត
- ឍ- ចំណាយសម្រាប់ការទទួលភ្ញៀវ ការកំសាន្ត ការសំរាកលំហែ ឬការប្រើប្រាស់មធ្យោបាយណាមួយដែលទាក់ទិននឹងសកម្មភាពទាំងនេះ ដែលមិនមែនជាចំណែកណាមួយនៃទំនាក់ទំនងបំរើការងារ។

## ផ្នែកទី៣.២ ៖ ការប្រើប្រាស់យានយន្ត

១- ការប្រើប្រាស់យានយន្តក្នុងការដឹកនិយោជិត មិនត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែមទេ បើសិនជា ៖

- យានយន្តត្រូវបានចតទុកនៅក្នុងទីកន្លែងធ្វើអាជីវកម្មនៅក្រោយពេលម៉ោងធ្វើការ និងនៅក្នុងថ្ងៃឈប់សម្រាកការងារ
- យានយន្តមិនត្រូវបានប្រគល់យ៉ាងជាក់លាក់ទៅឱ្យនិយោជិតណាម្នាក់ ឬសមាជិកគ្រួសាររបស់និយោជិតណាម្នាក់នៅក្រោយពេលម៉ោងធ្វើការ

- យានយន្តមិនត្រូវបានប្រើប្រាស់ដោយនិយោជិត ឬបុគ្គលនៅក្នុងបន្ទុករបស់និយោជិតដើម្បីធ្វើការងារផ្ទាល់ខ្លួន ។

## ផ្នែកទី៣.៣ ៈ តម្លៃជាប់ពន្ធរបស់អត្ថប្រយោជន៍បន្ថែម

១- តម្លៃនៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សាររួមទាំងពន្ធអាករទាំងអស់នៃអត្ថប្រយោជន៍បន្ថែមដែលបានផ្តល់ឱ្យ ។ ចំពោះទ្រព្យដែលត្រូវវិលស់ តម្លៃទីផ្សារនៃអត្ថប្រយោជន៍បន្ថែម គឺជាចំនួនប្រាក់វិលស់ដែលបានអនុញ្ញាតដូចមានចែងក្នុងវាក្យខ័ណ្ឌ គ កថាខណ្ឌ ១ នៃមាត្រា ១៣ ថ្មីនៃចវចសព ។ ក្នុងករណីរដ្ឋបាលសារពើពន្ធមិនឯកភាពចំពោះតម្លៃទីផ្សារនៃអត្ថ - ប្រយោជន៍បន្ថែមដែលកំណត់ដោយនិយោជក រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ឡើងវិញនូវប្រាក់ពន្ធត្រូវបង់ដូចមានចែងក្នុងមាត្រា ១១៩ នៃចសព។

២- អត្ថប្រយោជន៍បន្ថែមត្រូវជាប់ពន្ធនៅក្នុងខែដែលអត្ថប្រយោជន៍បន្ថែមនោះត្រូវបានផ្តល់ទៅឱ្យនិយោជិត ដោយមិនត្រូវគិតពីកាលបរិច្ឆេទដែលអត្ថប្រយោជន៍បន្ថែមនោះត្រូវក្លាយជាបន្ទុករបស់និយោជកទេ។

៣- ដូចមានចែងក្នុងមាត្រា ៤៨ នៃចសព តម្លៃជាប់ពន្ធនៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃសរុបនៃអត្ថប្រយោជន៍បន្ថែមទាំងអស់រួមបញ្ចូលទាំងពន្ធអាករគ្រប់ប្រភេទ និងពន្ធលើអត្ថប្រយោជន៍បន្ថែមខ្លួនឯងនេះផង។ ដើម្បីគណនាតម្លៃជាប់ពន្ធនៃអត្ថ - ប្រយោជន៍បន្ថែមសម្រាប់ខែណាមួយ និយោជកត្រូវយកតម្លៃនៃអត្ថប្រយោជន៍បន្ថែមសរុបដែលបានផ្តល់ឱ្យរូបវន្តបុគ្គលទាំងអស់ក្នុងខែនោះទៅចែកនឹង **0,៨0** ។

# ជំពូកទី៤
# ឥណទានពន្ធសម្រាប់ប្រាក់ពន្ធបរទេសដែលបានបង់

## ផ្នែកទី៤.១ ៈ គោលការណ៍

១- បុគ្គលនិវាសនជនអាចទាមទារយកឥណទានពន្ធសម្រាប់ប្រាក់ពន្ធលើប្រាក់បៀវត្សដែលខ្លួនត្រូវបង់នៅក្នុងប្រទេសក្រៅណាមួយនៅក្នុងឆ្នាំណាមួយដើម្បីកាត់កងជាមួយប្រាក់ ពបវ ដែលខ្លួនត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំនោះ។ ប៉ុន្តែឥណទានពន្ធផ្តល់ឱ្យសម្រាប់ពន្ធលើប្រាក់បៀវត្សដែលបានបង់នៅប្រទេសក្រៅណាមួយ គឺជាចំនួនទាបជាងគេក្នុងចំណោម :

- ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅនោះ
- ចំនួនដែលបានមកពីការយកប្រាក់ពន្ធលើប្រាក់បៀវត្សសរុប ពីគ្រប់ប្រភពក្នុងរយៈពេលជាមួយគ្នាដែលគណនាតាមអត្រាកំណើនតាមថ្នាក់ក្នុងមាត្រា ៤៧ នៃចសព ទៅគុណនឹងផលចែករវាងប្រាក់បៀវត្សដែលបានទទួលនៅប្រទេសក្រៅនោះ និងប្រាក់បៀវត្សសរុបពីគ្រប់ប្រភព។

## ផ្នែកទី៤.២ ៈ ឥណទានសម្រាប់ប្រាក់ពន្ធបរទេសដែលនិវាសនជនបានបង់

១- ឥណទានពន្ធដែលត្រូវអនុញ្ញាតឱ្យត្រូវកំណត់ប្រចាំឆ្នាំ ដោយផ្អែកលើប្រាក់បៀវត្សសរុបដែលបានទទួល គ្មានបូកបញ្ចូលនូវអត្ថប្រយោជន៍បន្ថែមនានាដែលត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែម។

២- ដូចមានចែងក្នុងកថាខណ្ឌ ២ នៃមាត្រា ៥0 នៃចសព ភស្តុតាងឯកសារបញ្ជាក់ពីការបង់ពន្ធបរទេសមានដូចតទៅ :

ក- សេចក្តីបញ្ជាក់របស់និយោជក ឬកិច្ចសន្យាបំរើការងារដែលមានបញ្ជាក់លំអិតអំពីការងារបានបំពេញ កាលបរិច្ឆេទ និងចំនួនប្រាក់បៀវត្សបានទូទាត់សម្រាប់ការងារនៅប្រទេសក្រៅ

ខ- ច្បាប់ចម្លងនៃទម្រង់ឯកសារដែលនិយោជកបានដាក់ជូនរដ្ឋបាលសារពើពន្ធប្រទេសក្រៅនោះដើម្បីបង់ប្រាក់ពន្ធ

គ- បង្កាន់ដៃទទួលប្រាក់ពន្ធបរទេសដែលរដ្ឋបាលសារពើពន្ធប្រទេសក្រៅបានចេញឱ្យ។

៣- ឯកសារដូចបញ្ជាក់ក្នុងកថាខណ្ឌ ២ នៃផ្នែកនេះ ដែលធ្វើជាភាសាផ្សេងទៀតក្រៅពីភាសាខ្មែរ អង់គ្លេស ឬបារាំង ត្រូវភ្ជាប់មកជាមួយនូវសេចក្ដីបកប្រែដែលមានការបញ្ជាក់ទទួលស្គាល់ត្រឹមត្រូវ។

## ជំពូកទី៥

## ភារកិច្ចរបស់និយោជក

### ផ្នែកទី៥.១ ._ ការបង់ប្រាក់ពន្ធកាត់ទុក និង ពន្ធលើអត្ថប្រយោជន៍បន្ថែម

១- ដូចមានចែងក្នុងមាត្រា ៥៣ នៃចសព ចំពោះប្រាក់ពន្ធកាត់ទុកលើប្រាក់បៀវត្សរបស់រូបវន្តបុគ្គលនិវាសនជនតាមមាត្រា ៤៧ នៃចសព ប្រាក់ពន្ធកាត់ទុកលើប្រាក់បៀវត្សរបស់រូបវន្តបុគ្គលអនិវាសនជនតាមមាត្រា ៤៩ ថ្មីនៃចវចសព ប្រាក់ពន្ធកាត់ទុកលើអត្ថប្រយោជន៍បន្ថែមតាមមាត្រា ៤៨ នៃចសព និយោជកត្រូវបង់ជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ពីខែដែលបានបើកប្រាក់បៀវត្ស ឬបានផ្ដល់អត្ថប្រយោជន៍បន្ថែមតាមទម្រង់បែបបទដែលនាយកដ្ឋានពន្ធដារបានកំណត់។ ក្នុងករណីគ្មានការកាត់ទុកប្រាក់ពន្ធ ឬមានការកាត់ទុកប្រាក់ពន្ធមិនត្រឹមត្រូវដែលមិនអាចដោះស្រាយនៅកម្រិតនិយោជកបាន រដ្ឋបាលសារពើពន្ធមានសិទ្ធិតម្រូវឱ្យរូបវន្តបុគ្គលដែលទទួលប្រាក់បៀវត្ស បង់ប្រាក់ពន្ធនេះឱ្យបានត្រឹមត្រូវ។

### ផ្នែកទី៥.២ ._ ភារកិច្ចរបស់និយោជកក្នុងការកត់ត្រា ថែរក្សា និងផ្ដល់ឯកសារនិងកំណត់ត្រានានា

១- ដូចមានចែងក្នុងកថាខណ្ឌ ៣ មាត្រា ៥៤ នៃចសព និយោជក ត្រូវ :

ក- រក្សាទុកនៅក្នុងឯកសារបំរើការងាររបស់និយោជិតម្នាក់ៗ នូវពត៌មានដូចតទៅ :

- នាម និង គោត្តនាមរបស់និយោជិត
- ភេទ
- ថ្ងៃ ខែ ឆ្នាំ កំណើត និង ទីកន្លែងកំណើត
- សញ្ជាតិ
- ទីលំនៅ ឬកន្លែងស្នាក់នៅ
- មុខងារ
- កាលបរិច្ឆេទចូលបំរើការងារ និងឈប់បំរើការងារ បើសិនជាមាន
- ប្រាក់បៀវត្សប្រចាំខែដុលគ្មានអត្ថប្រយោជន៍បន្ថែម
- អត្ថប្រយោជន៍បន្ថែមដែលមានចុះក្នុងកិច្ចសន្យាបំរើការងារ

ខ- កត់ត្រាក្នុងឯកសារទូទាត់លើរាល់ការទូទាត់ដល់និយោជិតនូវពត៌មានដូចតទៅ :

- ប្រាក់បៀវត្សប្រចាំខែសរុបគ្មានអត្ថប្រយោជន៍បន្ថែមដែលបានបើកឱ្យនិយោជិត
- ពត៌មានលំអិតលើចំណាយបន្ទាប់បន្សំដែលមិនជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែម ដូចជាប្រាក់ម៉ោងបន្ថែម ប្រាក់សំណងនូវចំណាយ ហើយនិងការទូទាត់ ឬបុព្វលាភដទៃទៀត
- ការបង់ចូលមូលនិធិសុខុមាលភាពសង្គមតាមការតម្រូវនៃច្បាប់ការងារ
- ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែរបស់និយោជិតដែលត្រូវជាប់ ពបវ តាមមាត្រា ៤៧ នៃចសព
- ប្រាក់ពន្ធកាត់ទុកតាមមាត្រា ៤៧ នៃចសព

គ- កត់ត្រាអត្ថប្រយោជន៍បន្ថែមដែលបានទូទាត់ឱ្យដល់និយោជិត ដោយមានបញ្ជាក់យ៉ាងច្បាស់លាស់នូវប្រភេទ និង តម្លៃនៃអត្ថប្រយោជន៍បន្ថែមនោះ

ឃ- ក្នុងករណីដែលនិយោជកទិញអត្ថប្រយោជន៍បន្ថែមសម្រាប់ជាប្រយោជន៍ដល់និយោជិត និយោជកត្រូវរក្សាទុកនូវវិក្កយបត្រ ឬកិច្ចសន្យាទិញអត្ថប្រយោជន៍បន្ថែមនោះក្នុងឯកសារគណនេយ្យរបស់សហគ្រាស

ង- កត់ត្រាក្នុងទិនានុប្បវត្តិបើកប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែមនូវពត៌មានដូចខាងក្រោម សម្រាប់និយោជិតម្នាក់ៗ :

- លាភការដុលរបស់និយោជិតដែលត្រូវជាប់ ពបវ
- មូលដ្ឋានកំណត់ពន្ធដែលត្រូវអនុវត្តការកាត់ទុកប្រាក់ពន្ធតាមមាត្រា ៤៧ នៃចសព
- ចំនួនប្រាក់ពន្ធកាត់ទុក
- តម្លៃនៃអត្ថប្រយោជន៍បន្ថែមដែលបានផ្តល់ឱ្យ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**ផ្នែកទី៦.១.~**

១- បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ផ្នែកទី៦.២.~**

១- ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៤ តទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
ហត្ថលេខា និងត្រា

**គាត ឈន់**

**<u>ចម្លងជូន:</u>**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់អង្គភាពពន្ធដារ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទម្រង់ ពបវ ០១
Form TOS 01

# លិខិតប្រកាសពន្ធលើប្រាក់បៀវត្ស
# Return for Tax on Salary

( មាត្រា ៥៣ នៃច្បាប់ស្តីពីសារពើពន្ធ )
(Article 53 of the Law on Taxation)

សម្រាប់មន្ត្រីពន្ធដារ For Tax Official

ថ្ងៃទី [ ][ ] ខែ [ ][ ] ឆ្នាំ [ ][ ]
DD MM YY

លេខចូល Nº ……………………………

ហត្ថលេខា
Signature

ឈ្មោះមន្ត្រីពន្ធដារ ……………………………
Tax official Name

| 01 | ការិយបរិច្ឆេទសារពើពន្ធសម្រាប់លិខិតប្រកាសនេះ Period covered by this return | |
|---|---|---|
| | ពីថ្ងៃទី…… ខែ…… ឆ្នាំ…… From (DD) Month (MM) Year (YYYY) | ដល់ថ្ងៃទី…… ខែ…… ឆ្នាំ…… From (DD) Month (MM) Year (YYYY) |

| 02 | លេខអត្តសញ្ញាណកម្មសារពើពន្ធ TIN |
|---|---|
| | [ ][ ][ ][ ][ ][ ][ ][ ][ ] |

**03**

ឈ្មោះសហគ្រាស Name of Enterprise ……………………………

សកម្មភាពអាជីវកម្ម Business Activities ……………………………

អាសយដ្ឋាន Address: No……… វិថី Street……… ក្រុម Group……… ភូមិ Village………

ឃុំ/សង្កាត់ Sangkat……… ក្រុង/ស្រុក/ខណ្ឌ District……… ខេត្ត/រាជធានី Municipality………

ទូរស័ព្ទ/ទូរសារ Fax/Phone ……… សារអេឡិចត្រូនិក E-mail ………

## I. ពន្ធលើប្រាក់បៀវត្សចំពោះនិយោជិតនិវាសនជន Tax on Salary on Resident Employees :

| 04 | ចំនួននិយោជិត No. of Employee | ប្រាក់បៀវត្សត្រូវបើក Salary to be Paid | សហព័ទ្ធ Spouse | ចំនួនកូនក្នុងបន្ទុក No. of M Children | មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស Tax on Salary Calculation Base | អត្រាពន្ធ Tax Rate | ពន្ធលើប្រាក់បៀវត្ស Tax on Salary |
|---|---|---|---|---|---|---|---|
| | A | B | C | D | E = B – [(C + D) x 150,000] | F | G |
| 1 | ………… | ………… | ………… | ………… | ………… | 0% | ………… |
| 2 | ………… | ………… | ………… | ………… | ………… | 5% | ………… |
| 3 | ………… | ………… | ………… | ………… | ………… | 10% | ………… |
| 4 | ………… | ………… | ………… | ………… | ………… | 15% | ………… |
| 5 | ………… | ………… | ………… | ………… | ………… | 20% | ………… |
| សរុប Total | ………… | ………… | ………… | ………… | ………… | | ………… |

## II. ពន្ធលើប្រាក់បៀវត្សចំពោះនិយោជិតអនិវាសនជន Tax on Salary on Non-Resident Employees :

| 05 | ចំនួននិយោជិត No. of Employee | ប្រាក់បៀវត្សត្រូវបើក Salary to be Paid | | | | អត្រាពន្ធ Tax Rate | ពន្ធលើប្រាក់បៀវត្ស Tax on Salary |
|---|---|---|---|---|---|---|---|
| | A | B | | | | C | D = B x C |
| | ………… | ………… | | | | 20% | ………… |

## III. ពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម Tax on Salary on Fringe Benefit :

| 06 | ចំនួននិយោជិត No. of Employee | ទឹកប្រាក់អត្ថប្រយោជន៍បន្ថែម Fringe Benefit Amount | | | | អត្រាពន្ធ Tax Rate | ពន្ធលើប្រាក់បៀវត្ស Tax on Salary |
|---|---|---|---|---|---|---|---|
| | A | B | | | | C | D = B x C |
| | ………… | ………… | | | | 20% | ………… |

| 07 | សរុបប្រាក់ពន្ធត្រូវបង់ Total Tax Due | ………… |
|---|---|---|

យើងខ្ញុំបានពិនិត្យគ្រប់ចំណុចទាំងអស់នៅលើលិខិតប្រកាសនេះ និងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយ ។ យើងខ្ញុំមានសក្ខីបត្របញ្ជាក់ច្បាស់លាស់ ត្រឹមត្រូវ ពេញលេញ ដែលធានាបានថា ព័ត៌មានទាំងអស់នៅលើលិខិតប្រកាសនេះ ពិតជាត្រឹមត្រូវប្រាកដមែន ហើយគ្មានប្រតិបត្តិការណាមួយមិនបានប្រកាសនោះទេ ។ យើងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ទាំងឡាយជាធរមាន ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ ។ We have examined all items on this return and the annexes attached here with. We have clear, correct, and full supporting documents to ensure that all information on this return is true and accurate and there is no business operation undeclared. We are fully responsible due to the existing Laws for any falsified information.

ធ្វើនៅ ………………… ថ្ងៃទី [ ][ ] ខែ [ ][ ] ឆ្នាំ [ ][ ][ ][ ]
Filed in DD MM YYYY

**អភិបាល/បណ្ណាធិការ/កម្មសិទ្ធិករ សហគ្រាស**
Director/Manager/Owner of Enterprise
(ហត្ថលេខា និងត្រា Signature & Seal)

សម្រាប់មន្ត្រីពន្ធដារ For Tax Official

បែបបទនៃការបង់ប្រាក់ : ☐សាច់ប្រាក់ ☐មូលប្បទានបត្រ ☐បង្វែរ

ចំនួនទឹកប្រាក់……………………………

បង់តាមបង្កាន់ដៃលេខ………………… ចុះថ្ងៃទី……/……/……

លរ.លន គណនេយ្យកម្ម………………… ថ្ងៃធ្វើ……/……/……

ឈ្មោះមន្ត្រីពន្ធដារ………………… ហត្ថលេខា …………………

## តារាងលម្អិតអំពីពន្ធលើប្រាក់បៀវត្សចំពោះនិយោជិតនិវាសនជន Details on the Tax on Salary on Resident Employees :

| លរ<br>No. | ឈ្មោះនិយោជិត<br>Name of Employee | សញ្ជាតិ<br>Nationality | មុខងារ<br>Function | ប្រាក់បៀវត្សត្រូវបើក<br>Salary to be Paid | សហព័ទ្ធ<br>Spouse | កូនក្នុងបន្ទុក<br>Minor Children | ទឹកប្រាក់កាត់បន្ថយ<br>Allowance | មូលដ្ឋានគិតពន្ធ បវ<br>Salary Tax Calculation Base | អត្រាពន្ធ<br>Tax Rate | ពន្ធលើប្រាក់បៀវត្ស<br>Tax on Salary | កំណត់សម្គាល់<br>Remarks |
|---|---|---|---|---|---|---|---|---|---|---|---|
| | A | B | C | D | E | F | G = ( E + F ) x 150,000 | H = D - G | I | J | K |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

វិធីគណនាពន្ធលើប្រាក់បៀវត្ស :
Calculation Method of Tax on Salary :

ប្រសិនបើ : - មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស (H) មានចំនួនចាប់ពី សូន្យរៀល ដល់ ១,២០០,០០០ រៀល ត្រូវជាប់ពន្ធតាមអត្រា 0%
If : the Salary Tax Calculation Base (H) is from 0 Riel to 1,200,000 Riel , it is taxed at 0%

- មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស (H) មានចំនួនចាប់ពី ១,២០០,០០១ រៀល ដល់ ២,០០០,០០០ រៀល ត្រូវជាប់ពន្ធតាមអត្រា ៥% វិធីគណនាគឺ : [មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស(H) x ៥%] – ៦០,០០០
the Salary Tax Calculation Base (H) is from 1,200,001 Riel to 2,000,000 Riel , it is taxed at 5% and the method for calculation is : [ Salary Tax Calculation Base (H) x 5% ] – 60,000

- មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស (H) មានចំនួនចាប់ពី ២,០០០,០០១ រៀល ដល់ ៨,៥០០,០០០ រៀល ត្រូវជាប់ពន្ធតាមអត្រា ១០% វិធីគណនាគឺ : [មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស (H) x ១០%] – ១៦០,០០០
the Salary Tax Calculation Base (H) is from 2,000,001 Riel to 8,500,000 Riel , it is taxed at 10% and the method for calculation is : [ Salary Tax Calculation Base (H) x 10% ] – 160,000

- មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស (H) មានចំនួនចាប់ពី ៨,៥០០,០០១ រៀល ដល់ ១២,៥០០,០០០ រៀល ត្រូវជាប់ពន្ធតាមអត្រា ១៥% វិធីគណនាគឺ : [មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស (H) x ១៥%] – ៥៨៥,០០០
the Salary Tax Calculation Base (H) is from 8,500,001 Riel to 12,500,000 Riel , it is taxed at 15% and the method for calculation is : [ Salary Tax Calculation Base (H) x 15% ] – 585,000

- មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស (H) មានចំនួនចាប់ពី ១២,៥០០,០០១ រៀល ឡើងទៅ ត្រូវជាប់ពន្ធតាមអត្រា ២០% វិធីគណនាគឺ : [មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស (H) x ២០%] – ១,២១០,០០០
the Salary Tax Calculation Base (H) is from 12,500,001 Riel and over , it is taxed at 20% and the method for calculation is : [ Salary Tax Calculation Base (H) x 20% ] – 1,210,000

## តារាងលម្អិតអំពីពន្ធលើប្រាក់បៀវត្សចំពោះនិយោជិតអនិវាសនជន និងពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម Details on the Tax on Salary on Non-Resident Employees and Tax on Salary on Fringe Benefit :

| លរ<br>No. | ឈ្មោះនិយោជិត<br>Name of Employee | សញ្ជាតិ<br>Nationality | មុខងារ<br>Function | ប្រាក់បៀវត្សត្រូវបើក/អត្ថប្រយោជន៍បន្ថែម<br>Salary to be Paid/Fringe Benefit | អត្រាពន្ធ ២០%<br>Tax Rate 20% | ពន្ធលើប្រាក់បៀវត្ស<br>Tax on Salary | កំណត់សម្គាល់<br>Remarks |
|---|---|---|---|---|---|---|---|
| | A | B | C | D | E | F = D x E | G |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

កំណត់សម្គាល់ : ប្រសិនសរសេរមិនអស់ សូមភ្ជាប់ជាមួយក្នុងក្រដាសដោយឡែក ។
**Notes** : Please use separate sheets if the space is insufficient.

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION
នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
DEPARTMENT OF LARGE TAXPAYERS
លេខ ២៦៣៩ ... អពដ/នអធ
N° ... GDT/LTD

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

# សេចក្តីជូនដំណឹង
## ស្តីពីអត្រាប្តូរប្រាក់ផ្លូវការប្រចាំខែ ឧសភា ឆ្នាំ២០១៩

**យោង៖** សេចក្តីជូនដំណឹងស្តីពីអត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃ ពីថ្ងៃទី០១ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ របស់ធនាគារជាតិ នៃកម្ពុជា។

| ថ្ងៃ (Date) | អត្រាប្តូរប្រាក់ (Exchange Rate) | | ផ្សេងៗ (Other) |
|---|---|---|---|
| 01-02 | 1$ | 4,055 រៀល | |
| 03-05 | 1$ | 4,058 រៀល | |
| 06-07 | 1$ | 4,060 រៀល | |
| 08-15 | 1$ | 4,055 រៀល | <u>បៀវត្ស</u> |
| 16-20 | 1$ | 4,053 រៀល | |
| 21-22 | 1$ | 4,050 រៀល | |
| 23-26 | 1$ | 4,051 រៀល | |
| 27-28 | 1$ | 4,053 រៀល | |
| 29 | 1$ | 4,055 រៀល | |
| 30 | 1$ | 4,058 រៀល | |
| 31 | 1$ | 4,062 រៀល | |
| **សរុបមធ្យមភាគប្រចាំខែ គិតចាប់ពីថ្ងៃទី០១-៣១** | 1$ | ***<u>4,055</u>*** រៀល | **<u>មធ្យម</u>** |

ថ្ងៃសុក្រ ១៣រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩
**ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ**

**អេង_វុតនា**

អគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 88 46 72, ទូរសារ: (+855) 23 886 700, Email: dlt@tax.gov.kh, Website: www.tax.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ៤៤៤ ក.ប/ប្រ.ក.ខល

# ប្រកាស
# ស្តីពី
# ការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០២០ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៣៩ និងមាត្រា១៤៤ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១០ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៨៧ ចំណងជើងចំណុច "គ" ផ្នែកទី៣ នៃជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២ នៃច្បាប់ស្តីពីការងារដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ


អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

# សម្រេច

**ប្រការ១ .-**

ចាប់ពីខែមករា ឆ្នាំ២០១៩ តទៅ ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងឡាយណា ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារត្រូវរៀបចំឲ្យមានការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតចំនួន ២(ពីរ)ដងក្នុងមួយខែ ដោយត្រូវបើកលើកទី១ ក្នុងសប្តាហ៍ទី២(ពីរ) និងលើកទី២ ក្នុងសប្តាហ៍ទី៤(បួន) នៃខែនីមួយៗ តាមបែបបទដូចខាងក្រោម៖

- លើកទី១ គឺស្មើនឹងចំនួន ៥០%(ហាសិបភាគរយ) នៃប្រាក់ឈ្នួលសុទ្ធសាធក្នុង ១(មួយ)ខែ
- លើកទី២ គឺស្មើនឹងចំនួនប្រាក់ឈ្នួលសុទ្ធសាធដែលនៅសល់ ប្រាក់ឈ្នួលបន្ទាប់បន្សំ និងអត្ថប្រយោជន៍ផ្សេងៗទៀត ដែលកម្មករនិយោជិតត្រូវទទួលបាននៅក្នុងខែនីមួយៗ។

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ប្រធាននាយកដ្ឋានវិវាទការងារ ប្រធានអង្គភាពក្រោមឱវាទនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ១២កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សហជីព និងសមាគមនិយោជកគ្រប់លំដាប់ថ្នាក់
  *"ដើម្បីជូនជ្រាប"*
- ដូចប្រការ៣
  *"ដើម្បីអនុវត្ត"*
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ